សៃម - ស្វរ
សាស្ត្រាចារ្យបរិញ្ញាប័ត្រអក្សរសាស្ត្រខ្មែរ
វិទ្យាល័យភ្នំដូនពេញ

មេរៀន

# វប្បធម៌ · ឥណ្ឌាខ្មែរ

មានតែងសេចក្តីគំរូ
សម្រាប់ថ្នាក់ទីបញ្ចប់



ស្របតាមកម្មវិធីថ្មី

បណ្ណាគារ
មូលមិត្ត ភូបលេខ ៩៩ ផ្សារចាស់
រក្សាសិទ្ធិគ្រប់យ៉ាង

១៩៧១

CA 19

រឹសម - ស្វះ
សាស្ត្រាចារ្យបរិញ្ញាប័ត្រអក្សរសាស្ត្រខ្មែរ
វិទ្យាល័យភ្នំដូនពេញ

សង្ខេបមេរៀន

# វប្បធម៌ និងអក្សរខ្មែរ

## មានតែងសេចក្តីគំរូ
## សម្រាប់ថ្នាក់ទីបញ្ចប់

បណ្ណាគារ
មូលមិត្ត ផ្ទះលេខ ៥៩ ផ្សារចាស់

រក្សាសិទ្ធិគ្រប់យ៉ាង

-១៩៧១-

# កម្មវិធីថ្នាក់ទីបញ្ចប់

## វប្បធម៌ - អរិយធម៌ខ្មែរ

### ១.– សេចក្តីផ្តើម

– វត្ថុបំណងនិងន័យនៃការសិក្សាវប្បធម៌ - អរិយធម៌ខ្មែរ

– ទំនាក់ទំនងរវាងវប្បធម៌-អរិយធម៌

– ការសិក្សាប្រៀបធៀបវប្បធម៌ឥណ្ឌានិងវប្បធម៌ខ្មែរ

### ២– មូលធម៌នៃវប្បធម៌ឥណ្ឌា

១– វេទនិយម (បញ្ញាពុទ្ធិ, ការៈ, សុខៈ)

២– ព្រាហ្មណ៍និយម (បញ្ញាពុទ្ធិ, ការៈ, សុខៈ)

ក) ព្រហ្មនិយម

ខ) វិស្ណុនិយម

គ) សិវនិយម

៣– ពុទ្ធសាសនា (លទ្ធិពុទ្ធ)

ក) ពុទ្ធប្រវត្តិ – ពុទ្ធប្រវត្តិសង្ខេប

– ពន្លឺអាស៊ីទ្វីប

– ពិធីព្រះពុទ្ធសាសនា (ល្វី ហ្វីណុត)

ខ) ពុទ្ធលទ្ធិ – អរិយសច្ចធម៌ (ក៊ុម - ស៊ី)

– ទស្សនវិជ្ជានិងពុទ្ធសាសនា (ប៉ាំង - ខាត់)

### ៣– មូលធម៌នៃវប្បធម៌ខ្មែរ

– ព្រាហ្មណ៍និយម (ក្នុងសិល្បៈ អក្សរសិល្ប៍ ជំនឿ ទំនៀមទំលាប់)

– ពុទ្ធនិយម ( " )

– ខ្មែរនិយម ( " )

– បរទេសនិយម ( " )

### ៤– មូលបទនៃវប្បធម៌ឥណ្ឌា - ខ្មែរ (ដូចក្នុងផ្នែកទី២ - ប្រៀបធៀប)

### ៥– យោបល់បញ្ចប់

– តម្លៃនៃវប្បធម៌ខ្មែរក្នុងក្របខ័ណ្ឌអរិយធម៌ពិភពលោក ។

× × ×

# សង្ខេបមេរៀន

## វប្បធម៌ឥណ្ឌា - ខ្មែរ

### សេចក្ដីផ្ដើម-

ប្រជាជាតិខ្មែរយើង ជាជាតិសាសន៍មួយមានគ្រឹះ តាំងមូលដ្ឋានជាតិ និងលក្ខណៈជាតិច្បាស់លាស់ - តែចុះនឹងមានប្រជាជាតិនានាជាតិនៅជ្រោយសុវណ្ណភូមិនេះ ព្រោះខ្មែរមានវប្បធម៌-អរិយធម៌ផ្ទាល់ខ្លួន និងពិតប្រាកដជាងគេតាំងពីដើម ព្រោះមានភស្តុតាងនៅជាក់ច្បាស់ទាល់សព្វថ្ងៃ ហើយការមានវប្បធម៌-អរិយធម៌ នៃជនជាតិខ្មែរ បានជះឥទ្ធិពលមកលើ គឺវប្បធម៌-អរិយធម៌ នៅតែរក្សាលក្ខណៈនិងបុគ្គលភាពរបស់ខ្លួនដដែល ។

ក្នុងចំណោមវប្បធម៌ - អរិយធម៌នានាដែលបានផ្សាយចូលមកស្រុកខ្មែរនៅសម័យដើម, វប្បធម៌-អរិយធម៌ឥណ្ឌាបានផ្សាយឥទ្ធិពលមកលើវប្បធម៌ - អរិយធម៌ខ្មែរមុនគេ ហើយដោយទៅក្នុងសភាពលក្ខណៈរបស់ខ្លួន មានធាតុ, មូលដ្ឋានស្របខ្លួនត្រូវជាតុគ្នានឹងលក្ខណៈខ្មែរ ទើបខ្មែរទទួលយកមកទុកដាក់ក្នុងវប្បធម៌អរិយធម៌របស់ខ្លួនដោយងាយ ប៉ុន្តែខ្មែរពុំបានទទួលយកទាំងស្រុង ទាំងដុលមកទុកដាក់ជារបស់ខ្លួនទេ គឺខ្មែរបានកែច្នៃប្រែឲ្យមានលក្ខណៈ និងបុគ្គលភាពស្របស្រួលតាមលក្ខណៈនិងបុគ្គលភាពរបស់ខ្មែរស្ទើរតែទាំងអស់ ទោះក្នុងព្រាហ្មណ៍និយមក៏ដូចពុទ្ធនិយមដែរ ។

ដោយហេតុនេះហើយ បានជាក្នុងការសិក្សាស្វែងយល់ពីវប្បធម៌ - អរិយធម៌ខ្មែរ អ្នកសិក្សាត្រូវសិក្សាភ្ជាប់នូវវប្បធម៌ឥណ្ឌានិងខ្មែរ ព្រមទាំងធ្វើការគប់ប្រៀបគ្នានូវធាតុដើមនៃវប្បធម៌ទាំងពីរនេះផង ជាពិសេសអ្នកសិក្សាត្រូវតែសិក្សានូវធាតុសំខាន់ៗ នៃវប្បធម៌ទាំងពីរដែលទាក់ទងគ្នានេះឯង ។

### អត្ថន័យ-

ពាក្យ "វប្បធម៌" សំគាល់សំដៅ, កិច្ចការ, ផ្លូវចិត្តនិងរូបកាយនៃសកម្មភាពរបស់មនុស្សជាតិនីមួយៗ ដែលមានការរីកលូតលាស់ដោយគេឃើញ - ជាក់ស្ដែងតាមបន្តុបដាយរបស់ខ្លួន ។ ធាតុ - វិធីប្លុងមិភាពមួយ ដែលមនុស្សជាតិបានសាបព្រោះដាក់ បង្កបង្កើតសម្រាប់ស្ដែង

មនុស្ស ។ មិនតែប៉ុណ្ណោះ វប្បធម៌ជាសាខានៃកត្តាលើកស្ទួយរបស់ទាំងជាការលេចមុខនៃថែមទៀត ។

ចំពោះពាក្យអរិយធម៌វិញ គឺជាកំលាំងនៃវប្បធម៌ហ្នឹងឯង ។ គេច្រើនតែភ្ជាប់ពាក្យ អរិយធម៌ជាមួយនឹងពាក្យវប្បធម៌ ដូចជាវប្បធម៌-អរិយធម៌ ប៉ុន្តែពាក្យ ២ ម៉ាត់សម្រាប់សំគាល់ផលនៃពលកម្មមនុស្សជាតិយ៉ាងណា ព្រោះវប្បធម៌កើតមុន ហើយទើបកើតចេញជាអរិយធម៌និមួយៗ តាមសង្គមជាតិរបស់ខ្លួនរៀងៗខ្លួន ។ ដូច្នេះយើងនឹងឃើញភាពខុសគ្នារវាងវប្បធម៌-អរិយធម៌នោះ តើអរិយធម៌មានអ្វីខ្លះ ? ហើយវប្បធម៌មានអ្វីខ្លះ ?

- **អរិយធម៌**
  - វប្បធម៌
    - ចំណេះ
      - ជំនឿ
      - សាសនា
      - វិជ្ជា
    - ការផ្សាយ
      - សញ្ញា
      - អក្សរ - ភាសា
      - សិល្បៈ
    - អនុវត្តន៍
      - ទំនៀមទំលាប់ - ប្រពៃណី
      - ការសិក្សា - អប់រំ
      - ល្បែង - កីឡា
  - សង្គមធម៌
    - ប្រដាប់ប្រដា
      - គ្រឿងរស់
      - គ្រឿងរបរ
      - គ្រឿងបច្ចេកទេស
    - របៀបរបប
      - សេដ្ឋកិច្ច
      - សង្គមកិច្ច
      - នយោបាយ
    - ទ្រង់ទ្រាយសង្គម
      - ក្រុមគ្រួសារ
      - ជាន់ថ្នាក់
      - អង្គការ

ដូច្នេះ វប្បធម៌និងសង្គមធម៌ ជាមូលដ្ឋាននៃអរិយធម៌នេះឯង ហើយនៅក្នុងវប្បធម៌មានចែកជាពីរពួក ១ ជាចង្ក្រម ១ ថែមទៀត ។

× × ×

# មូលដ្ឋាន
# នៃប្រវត្តិខ្មែរ

បានជាយើងលើកយកបញ្ហានេះ មកល្បងសិក្សាជាមុនដូច្នេះ ដោយហេតុថា យើងត្រូវស្គាល់ប្រវត្តិដើមនៃខ្លួនយើងជាមុនសិន មុននឹងស្គាល់ប្រវត្តិមួយចំនួនទៀត គឺប្រវត្តិឥណ្ឌា - ខ្មែរហើយនិង ព្រោះថ្មីៗនេះយើងពិតជាមានប្រវត្តិស្រុកកម្ពុជា ដែលជារបស់ខ្មែរផ្ទាល់នេះប្រាកដស្រេចហើយ ទើបមានប្រវត្តិថ្មីដែលឥណ្ឌានាំចូលមកប្រទេសយើង ។ ដំបូងយើងត្រូវស្គាល់តាមលំដាប់ខាងក្រោមនេះ ៖

## ១- កំណើតជនជាតិខ្មែរ

**ក) អំបូរពូជសាសន៍** — គឺពូជសាសន៍មន - ខ្មែរ ដែលស្ថិតនៅក្នុងក្រោយសុវណ្ណភូមិ (ដែនដីសម្បូណ៌មាស) មានជាតិសាសន៍ជាមនុស្សជាតិដើមនៅលើទឹកដីនេះផង មកពីឥណ្ឌា – ជ្វា – ចិន ផង ។

**ខ) ឈ្មោះខ្មែរ** — បើយោលទៅតាមប្រវត្តិសាស្ត្រ ពាក្យថា ខ្មែរ (ខ្មែរៗ) មកពីពាក្យកម្ពុ ជាឈ្មោះរបស់មួយអង្គ ចិនទាំងអស់ដែលជាប្រភពដើមកម្ពុ ។ ការហៅឈ្មោះរបស់កម្ពុជិនទាំងមេកបានជាកម្ពុមេក > កម្មេក > កមេក > កមេរ > ក្មេរ > ក្មែរ > ខ្មែរ នេះឯង ហើយក្នុងសិលាចារឹកមានសរសេរជាក្មេរឬក្មែរ តែប៉ុណ្ណោះ ។

បើតាមឯកសារខ្លះទៀត ពាក្យថា "ខ្មែរ" នេះ ក្លាយមកពីពាក្យថា "គុមេរុ" គឺជាឈ្មោះដែនដីមួយដែលនៅប្រទេសឥណ្ឌាសម័យបុរាណ ។ ហើយក្នុងសម័យមហានគរ គេក៏សរសេរថា "ក្មេរ ឬក្មែរ" នៅឡើយ ។ តំណតមក ពាក្យ ក្មេរ ឬ ក្មែរនេះ ក៏ក្លាយរូបមកជា "ខ្មែរ" ដូចសព្វថ្ងៃ ។

## ២-អំពីកំណើតស្រុកខ្មែរ

### ក-កំណកំណើត·-

ស្រុកទេសខ្មែរកើតដោយក្លាយស្រុកចេនឡាខ្មែរគោកលើ (ខាងជើង) និងស្រុកនគរភ្នំ(ហ្វូណន) គោកក្រោម (ខាងត្បូង) ។

### ខ-ពេលវេលា·-

មនុស្សបុរាណរស់នៅលើស្រុកខ្មែរនេះតាំងពីប្រហែល ៦ សែនឆ្នាំមកមុន គ.ស ហើយបើគិតពីការក្លាយស្រុកចេនឡា និងហ្វូណន គឺនៅដើមសតវត្សទីមួយនៃ គ.ស ។

## ៣-កំណើតវប្បធម៌ខ្មែរ

ក-អ្នកបង្កើត- គឺខ្មែរ · មន · សម្រែ · ពនង

ខ-ពេលវេលា- ពី ៦ សែនមក ១៦.០០០ ឆ្នាំមុន គ.ស

គ-ទីកន្លែង- នៅសំរោងសែន (កំពង់ឆ្នាំង) ម្លូព្រៃ (កំពង់ធំ)

ឃ-វត្ថុប្រើប្រាស់- ពាងក្អម · ឆ្នាំង · ចាន ។ល។

## ៤- ចំណែកនៃវប្បធម៌ខ្មែរ

ដើម្បីងាយស្រួលសិក្សាអំពីវប្បធម៌ខ្មែរជាផ្នែកៗ គេត្រូវចែកវប្បធម៌នេះជា៤ផ្នែកគឺ:

ក- វប្បធម៌បុរេប្រវត្តិ តាំងពីដើមមកដល់គ្រិស្តសតវត្សទី១ ។

ខ- វប្បធម៌មុនអង្គរ- ពីសតវត្សទី១ ដល់សតវត្សទី៨ នៃ គ.ស ។

គ- វប្បធម៌សម័យអង្គរ- ពីសតវត្សទី៨ ដល់សតវត្សទី ១៣ ។

ឃ- វប្បធម៌ក្រោយសម័យអង្គរ- ពីសតវត្សទី១៤ ដល់ទី១៩ នៃ គ.ស ។

### កំណត់ចំណាំ·-

គេទាំងយើងនឹងសិក្សានៃវប្បធម៌បុរេប្រវត្តិតែមួយផ្នែកប៉ុណ្ណោះ ដោយហេតុថា វប្បធម៌ខ្មែរផ្នែកនេះ ពុំទាន់មានវប្បធម៌ណាចូលមកជ្រាបឥទ្ធិពលទាក់ទងនៅឡើយ ។

## វប្បធម៌បុរេប្រវត្តិ.–

**វប្បធម៌បុរេប្រវត្តិ**

១– ជំនឿ
- ជឿខ្មោច - ព្រាយ - អាប - អ្នកតា
- សៀនអារក្ស - អ្នកតា - បង់បត់
- ធ្វើពិធីបួង [illegible]

២– វិជ្ជា
- ចេះកាយដីធ្វើស្រែ-ចំការ-ក្រឡ
- ចេះយកដែកធ្វើកាំបិត-ពូថៅ-ព្រួញ
- ចេះធ្វើស្រាផឹក

៣– ភាសា–អក្សរ
- ភាសាខ្មែរ-មន
- គ្មានប្រើអក្សរ

៤– សិល្បៈ
- ចេះធ្វើកណាត់សំពត់
- ចេះធ្វើពាង-ក្រឡ-កន្ថៃ-ជើង
- ចេះធ្វើក្បាច់ល្អៗ

៥– ទំនៀមទម្លាប់
- ស្រីៗចេះធ្វើបង្វិលការនៅផ្ទះ
- ប្រុសៗធ្វើការខាងក្រៅ
- កប់ខ្មោចឲ្យអង្គុយក្នុងពាង

## យោបល់រួម.–

ខ្មែរមានវប្បធម៌រួចមកហើយ តាមមនោគតិ តាមទំនោរចំណង់ចិត្តគាត់ពីសម័យដើមបង្អស់ ហូតដល់ពេលដែលវប្បធម៌ណាមួយចូលមកផ្សព្វផ្សាយជាមួយនឹងវប្បធម៌ខ្មែរ នៅដើមគ្រិស្តសតវត្សទី ១ នោះឯង ។

× × ×

## ១- មូលធម៌នៃវប្បធម៌ឥណ្ឌា

### វិភាគវប្បធម៌ឥណ្ឌា.-

តាមធម្មតា គេតែងតែចែកវប្បធម៌ឥណ្ឌាជា ៤ ផ្នែក ព្រោះផ្នែកនីមួយៗ គឺជាមូលដ្ឋានទ្រទ្រង់វប្បធម៌នោះទាំងមូលគឺ :

១-វេទនិយម

២-ព្រាហ្មណ៍និយម

៣-ហិណ្ឌូនិយម

៤-ពុទ្ធនិយម

គោលនិយមមួយៗ ត្រូវមាន ៣ ផ្នែកទៀត លើកលែងតែហិណ្ឌូនិយមមួយចេញ ដែលមានគោលនិយម ៣ ដែរ តែផ្សេងគ្នា ។ គោលនិយមក្នុងវេទនិយម, ព្រាហ្មណ៍និយម និងពុទ្ធនិយមមាន ៣ ផ្នែកដូចគ្នាគឺ :

ក-បញ្ហា ពុទ្ធិ La Connaissance

ខ-បញ្ហា ភាព L'être

គ-បញ្ហាសុខ: Le Bonheur

រីឯហិណ្ឌូនិយម មាន ៣ ផ្នែកដែរគឺ:

ក-ព្រហ្មនិយម

ខ-វិស្ណុនិយម

គ-សិវនិយម

គួរចំណាំថា នៅក្នុងព្រាហ្មណ៍និយម ក៏មានបញ្ហាព្រះព្រហ្ម, វិស្ណុ និង សិវៈនេះដែរ ។

### វេទនិយម

១- ន័យនៃវេទនិយម.-

លើគម្ពីរវេទ ។ គម្ពីរនេះ ជាចំណេះវិជ្ជា, គំនិត, កម្រងមន្តអាគម, អត្ថបទ, មូលដ្ឋាននិងជាវិធីរៀបរៀបចំសង្គមមនុស្ស ដែលពួកអារ្យាន់ នាំចូលមកក្នុងប្រទេសឥណ្ឌា ។

## ២- អ្នកបង្កបង្កើត.-

ក- តាមមតិយោបល់ព្រាហ្មណ៍.- គឺជាអាទិទេពឈ្មោះបុរុសៈ ដែលផ្តល់ក្បួនវេទ មកឲ្យឥសីៗបានយកមកបង្ហាត់បង្ហាញផ្តល់ឲ្យពួកព្រាហ្មណ៍ ។

ខ- តាមចលនាប្រវត្តិសាស្ត្រ.- គឺពួកមិលក្ខៈនិងពួកអាយ៉ិន ដែលបាន រួមគំនិត, មនោគតិ បង្កើតគម្ពីរវេទនេះឯង ព្រោះមិលក្ខៈនេះ ជាពួកមនុស្សដែលជាម្ចាស់ដើមនៃស្រុកឥណ្ឌា ឯពួកអាយ៉ិនជាពនេចរ (ចរព្រៃ) ដែលបានមកបង្កំលុកលុយប្រទេសឥណ្ឌាផ្នែកខាងជើង ហើយដោយខ្លួនខ្លាំងពួក មានវប្បធម៌នៅក្នុងខ្លួនស្រាប់ ក៏ផ្តើមបង្កើតគម្ពីរវេទនេះឡើង ។

## ៣- រយៈពេលបង្កើត.-

គម្ពីរវេទត្រូវពួកមិលក្ខៈនិងអាយ៉ិន បង្កើតឡើងក្នុងរយៈពេល ពី១៥០០ដល់១០០០ឆ្នាំ មុន គ.ស ។

## ៤- ចំណែកនៃគម្ពីរវេទ.-

គម្ពីរវេទ ចែកចេញជា ៤ ផ្នែកគឺ:

ក- ឫគ្វេទ (ឫគវេទ) **Rgveda** .- ជាគម្ពីរមានចំណាស់ជាងគេ ហើយជាគម្ពីរមានគាថាសម្រាប់សូត្រ អង្វរបន់ស្រន់ បួងសួងសរសើរអាទិទេព និងសូត្រធ្វើរីត៍ ( Rite ), សូត្រក្នុងពិធីបូជាយញ្ញ ។

ខ- យជុរវេទ **Yajurveda** .- ជាគម្ពីរដែលមានចំណាស់បន្ទាប់ពី គម្ពីរឫគ្វេទប្រហែល ៦០០ ឆ្នាំមុន គ.ស. មានចែងគាថាសំរាប់ធ្វើរីត៍ និងបទពន្យល់អំពីរីត៍ ក្នុងពិធីបូជាយញ្ញផ្សេងៗ ។ ជាងនេះទៀត មានការរៀបរៀងចង្វាក់តន្ត្រីសំរាប់បូជាផ្សេងទៀត ដូចជា:

-ការបូជាចំពោះទេវតា ដែលមហាក្សត្រនិងព្រាហ្មណ៍ត្រូវធ្វើឡើង ។

-ការបូជាក្នុងពិធីរាជាភិសេក ។

– ពិធីបូជាដែលមហាក្សត្រត្រូវធ្វើ ដើម្បីពង្រីកទឹកដីទៅជាចក្រពត្រាធិរាជ (អស្វមេធ) ។

គ– សាមវេទ Samaveda.– ជាគម្ពីរកើតក្នុងពេលជាមួយនឹងយជុរវេទដែរ គឺជាក្បួនដែលរៀនអំពីបទចម្រៀងពីតិកៈ សម្រាប់ច្រៀងពណ៌នាស្តុតិសរសើរបន្ទន់ចិត្តព្រះឥន្ទជាដើម ក្នុងពេលបូជាយញ្ញសោម ។ ដែលគឺមាន :

– ចម្រៀងសម្រាប់ច្រៀងក្នុងព្រៃ ។

– ចម្រៀងសម្រាប់ច្រៀងក្នុងភូមិស្ថាន ដើម្បីសុខសួស្តី ។

ឃ– អថវវេទ Atharvaveda.– ជាគម្ពីរកើតក្រោយបង្អស់ ហើយជាគម្ពីរបរិយាយមានវេទមន្ត ស្នេហ៍កាគម សម្រាប់ស្ត្រីឲ្យគេស្រឡាញ់ និងសម្រាប់បណ្តេញខ្មោចបីសាចឲ្យខ្លាច ។

## ឃ្លាបញ្ចប់សេចក្តី.–

គោលគំនិតនៃគម្ពីរវេទទាំង ៤ គេនាំគ្នាពាក់ព័ន្ធនឹងសម្ព័ន្ធប្រវត្តិ ដែលបានលើកយកបញ្ហាដែលជាគោលនិយមទូទៅ ៣ យ៉ាង គឺ បញ្ញាគតិ, កាមៈ និងសុខៈ មកដោះស្រាយជានិច្ច ។

## បញ្ហាពុទ្ធិក្នុងទេវនិយម

ពុទ្ធិ បានដល់ការចេះដឹង, វិជ្ជា, គំនិត, យោបល់យល់ ដែលមានសភាពនៅខាងក្រៅនិងខាងក្នុងនៃមនុស្សលោក ។ ចំណែកនៃពុទ្ធិ មាន ៣ ប្រភេទគឺ :

១– ពុទ្ធិវត្ថុ Objet de la connaissance

២– ពុទ្ធិវិធី Méthode de la connaissance

៣– ពុទ្ធិវាទ Théorie de la connaissance

### ១– ពុទ្ធិវត្ថុ Objet de la connaissance.–

បានដល់វត្ថុទាំងឡាយ គ្រឿងប្រកបខាងក្រៅសម្រាប់បង្កើតពុទ្ធិ ដែលជាវិជ្ជា, ចំណេះ, បញ្ញា, ការគិតពិចារណា ។ ក្នុងវេទនិយម ពុទ្ធិស្ថិតនៅលើកំណើតយកទេវតា ដែលមាន

គម្ពីរវេទទាំង៤ ជាគ្រឿងប្រដាប់ខ្ពស់បំផុត គឺ ឫគ្វេទ, យជុរវេទ, សាមវេទ និងអថរវវេទ ។ ក្រៅពីនេះ មានគម្ពីរញាតផ្សេងទៀត ដែលជាឧបករណ៍ដ៏សំខាន់គឺៈ

ក- សំហិតា.– ជាប្រជុំនៃបទគាថា ដែលនិយាយពីការបួងសួង បូជា និងសរសើរអាទិទេព ។

ខ- ព្រាហ្មណៈ .– ជាគម្ពីរនិយាយពីពិធីបូជាយញ្ញ ដែលមានអាយុប្រមាណ ១.០០០ ឆ្នាំមុន គ.ស ។

គ- ឧបនិស្ស័ទ.– ជាក្បួនទស្សនវិជ្ជា ដែលនិយាយពីទ្រឹស្តីនៃលោកៈ និងទេវៈ ហើយដែលជាប់ទាក់ទងទៅនឹងព្រហ្ម មានអាយុប្រមាណ៥០០ ឆ្នាំមុន គ.ស ។

ឃ- អរញ្ញក (អារណ្យក).– ជាគម្ពីរធម៌ការបស់ពួកឫសី សំរាប់សូត្រដេញខ្មោចបិសាចនៅក្នុងព្រៃ ដែលមានអាយុជំណាលគ្នានឹងគម្ពីរឧបនិស្ស័ទដែរ ។

គម្ពីរក្បួនច្បាប់ ដែលជាអំណោយនៃអាទិទេពទាំងនេះ ជាកត្តា និងជាទ្រឹស្តីនៃពុទ្ធិវត្ថុ ។

២- ពុទ្ធិវិធី **Méthode de la connaissance.–**

គឺជាវិធីសំរាប់បង្កើតឲ្យមានពុទ្ធិ ដែលជាចំណេះចេះដឹង, ជាវិជ្ជា នោះឯង ។ វិធីធ្វើឲ្យមានពុទ្ធិនេះ ស្ថិតនៅលើ ៖

ក- សិក្សាគម្ពីរវេទ.– ដែលទុកជាមធ្យោបាយបណ្តុះចំណេះវិជ្ជា ។

ខ- សូត្រមន្តអាគមគាថា .– ជាពាក្យស័ក្តិសិទ្ធិរបស់អាទិទេព ។

គ- បូជាយញ្ញ .– តាមវិធីផ្សេងៗ មានការសម្លាប់ មនុស្ស-សត្វ ដើម្បីបូជាអាទិទេព ។

ឃ- ពិចារណា.– ដោយការខំរិះគិតចំពោះឯកភាពនៃអាត្មន និងព្រហ្ម ដែលជាប់ទាក់ទងគ្នា និងដាច់ចេញពីគ្នាជាអស្ចារ្យ ។

វិធីទាំងនេះ មនុស្សអាចធ្វើបានដោយការប្រព្រឹត្ត, ដោយបរិនាគតិដ៏ខំរឹង តាមចំណង់របស់ខ្លួន ។

### ៣- ពុទ្ធិវាទ Théorie de la connaissance .–

ទ្រឹស្តីនៃការសម្រេចពុទ្ធិ ដែលជាវិជ្ជាទេវវិទ្យានេះ គឺជាអំណោយនៃអាទិទេព យ៉ាងសុទ្ធសាធ បានសេចក្តីថា បានសម្រេចឬមិនបានសម្រេចស្រេចនៅលើអាទិទេព ។ អ្នកដែលមានបុណ្យសិទ្ធិអាចនឹងសិក្សារៀនសូត្រប្រព្រឹត្តបាន មានតែពួកព្រាហ្មណ៍ប៉ុណ្ណោះ ។

### បញ្ហាភាវៈក្នុងវេទនិយម

ភាវៈបានផលិតឲ្យជាតិទាំងអស់ មានលោកៈ, មនុស្ស, សត្វ, រុក្ខជាតិ, ទេវៈ, កាយ, ចិត្ត, អាត្មន, ភ្លើងខ្យល់, អាទិទេព ជាដើម ។ ភាវៈនេះមានមូលដ្ឋាន ឬ មូលធាតុ ៣ យ៉ាង សំខាន់គឺ :

១- ភាពនិម្មាណ

២- ភាពវិធី

៣- ភាពវាទ

#### ១- ភាពនិម្មាណ.–

លក្ខណៈរួមនៃធាតុ៤គឺ ទឹក ដី ភ្លើង ខ្យល់ ឲ្យបង្កើតបានជាធម្មជាតិ : មនុស្ស, សត្វ, ជាតិ, ទេវៈ ដែលជារូបកាយ ឬ ជារូប ហើយរូបនេះ កាលជួបនឹងព្រលឹង, វិញ្ញាណ ឬជាអាត្មននេះ ហើយក៏កកើតទៅជាលោក ៣ គឺ : ទេវលោក, មនុស្សលោក និងយមលោក បាតាល ។

ក- បញ្ហាទេវលោក.– កន្លែង ឬ លំនៅនៃទេវ ដែលមានទេវៈច្រើនរស់នៅ និងគ្រប់គ្រង ។ ទេវៈក្នុងលទ្ធិវេទមានគួរសំខាន់គឺ :

-ព្រះឥន្ទ.– ជាទេវៈបង្កើតផ្គរនិងរន្ទះតំណាងសង្គ្រាម ហើយមានឥទ្ធិពលលើសគេ ។ ប៉ុន្តែមកក្រោយគេលែងជឿវិញ ព្រោះចាញ់សង្គ្រាម ពួកអសុរញៀក ច្រើនដង ហើយមិនតែប៉ុណ្ណោះ ព្រះឥន្ទជាទេវៈ មិនរួមប្រព្រឹត្តតាមបុគ្គលនឹងសីលធម៌យ៉ាងខ្លាំង ដូចជាសេពសុរាស្រវឹងស្រាសោយ, មានស្រីស្នំច្រើន ហើយប្រព្រឹត្តខុសក្នុងកាមគុណ ដូចជា

លួចប្រពន្ធគេជាដើម ។

.– ក្នុងសិល្បៈ ព្រះឥន្ទមានពណ៌ខៀវ ជិះដំរីឰរាវ័ណ, កាន់ដងវជ្រ, កងចក្រ, ព្លូវ៉ៅ, កង្វៀរ ។

ព្រះឥន្ទមានមហេសី ៤ ឈ្មោះនាង សុធម្មា, សុជាតា, សុចិត្តានិងសុនន្ទា ។

**– ព្រះវរុណ.–** ជាទេវៈបង្កើតភ្លៀងនិងទឹក ជាបងបង្កើតរបស់ព្រះអាទិត្យ ចូលចិត្តពាក្យទៀងត្រង់ ចាំឃ្លាំមើលការប្រព្រឹត្តល្អអាក្រក់របស់មនុស្ស ។ ខ្មែរហៅជាព្រះពិរុណ ជាទេវៈមានរូបល្អណាស់ ។

.– ក្នុងសិល្បៈខ្មែរ ជារូបមនុស្សជិះនាគ ប៉ាំងកូស់ ។

**– ព្រះអាទិត្យ.–** ជាទេវៈបង្កើតកំដៅ, ពន្លឺ, បង្កើតនិងបំបាត់ជម្ងឺ និង ជាចៅក្រមកាត់ទោសមនុស្សលោក ។

.– ក្នុងសិល្បៈខ្មែរ ព្រះអាទិត្យជារូបទេវៈជិះរទេះសេះ គង់លើផ្កាឈូក នៅពីលើក្បាល (ក្បាល) មានសេះ៦ពណ៌ (ឧក្កណ្ឋសៀ) ។

**– ព្រះយមៈ.–** ជាទេវៈកាត់ក្តីទោសមនុស្ស (ពាំងរស់ពាំងស្លាប់) គឺជាទេវៈ តំណាងមរណៈ ឬ មច្ចុ (សេចក្តីស្លាប់) ហើយជាទេវៈនៅទៀងត្រង់ (ធម្ម) មិនចេះផ្លាស់ប្តូរឡើយ ទាំងឋានៈនិងរូប ។

·– នៅក្នុងសិល្បៈខ្មែរ ព្រះយមជាទេវៈជិះដំរី កាន់មាន, ព្លូវ៉ៅ, កាំបិតស្នៀត, ខ្សែ និងបាវ ។

**– ព្រះអគ្និ.–** ជាទេវៈតំណាងភ្លើង ជាសាក្សីនៃសេចក្តីល្អរបស់មនុស្ស ។

.– ក្នុងសិល្បៈខ្មែរ ព្រះមេឃៈ មានរូបជាមនុស្សក្បាលពីរ ដៃបួន ជិះចៀមឈ្មោល កាន់ ព្លូវ៉ៅ, ស្លាបព្រា, ភ្លើងនិងទឹក ។

**– ព្រះរុទ្រៈ.–** ជាទេវៈមានអំណាចនិងកំហឹងច្រើន ខ្លាំងពូកែ មានមហេសី ច្រើន តំណាងបម្យ៉ាំង ។

- **ព្រះកុវេរ** .- ជាទេវតាតំណាងសច្ចៈ (ទៀងត្រង់) មានគេ [illegible] លចិត្ត ច្រើន និងជាទេវតាតំណាងទ្រព្យសម្បត្តិផង ។

.- ក្នុងសិល្បៈខ្មែរ ព្រះកុវេរៈមានរូបជាបិសាច វិកលវិការ មានធ្មេញ ៨ ជើង ៣ ។

- **ព្រះចន្ទ** .- ជាទេវតាតំណាងរុក្ខជាតិ និងរូបល្អ កើតពីទឹកសោម ([illegible]) ។

.- ក្នុងសិល្បៈខ្មែរ ព្រះចន្ទជាមនុស្សមានរូបល្អធេក ជិះសេះកាជាខេយ្យ ឬ អង្គុយលើផ្កាឈូក ។

- **ព្រះពហស្បតី** .- ជាទេវតាតំណាងការចេះដឹង ព្រះគ្រូនៃមនុស្សលោក ។ កាលដើមជាទីប្រឹក្សានៃព្រះឥន្ទ ។

- **ព្រះវាយុ** (ព្រះពាយ) .- ជាទេវតាតំណាងធាតុត្រជាក់, ខ្យល់ ។ ក្នុងរឿងរាមកេរ្តិ៍ខ្មែរ ព្រះពាយជាបិតាហនុមាន ។

ទេវតាទាំងនេះ មនុស្សតែងគោរពបូជា និងគោរពខ្លាចថែមទៀត ហើយក្នុងសម័យក្រោយវេទនិយម ដូចជាសម័យព្រាហ្មណ៍និយម និងពុទ្ធនិយម គឺមនុស្សនៅគោរពទេវតានៅឡើយ ។ ក្រៅពីនេះ មានទេវតាជាច្រើនអង្គទៀត ដូចព្រះគង្គា, ព្រះសុក្រ, ព្រះពិស្រពណ៍ ជាដើម ។

ខ- បញ្ហាមនុស្សលោក.-

លំនៅនៃមនុស្សរស់នៅ ត្រង់ជុំវិញចង្កេះភ្នំព្រះសុមេរុ ។ មនុស្សនេះមានការបែងចែកជាវណ្ណៈ (គណៈ - ប្រភេទ) ៤ យ៉ាងគឺ :

**១- វណ្ណៈព្រាហ្មណ៍** .- ជាវណ្ណៈខ្ពស់ជាងគេ កើតពីព្រះឱស្ឋព្រហ្ម ជាអ្នកថែរក្សានិងនាំពាក្យនៃកាទេវតា ហើយជាគ្រូបង្រៀនសាសនាដល់មនុស្សលោក ។ ព្រាហ្មណ៍ស្លៀកពាក់ស មានសិទ្ធិរៀនសូត្រគម្ពីរវេទច្រើនយ៉ាងបាន ។

**២- វណ្ណៈក្សត្រ** .- ជាវណ្ណៈទី២ កើតពីព្រះហស្តព្រហ្ម មានមុខងារជា [illegible] ទឹកដី ថែរក្សាការពារទឹកដីនិងធ្វើចម្បាំងព្រមទាំងរៀនយុទ្ធវិធីនានាផង ។ វណ្ណៈក្សត្រស្លៀកពាក់ក្រហម ជានិមិត្តរូបនៃសេចក្ដីក្លាហាន ។

៣- វណ្ណៈវេស្ស (វៃស្យ) .– ជាវណ្ណៈដែលកើតពីភ្លៅព្រហ្ម មានមុខងារជាអ្នកកសិ ធ្វើស្រែចំការនិងជំនួញផ្សេងៗ ស្លៀកពាក់ពណ៌លឿង ។

៤- វណ្ណៈសុទ្ទៈ (ស៊ូទ្រៈ) .– ជាវណ្ណៈកើតពីជើងព្រហ្ម មានមុខងារជាខ្ញុំបំរើគេ (ខ្ញុំបំរើវណ្ណៈទាំងបីខាងលើ) ស្លៀកពាក់ពណ៌ខ្មៅ ។

វណ្ណៈទាំង៤ នេះ មានជីវភាព, មុខរបរ, ការយកស្វាមី ភរិយា ដាច់ស្រឡះពីគ្នា ។ បើព្រាហ្មណ៍, ក្សត្រ ឬវេស្ស បានលបសាហាយស្មន់ជាមួយវណ្ណៈសុទ្ទៈ ហើយបានកូនមក កូននោះហៅថា មនុស្សចណ្ឌាល ជាក្រុមមនុស្សមួយពួកទៀត ដែលប្រកបដោយក្តីថោកទាបក្រៃពេក ប្រៀបបាននឹងសត្វធាតុ ។

គ- បញ្ញាបាតាល (យមលោក) .–

បាតាលជាលំនៅមួយទៀត នៃពួកមនុស្សសត្វដែលមានកំហុសធ្ងន់ ៗ បាតាលចែកជា ៤ គឺ :

១- នរក .– លោកជាលំនៅនៃមនុស្ស ដែលមានទោសធ្ងន់ ត្រូវទទួលទោស ។ នរកមាន ១៨ កន្លែង មានអវិចី, លោហកុម្ភី ជាដើម ។

២- ប្រេត .– លោកជាលំនៅនៃមនុស្សសត្វ ដែលបានទទួលទោសធ្ងន់រួចហើយ ក៏មកយកកំណើតក្នុងប្រេតវិស័យ ដែលពោរពេញទៅដោយភាពក្រៀមក្រំអត់ឃ្លាន គ្មានអ្វីស៊ីបុក មានរូបធំប៉ុនភ្នំ តែមាត់ប៉ុនម្ជុល ជាដើម ។

៣- អសុរកាយ.– លោកជាលំនៅនៃមនុស្សសត្វ ដែលបានទទួលទោសធ្ងន់ ហើយក៏មកកើតជាបិសាច ស៊ីខ្ទុះឈាម សំណល់នៃសាកសពមនុស្សសត្វ ។

៤- តិរច្ឆាន .– បានដល់ពួកសត្វទាំងឡាយ ដែលគ្មានឧត្តមសញ្ញា ដូចខ្លា, គោ, ក្របី ជាដើម ។

ភាពៈដែលជាទុក្ខណៈនេះ មានការពាក់ព័ន្ធទៅនឹងត្រៃភព ។ ពួកនរក ប្រេត តិរច្ឆាន អសុរកាយ ឬ ទេវៈ ក៏មានលំនៅស្ថាន មានកំណើតនៅក្នុងមនុស្សលោកនេះ ក៏មានគ្រាន់តែបដិសន្ធិ

3

ដោយធាតុផ្សេងៗគ្នា ។

## ២_ ភាវវិធី .-

គឺជាវិធី, របៀបដែលពន្យល់ពីភាវៈ ពីកំណើតនៃភាវៈដែលកើតឡើង ។ ភាវៈកើតឡើងដោយព្រហ្មន ដែលជាឯកធាតុដ៏ធំបំផុត ជាសាកលវិញ្ញាណ ហើយដែលនាំឲ្យមានអាត្មន៍ជាព្រលឹងតូចៗ នៅចម្រុះព្រហ្មននឹងអាត្មន៍នេះ មានកម្មមួយទៀត ដែលសម្រាប់នាំមនុស្សសត្វឲ្យកើតក្នុងសង្សារវដ្ត ។

ព្រហ្មននេះ មានលក្ខណៈជាអាទិទេព ដែលមានឥទ្ធិពលទៅលើគ្រប់ធម្មជាតិ ហើយបង្កើតធម្មជាតិ : មនុស្ស, សត្វ, រុក្ខជាតិ ។

អាត្មន៍ជាភាវៈ ជាចិត្តវិញ្ញាណ ដែលជាតត្តនចិត្ត (ចិត្តខាងក្នុង) ស្ថិតនៅក្រោមឥទ្ធានុភាព នៃព្រហ្មន ។ អាត្មន៍នេះ ពុំចេះស្លាប់បាត់បង់ទៅណាឡើយ ។

ឯកម្ម ជាពូជ, ជាធាតុ ដែលនាំធម្មជាតិ មនុស្សសត្វ ឲ្យទៅកើត, ឲ្យយកបដិសន្ធិ ក្នុងភពណាមួយ : ទេវលោក, មនុស្សលោក ឬ បាតាលលោកជាដើម ។

ភាវៈទាំងបី កាលណាជួបប្រទះគ្នានឹងបង្កើតជាភាវៈមួយឡើង ។ នេះជាវិធីបង្កើតភាវៈ ។

## ៣- ភាវទាន .-

គឺជាទស្សនទ្រឹស្តីមួយដែលពន្យល់ពីការបង្កើតភាវៈ ដែលជាឯកភាវនិយម ឬ ជាមូលធាតុ ដែលយកព្រហ្មនជាឯកធាតុ ឬ ជាប្រភពនៃការបង្កើតលោក ។ ព្រហ្មននេះ ស្ថិតនៅទីនទេវៈ ព្រះបុរសៈ (Purusa) ជាអ្នកបង្កើតលោក ដោយការបំបែកព្រលឹងវិញ្ញាណមួយភាគមកក្រោម ដើម្បីបង្កើតធម្មជាតិ ដែលជាទឹក ដី ភ្លើង ខ្យល់ ជាដើម ។

## យោបល់រួមចំពោះភាវៈ

ភាវៈជាពហុធាតុ ដែលកើតឡើងដោយការផ្សំគ្នានៃ ទឹក ដី ភ្លើង ខ្យល់ ជាដើម ប៉ុន្តែ គន្លងគឺមានទេវៈដែលជាព្រហ្មន ជាអ្នកផ្តល់កំណើត, មានឥទ្ធានុភាពលើធម្មជាតិគ្រប់យ៉ាង ទោះសព្វថ្ងៃ លោកកើតដោយសារអាទិទេព-ព្រហ្មន ដែលជាធាតុដើមដ៏ខ្ពង់ខ្ពស់ ។

ការយល់ពីបញ្ហាភាវៈនេះ នាំឲ្យមានប្រយោជន៍ដល់ការកែចិត្តយល់ឆ្លងបញ្ហាសុខៈតទៅ ។

# បញ្ហាសុខៈក្នុងពុទ្ធនិយម

សុខៈជាបញ្ហាមួយធំទៀត ដែលទាក់ទងទៅនឹង សុខ ទុក្ខ វិជ្ជា ជាដើម ហើយ ដែលលទ្ធិសាសនាណាក៏ដោយ តែងតែស្វែងរកនិងដោះស្រាយជានិច្ច ។ បញ្ហាសុខៈនេះ ចែកជា ៣ ផ្នែកគឺ :

១- សុខប្រភេទ

២- សុខវិធី

៣- សុខវាទ

**១- សុខប្រភេទ .-** គឺជាផ្នែកនៃសេចក្ដីសុខ ។ គេចែកសុខប្រភេទនេះ ជា ២ យ៉ាងគឺ : សាមញ្ញសុខនិងបរមសុខ ។

ក- សាមញ្ញសុខៈ ឬសុខធម្មតា .- ជាសុខដែលមាននៅក្នុងលោកិយ ប្រកបដោយកាមៈគ្រាតគ្រាត ពុំបរិសុទ្ធ ដោយហេតុថា នៅទាក់ទងនឹងទុក្ខ ព្រោះការវិលវល់កើតស្លាប់ ដោយសារតណ្ហា ដែលមានកម្មជាបច្ច័យ ។ សុខបែបនេះ ពុំកាន់ត្រឹមត្រូវនៅឡើយ ទាល់តែមានបរមសុខថែមទៀត ។

ខ- បរមសុខ .- ជាសុខក្នុងបរលោក គ្មានទុក្ខណាមួយនៅពេលដែលតណ្ហា ដាច់ចេញពីព្រលឹង ទៅកើតជារូប ហើយពិសេសត្រឡប់ទៅរួមនឹងការដើមវិញ ។

ប៉ុន្តែសុខនិងទុក្ខនេះ តែងទាក់ទងទៅនឹងវិជ្ជា និង អវិជ្ជានេះថែមទៀត ។

យ៉ាងណាមិញ វិជ្ជាជាធាតុដែលផ្ដាសបាតកម្ម ហើយអាចនាំឲ្យតណ្ហា ទៅជួបនឹងព្រហ្មវិញ ដែលជាបុព្វហេតុនាំឲ្យមានបរមសុខ : ឯអវិជ្ជា ជាធាតុដែលប្រកបដោយកម្ម ដែលនាំឲ្យតណ្ហាត្រូវរប់ទៅជួបនឹងព្រហ្មនោះឡើយ តែនៅវិលវល់កើតស្លាប់ក្នុងសង្សារនេះឯង ។ ឧទាហរណ៍ដូចជា : កម្ម, សំសារ និងអវិជ្ជា ។

**២- សុខវិធី .-** គឺជាវិធីដែលនាំឲ្យបានសុខ ។ គេអាចចែកសុខវិធីនេះជា ២ ផ្នែកទៀតគឺ : វិធីបង្កើតសុខធម្មតា ឬសាមញ្ញសុខ និងវិធីបង្កើតបរមសុខ ។

ក–វិធីបង្កើតសុខធម្មតា.– ដើម្បីនឹងបានសុខធម្មតា ជាសុខក្នុងលោកិយ គេត្រូវ :

– ប្រកាន់វណ្ណៈ ដោយការបែកពួកមនុស្សតាមវណ្ណៈទាំង ៤

– គោរពព្រាហ្មណ៍

– គោរពវេទ

– ធ្វើពិធីបូជាយញ្ញ

– មានភក្តិ ( ជំនឿ La foi )

– បំពេញតបៈនិងរៀនវេទ ។

ខ–វិធីបង្កើតបរមសុខ.– ចំណែកខាងវិធីបង្កើតបរមសុខវិញ គេត្រូវ :

– ធ្វើមោក្សៈ (Délivrance) ដែលជាវិធីធ្វើឲ្យអាត្មានទៅជួបនឹងព្រហ្មន៍ ដែលជាទេវៈ ឬជាធាតុដើមវិញ ។ ការលែងស្លាប់កើតវិលវល់ក្នុងសង្សារ ដោយអស់កម្មវិបាកនេះ នាំឲ្យមានបរមសុខនេះឯង ។

– មិនតែប៉ុណ្ណោះ គេត្រូវបួសជាតាបសផង បំពេញតបៈ និងយោគៈ ។

តប .– ការដុតកំដៅផ្លូវកាយ ។

យោគ .– ការហាត់ពត់ អប់រំចិត្ត ។

វិធីបែបបទទាំងនេះ ក៏នៅពុំទាន់គ្រប់គ្រាន់នៅឡើយ ដូច្នេះត្រូវប្រើវិធីស្វែងរកសុខ ១ បែបទៀត គឺការបង្កបង្កើតវិជ្ជា ឬ បំបាត់អវិជ្ជា ។

យើងឃើញហើយ បញ្ហាសុខទុក្ខ តាមទស្សនវេទនិយមទាក់ទងទៅនឹងវិជ្ជានិងអវិជ្ជា ។ ដើម្បីរកបរមសុខ ឬ ឯកន្តសុខ ជាសុខមិនវិលត្រឡប់មករកទុក្ខវិញ គេត្រូវបំបាត់អវិជ្ជា ហើយបង្កើតវិជ្ជា ដែលជាចំណេះចេះដឹងដ៏ច្បាស់លាស់ឡើង ។ ការចេះដឹងដោយពិតជា ការជួបអាត្មននិងព្រហ្មន៍ទៅជាឯកភាពៈ គឺជាបរមសុខនេះឯង ឈ្មោះថាធានវិជ្ជា ។

ដូច្នេះ សុខវិធីដែលជាទស្សនៈនាំឲ្យមានសុខដែលជាបរមសុខនោះ គឺ វិធីដែលពន្យល់ថា

ការផ្ដាច់អាត្មន៍ចេញពីរូបកាយទៅរួបរួមជាមួយនឹងព្រហ្មន៍ ជាឯកភាវៈតែម្ដង ។

## ៣- សុខធាន .–

គ្មានអ្វីប្រសើរក្រៅពីផលនៃការវិវេកឡើយ ។ ក្នុងលទ្ធិវេទនិយម ការបានសុខពិតប្រាកដ គឺបានរំដោះខ្លួនពីសេចក្ដីទុក្ខ ប្រែរះជាសភាពវិវេកដ៏ស្ងប់ស្ងាត់ ហើយដើម្បីនឹងបានទទួលសុខណាមួយនេះ គេត្រូវតែ :

– ធ្វើតាមគម្ពីរវេទ
– គោរពតាមគម្ពីរវេទ
– អនុវត្តតាមគម្ពីរវេទ
– មានភក្ដីចំពោះគម្ពីរវេទ ។

កាលមនុស្សប្រព្រឹត្តដូច្នេះ ដោយត្រឹមត្រូវតាមលក្ខខណ្ឌទ្រឹស្ដីនៃវេទនិយម ហើយការវិវេកដែលជាទៅនៃខាងឯង នឹងផ្ដល់សេចក្ដីសុខ (សុខពិត ឬ ពេលសុខតាមគតិ) ឲ្យដល់អ្នកគោរពប្រតិបត្តិ ។

## យោបល់រួមចំពោះបញ្ហាវេទនិយម.–

រួចមកហើយនេះ យើងបានឃើញថា វេទនិយមស្ថិតនៅលើគន្លងដែលជាទ្រឹស្ដីសំខាន់ៗ ដូចតទៅ :

– ជាអស្តិកនិយម ដែលគ្មានសភាពពុទ្ធលក្ខណៈជាប្រត្យក្សភាពសោះឡើយ ។

– ជាទេវនិយម មានបែកជាពីរគឺ ឯកទេវនិយម (Monothéisme) ដែលគោរពតែទេពតែមួយ និងពហុទេវនិយម (Polynothéisme) ដែលគោរពទេពច្រើនអង្គ ដែលគេស្រះគាពគោរព ។

– ជាឯកភាវនិយម ដែលគេយល់ថាអាត្មន៍នៃសត្វលោកទាំងអស់ : មនុស្ស, សត្វ, នេះ មានកំណើតពីព្រហ្មន៍ ហើយកាលណាអាត្មន៍នោះត្រឡប់ទៅរួបព្រហ្មន៍វិញ ទើបបានសុខ ។

– ហើយមិនតែប៉ុណ្ណោះ លទ្ធិវេទនិយមបានឲ្យគោរពទៅលើចិត្ត, ព្រលឹងដែលជាអាត្មន៍

នេះផង ទៅលើការទទួលផង ព្រោះចិត្ត (អាត្មន) ដែលអាស្រ័យនឹងរូបកាយមិនបរិសុទ្ធ ក៏រងា-សារកមិន ហើយបាននៃការទទួលមួយគត់ ដែលបានឲ្យនូវគ្រឿងគ្រប់យ៉ាង (កំណើត, វិជ្ជា, បរិសុទ្ធ, សុខទុក្ខ ។ល។ ) ដល់មនុស្សសត្វ ។

• ដូច្នេះវេទនិយម មានលក្ខណៈជាលទ្ធិមួយ ដែលបង្ហាញដឹកនាំមនុស្សឲ្យបានដល់នូវសុខគ្រប់យ៉ាង ជាពិសេសនិព្វានសុខនេះឯង ។ បញ្ញាវុឌ្ឍិ, ការៈ, សុខៈ ក្នុងវេទនិយម គឺជាកំណោយនៃការទទួលទាំងអស់ ។

× × ×

## បញ្ហាព្រាហ្មណ៍និយម

ការបែបបទឋានុភាពនៃការទទួលខុស និងភាពពុញ្ញាខាងបំពោះសាស្ត្រខុស ដែលមិនសមហេតុផល ហើយជាពិសេស ពួកលទ្ធិបានក់យ់បាក់លទ្ធិនិយមឯទៀតក្នុងសម័យនោះយ៉ាងខ្លាំង ដើមវេទនិយម បានចាប់ផ្ដើមសាបសោយទៅបន្តិចបន្តួចៗ ហើយលទ្ធិព្រាហ្មណ៍ បានចាប់កំណត់កំណើតឡើងក្នុងសង្គមឥណ្ឌា ដើម្បីរស់រង់ទប់នឹងលទ្ធិដទៃទៀត ជាពិសេសគឺទប់ទល់នឹងពុទ្ធលទ្ធិនេះឯង ។

សម័យព្រាហ្មណ៍និយម ចាប់ផ្ដើមកំណើតឡើងប្រហែលពីពេល ៨៥០ ឆ្នាំមុនគ.ស ហើយមានលក្ខណៈសកម្មភាព ទៅរហូតដល់សតវត្សទី ១០ និងដើមសតវត្សទី ១៦ នៃគ.ស តែមទៀត ។ លទ្ធិព្រាហ្មណ៍និយមនេះ មានប្រភពដើមមកពីលទ្ធិវេទនិយម ហើយបានចាក់ឫសគល់យ៉ាងមាំទៅក្នុងប្រទេសឥណ្ឌា សម្បីពុទ្ធលទ្ធិបានចាប់បាក់យ៉ាងខ្លាំងដែរយ៉ាងណា ក៏ព្រាហ្មណ៍លទ្ធិនេះ នៅតែតតាំងនៅដោយធំធេងហើយដដែល ។

## មូលហេតុនៃការកើតព្រាហ្មណ៍លទ្ធិ.-

សម័យវេទនិយម, មិនមានអេបង់ឋានុភាព វណ្ណៈ ឬ សាសនាជាតំណែងអស់លើសនៅឡើយ ប៉ុន្តែពួកព្រាហ្មណ៍ ដែលមានសាស្ត្រាយល់ឃើញឆ្ងាយ ក៏បង្កើតលទ្ធិនេះឡើង ដោយៈ

- ក្រែងលទ្ធិវេទនិយម មិនអាចទប់ទល់តទល់នឹងពុទ្ធលទ្ធិបាន ។

- ពុទ្ធលទ្ធិ បានជះឥទ្ធិពលទៅលើលទ្ធិឯទៀតៗ ខ្លាំងណាស់ទៅហើយ ឯពួកព្រាហ្មណ៍ដែលពុំមានទស្សនៈស្របទៅនឹងពុទ្ធលទ្ធិ ព្រោះលទ្ធិខ្លួនជាវណ្ណៈទី១ ហើយភ្ជាប់គោរពតាមវេទនិយមទៅ ក៏បង្កការពារផលប្រយោជន៍វណ្ណៈខ្លួនផង, ចង់ធ្វើឲ្យទ្រឹស្តីផ្សេងៗ មានប្រសិទ្ធិភាពផងគំនិតប្រែប្រួលខ្លួនឡើង ។ ( ពុទ្ធលទ្ធិ បានវាយបំបាក់ពួកព្រាហ្មណ៍ និងក្សត្រិយ៍ទាំងពីរ ឥតឲ្យមានវណ្ណៈឡើយ អ្នកបួសត្រូវគោរពគ្នា តាមវស្សាចាស់.ទុំ) ។

សម័យព្រាហ្មណ៍និយម បានកើតឡើង ដើម្បីកែប្រែលើលទ្ធិចាស់ (វេទនិយម) របស់ខ្លួនផង និងដើម្បីទប់ទល់នឹងពុទ្ធលទ្ធិផង ។

## ចំណែកនៃវ័យរបស់ពួកព្រាហ្មណ៍.–

ដើម្បីនឹងធ្វើបដិវត្តន៍លទ្ធិព្រាហ្មណ៍ឲ្យមានប្រសិទ្ធិភាព ពួកព្រាហ្មណ៍បានបង្កើតការរៀបចំគ្រួសារដោយវិធី ៤ យ៉ាង ក្នុងជីវភាពរបស់គេគឺ :

ក– ព្រហ្មចារី.– ក្នុងកុមារវ័យ កូនព្រាហ្មណ៍ត្រូវរៀនសូត្រគម្ពីរវេទជាមួយគ្រូព្រាហ្មណ៍ ។

ខ– គ្រឹហស្ថ.– ក្នុងយុវវ័យ ត្រូវមានគ្រួសារបន្តពូជពង្ស ។

គ– វានប្រស្ថ.– គមក (បរិព្វាជ) ត្រូវទៅនៅព្រៃ រៀនធ្វើអ្នកបួស តែអាចយកគ្រួសារទៅនៅផងបាន ។

ឃ– សន្យាសៈ.– នៅវ័យចុង ពួកព្រាហ្មណ៍ ត្រូវប្រព្រឹត្តសីលស្ងប់ចិត្តឲ្យស្ងប់ស្ងាត់ លែងគិតដល់សព្វលោកិយទាំងអស់ ។

## ការវិវត្តន៍របស់ព្រាហ្មណ៍និយម.–

ដើម្បីឲ្យពលព្រាហ្មណ៍និយម នៅតែពុំអាចនឹងទប់ទល់បានជាមួយពុទ្ធលទ្ធិ ផងក្តី ទាំងក្នុងសម័យនោះ ពួកព្រាហ្មណ៍បានបង្កើតលទ្ធិ ៣ ទៀតគឺ :

១– លទ្ធិព្រហ្មចារ្យ

២– លទ្ធិអាគ្និន

៣– លទ្ធិឧបនិស័ទ

១– លទ្ធិព្រហ្មចារ្យ .– ជាលទ្ធិមួយដែលពួកព្រាហ្មណ៍បានបង្កើតឡើង សម្រាប់ឲ្យពួកព្រាហ្មណ៍សំគាល់សំគាន់ចិត្ត ចេញចាកកាមទៅបួសជាសមណព្រាហ្មណ៍ រស់នៅក្នុងស្ងប់ស្ងាត់ ។

២– លទ្ធិអាគ្និន .– ជាលទ្ធិដែលពួកព្រាហ្មណ៍អប់រំមនុស្សក្នុងគ្រួសារ ដែលជាព្រាហ្មណ៍ឲ្យសំគាល់សំគាល់ការក្នុងឲ្យស្អាតបរិសុទ្ធ ដោយគ្រឿងសេពហ្មង ដែលចោលចាកមិន ដើម្បីទៅជួបនឹងព្រហ្ម សម្រេចបរមសុខវិញ ។

៣– លទ្ធិឧបនិស័ទ .– ជាលទ្ធិដែលគេអប់រំកាយ របៀបពិសេស ដោយវិធីធ្វើយោគៈ ព្រោះកាយពោរពេញទៅដោយកិលេសតណ្ហា ហើយចិត្តដែលជាធម្មជាតិរវើរវាយប្រែប្រួល មិនចេះឈប់ឈរ កាលណាគេអប់រំធ្វើឲ្យលំបាកនិងមានការចុញទ្រាំចំពោះតណ្ហាខ្លះ ហើយចិត្តនឹងបរិសុទ្ធស្អាតឡើង ។

គោលលទ្ធិទាំង ៣ ស្ថិតនៅក្នុងគោលបំណងដូច គឺធ្វើលទ្ធិព្រាហ្មណ៍ឲ្យល្អស្អាត ចេញ ខស្ទួនគ្រឿងប្ដូរបស់លទ្ធិខ្លួនឲ្យកែតែល្អស្អាតឡើងជានិច្ច ។

**សេចក្ដីសង្កេត.–** ប៉ុន្តែពាក្យថាលទ្ធិព្រាហ្មណ៍ មានមនុស្សយកទៅបកប្រែផ្លែផ្សេងគ្នាដោយ គឺលទ្ធិខ្លះទៅកែឲ្យតម្លៃទៅលើអាទិទេព ឲ្យតម្លៃទៅលើព្រហ្មដដែល ដែលជាការគ្មានប្លែកអ្វីពីលទ្ធិវេទនិយមនោះសោះឡើយ ។ មិនតែប៉ុណ្ណោះ លទ្ធិព្រាហ្មណ៍និយម គឺបានលើកយកបញ្ហា ៣ យ៉ាងគឺ : គុរូ, កាមៈ និងសុខ ការពារនិងការស្រាវជ្រាវ ។

## បញ្ហាពិធីក្នុងព្រាហ្មណ៍និយម.

១– ពិធីបត្ត.– គឺ គ្រឿងប្រើប្រាស់សម្រាប់បង្កើតក្នុង ពិធីក្នុងលទ្ធិវេទនិយម ដែល គឺមាន :

ក- ឫគ្វេទ (ឫគវេទ)

ខ- សាមវេទ

គ- យជុរវេទ

ឃ- អថវ៌វេទ

ផ្សេងពីគម្ពីរវេទ, ដើម្បីបង្ហាញលទ្ធិមួយទៀត ពួកព្រាហ្មណ៍បានរៀបចំអត្ថបទវិជ្ជាដ៏សំខាន់ៗ សំរាប់ប្រើជាឧបករណ៍នៃការបង្កើតពុទ្ធិវេទគី :

ក- រាមាយណៈ .- រឿងអវតារនៃព្រះវិស្ណុ (ការចាប់កំណើតនៃព្រះនារាយណ៍ មកជាព្រះរាម) ជារឿងចម្បាំងរវាងសេចក្តីល្អ និងអាក្រក់ ជាអត្ថបទអក្សរសិល្ប៍និងសាសនា ។

ខ- មហាភារតយុទ្ធ .- រឿងចម្បាំងរវាងកៅរព និង បាណ្ឌព ដែលជាដ៏ធំមួយក្នុងរឿងរាជសម្បត្តិ ហើយជារឿងអវតារនៃព្រះវិស្ណុ (នារាយណ៍) ដែរ ។

គ- បុរាណ .- ជាគម្ពីរមួយ ដែលនិយាយពីប្រវត្តិសាស្ត្រលោក (ទឹកដី) ។

ឃ- ធម្មសាស្ត្រ .- ជាគម្ពីរច្បាប់ទូទៅ គ្រប់គ្រងប្រទេស, សង្គមមនុស្ស ។

ង- តន្ត្រៈ .- ជាគម្ពីរមេបទេស, ទ្រឹស្តីសម្រាប់ជាច្បាប់ទូទៅនានាផ្សេងៗ ។

គ្រឿងប្រដាប់សម្រាប់បង្កើតពុទ្ធិនៅក្នុងទស្សនៈព្រាហ្មណ៍ ក្រៅនេះមានទាក់ទងនឹងសាសនា និងអក្សរសិល្ប៍ ។

២- ពុទ្ធិវិធី .- របៀបវិធីផ្សេង ដែលនាំឲ្យមានពុទ្ធិ ពួកព្រាហ្មណ៍តែងផ្អែកទស្សនៈទៅលើប្រភព ៣ យ៉ាងដ៏សំខាន់ :

ក- ស្រុតិ (Sruti) .- ជាចំណេះ បានមកដោយអំណាចនៃការវិវរណៈ (Révélation) ។

ខ- ស្ម្រតិ (Smrti=Tradition sacrée).- ជាចំណេះដោយការទន្ទេញចាំមាត់ ដោយមានពួកព្រាហ្មណ៍ជាអ្នកបង្រៀនតាមតែអត្ថបទគម្ពីរ និង គោលគំនិតដើម ។

គ- អន្វិក្សិគិ (Anviksiki=Investigation rationnelle) .- ជាចំណេះ

ចេះដឹង ដែលមនុស្សស្រាវជ្រាវ ពិចារណាគេឃើញ ស្រប ឬ ផ្ទុយនឹងវត្ថុធាតុដើម អង្គជាតិ, ធម្មធាតុ, ដោយឲ្យតម្លៃទៅលើទ្រឹស្តីនេះ មិនឲ្យតម្លៃទៅលើទ្រឹស្តី ឬ ទស្សនៈនោះ ។

ដូចនេះ ពុទ្ធិវិធីស្ថិតនៅលើ :

- ធ្វើពិធីបូជាយញ្ញ :
- សូត្រស្មូត្រ ចំពោះអាទិទេព (សរសើរ)
- បន់ស្រន់, បួងសួងចំពោះអាទិទេព
- អង្វរគេចំពោះអាទិទេព ។

**៣- ពុទ្ធិវាទ.–** ចំណេះចេះដឹង ជាពិសេសចេះទស្សនៈទ្រឹស្តី ៦ យ៉ាង ដែលហៅថា គម្ពីរទសាស្ត្រ :

**ក- មិមំសា.–** ការពិចារណាខុសត្រូវចំពោះធម៌វិន័យ, មន្តអាគម, វេទមន្តលើពិធីបូជាយញ្ញចំពោះអាទិទេព ។ ទស្សនៈនេះ មានការគូសតែបញ្ជាក់ចំពោះទ្រឹស្តី សម្រាប់អ្នកកាន់លទ្ធិឲ្យច្បាស់លាស់ ។ អ្នកបង្កើតទស្សនៈឈ្មោះ ជៃមិនិ នៅទី១ និងទី២ មុន គ.ស ។

**ខ- វេទន្ត.–** ទស្សនៈដែលពន្យល់តាមឫសគល់ដើមនៃគម្ពីរវេទ ជាឯកភាពនិយម ឬ អទ្វៃតៈ ។ វេទន្ត មានន័យថា ទីបំផុត ឬ ចុងនៃវេទ អ្នកបង្កើតឈ្មោះ ពាទ្រាយណៈ មានចំណាស់ជំនាន់គ្នានឹងទស្សនៈ មិមំសា ឬ ក្រោយនេះបន្តិចប៉ុណ្ណោះ ។ ទស្សនៈនេះនិយមថា មានអាទិទេពធំ គឺព្រហ្ម ដូចក្នុងគម្ពីរឧបនិស្ស័ទ ហើយការសម្រេចបរមសុខទស្សនៈវេទន្ត បានពន្យល់ថា ត្រូវតែអាត្មានវិលទៅជួបព្រហ្មជាដាច់ខាត ។

**គ- សំខ្យា.–** ជាទស្សនៈដែលពន្យល់ពីការកើតកាត រាប់ចំនួនធាតុដែលផ្តើមបង្កើតលោកប្រកបដោយធាតុ៤:

- **គុណ.–** ធាតុល្អ អាក្រក់ នៃធម្មជាតិ
- **សត្វ.–** ធាតុរូបនៃធម្មជាតិ
- **តមៈ.–** ធាតុទំនាស់នឹងធម្មជាតិ

– សាំខ្យៈ .– ជាគុណដែលជាកម្លាំងសម្រាប់ការប្រឌិតការៈ ធ្វើឲ្យកើតជាទៅក្រោម ចាក់ចេញ ។ ទស្សនៈនេះ កើតប្រហែលក្នុងសតវត្សទី៦ ឬ ៧ នៃគ.ស អ្នកបង្កើតឈ្មោះ កបិលៈ ។

ឃ– យោគ .– ជាទស្សនៈសម្រាប់ពន្យល់ពីការបញ្ចប់ទុក្ខ ឲ្យក្រាសចាកសៅហ្មង ។ បង្កើតនៅសតវត្សទី២ នៃគ.ស ដោយលោក ក្បាសៈ មិនសូវល្បីរាយ លោក បតញ្ជលិ ។

ង– វៃសេសិក .– ជាទស្សនៈបញ្ជាក់អំពីភាពផ្សេងៗនៃធម្មជាតិ ។ លោក គណាទ បានពន្យល់អំពីបរមាណុធាតុ ដោយបញ្ជាក់ថា ធម្មជាតិសុទ្ធតែកើតមកពីការរៀបចំ ធាតុទាំងអស់ ដូចជាទៅក្នុងរូបធាតុ ជាផ្នែកទាំង ៦ យ៉ាង គឺដូចតទៅនេះ :

១– ទ្រព្យៈ (Substance) .– គឺជាគុណមូលដ្ឋានដំបូងបំផុត សម្រាប់បង្កើតជាតិ ។

២– គុណៈ (Propri…té).— គុណភាពនៃធម្មជាតិ ។

៣– កម្មៈ (Activité) .– សកម្ម, ចលនានៃធម្មជាតិ : មនុស្ស, សត្វ ដែលជាទ្រព្យ ៗ ឲ្យកើតបរិវត្តទ្រព្យ ទៀត ។

៤– សាមញ្ញ (Généralité) .– ភាពទូទៅ ដែលនាំឲ្យធម្មជាតិជួបផ្តុំដូចគ្នា, បង្កើតគុណភាព ។

៥– វិសេស (Corps composé) .– ជំនួបនៃទ្រព្យនិងទ្រព្យ ដោយសារកម្ម ។

៦– សមវាយៈ (Corps inhérent) .– ដំណើរជួបគ្នានៃទ្រព្យនិងទ្រព្យ ហើយក្លាយបានជារូបធាតុផ្សេងៗ ។

– ទស្សនៈវៃសេសិក គិតឲ្យឆ្ងាយទៅលើទេវនិយមបន្តិចដែរ ។

ច– ន្យាយៈ .– ជាទស្សនៈរបស់លោក គោតមៈ ដែលបានពន្យល់ ឲ្យគិតទៅលើការផ្សំផ្គុំនៃធាតុ ទឹក, ដី, ភ្លើង, ខ្យល់ បង្កើតជាលោកយើងនេះ ។ ទស្សនៈនេះ បានចំណាស់ស្របគ្នានឹងក្នុងសម័យដែរ (៥៤៣ មុន គ.ស) ហើយគឺជាទស្សនៈ

ដែលឲ្យតម្លៃទៅលើទេវនិយមដដែល ។

ក្នុងលទ្ធិព្រាហ្មណ៍ ទោះបីមានការបែកចេញលទ្ធិទេវនិយមក៏ដោយ ក៏ពុំទាន់ផុតពីផ្នែកទេ· នៅតែជាប់ទាក់ទងទៅលើជំនឿក្នុងគម្ពីរវេទដដែល ហើយតែងតែឲ្យតម្លៃ និងគោរពបូជាវណ្ណៈ ព្រាហ្មណ៍ ដែលជាវណ្ណៈទី ១ ក្នុងសង្គមវណ្ណៈ នៅសម័យនោះជានិច្ច ។

## បញ្ហាគោលៈក្នុងព្រាហ្មណ៍និយម

**១- គោលនិម្មាណ .–** តាមរនៅក្នុងលទ្ធិព្រាហ្មណ៍ បានបញ្ជាក់តាមគម្ពីរ ព្រហ្មបុរាណ៍ថា អ្វីៗទាំងអស់ជាធម្មជាតិ : មនុស្ស, សត្វ, រុក្ខជាតិ, ទឹក, ដី, ភ្លើង, ខ្យល់, អាកាស កើតពីព្រហ្មទាំងអស់ ។

**២- គោលវិធី .–** លោកៈ ពុំប្លែកពីទ្រឹស្តីក្នុងវេទនិយមឡើយ គោលគឺមាន លោក ៣ :

**ក- ទេវលោក .–** ជាស្ថានសួគ៌ៈនៅជាន់លើមនុស្សលោក ។ ក្នុង ទេវលោក ពួកព្រាហ្មណ៍បានគោរពនិងឲ្យតម្លៃទៅលើអាទិទេពធំៗ ៣ ដែល...គឺ :

១- ព្រះព្រហ្ម .– (ព្រហ្មនិយម) ព្រហ្មបានឡើងជាអាទិទេពធំនៅសម័យ ព្រាហ្មណ៍និយម ដូចព្រះឥន្ទក្នុងសម័យវេទនិយមដែរ ។ ព្រះព្រហ្មមាននាទីជាអ្នកបង្កើតលោក ។

– នៅក្នុងសិល្បៈខ្មែរ ព្រះព្រហ្មមានព្រះភក្ត្រ ៤ ព្រះហស្ត ៤ ជិះហង្សជាយាន, មាន ជាសង្ខូចប៉ុងទឹក ១ ជាសម្បុល ១ ស្លាបព្រា ១ និងខ្សែផ្កា ( Rosaire ) និងផ្ទុំគម្ពីរជាគេគនទណ្ឌា មានមហេសីឈ្មោះនាងសរស្វតី ។

គេថាពេលវេលានៅស្ថានព្រហ្មមានវែងណាស់ មួយថ្ងៃនៅស្ថានព្រហ្មស្មើនឹងមួយកល្បនៅស្ថាន មនុស្ស ពេលព្រះព្រហ្មផ្ទំគឺជាពេលភ្លើងឆេះកល្ប ពេលព្រះព្រហ្មភ្ញាក់ ជាពេលដែលផែនដី កកើតឡើងវិញ ។ កុំច្រឡំរូបព្រះភក្ត្រ ៤ នៅប្រាសាទបាយ័ន មិនមែនជាព្រះព្រហ្មទេ គឺជារូប តំណាងតួ អវលោកិតេស្វរៈ ។

២- ព្រះវិស្ណុ (ព្រះនារាយណ៍) .– ពេលដែលផែនដីកើតហើយ ព្រះវិស្ណុមាន

នាទីជាអ្នកថែរក្សាការពារ-រៀបចំលោក ។

–ព្រះវិស្ណុក្នុងសិល្បៈខ្មែរ ជារូបមនុស្សមានក្បាលមួយ ដៃ ៤ កាន់ចាស ១ ស័ង្ខ ១ ពេជ្រ ១ ដំបងមូល ១ ពាក់មកុដមូល (Mitre cylindrique) ជិះគ្រុឌជាយានជំនិះ ជួនកាលជារូបឈរ ឬ ផ្ទំ នៅកណ្ដាលសមុទ្រ លើនាគមួយឈ្មោះ អានន្ត ។ នៅត្រង់ផ្ចិតមានផ្កាឈូកដុះចេញមក ហើយ ព្រះព្រហ្មគង់លើផ្កាឈូក ។ ព្រះវិស្ណុមានប្រពន្ធពីរឈ្មោះ ស្រី និង លក្ស្មី មានបុត្រម្នាក់ឈ្មោះ កាមៈ ។ ស្រី ជាតំណាងភាពល្អស្រស់ (សោភណភាព), លក្ស្មី ជាតំណាងទ្រព្យសម្បត្តិ ។

ព្រះវិស្ណុមានឈ្មោះច្រើនគឺ នារាយណ៍, កេសវ, ហរិ, អនន្ត ហើយតែងតែចាប់កំណើតជា មនុស្សសត្វផ្សេងៗ ដើម្បីជួយស្រោចស្រង់លោក ។ អវតាររបស់ព្រះវិស្ណុមាន ១០ យ៉ាងគឺ:

១– ត្រីមត្ស្យ (Matsya).– ចាប់កំណើតជាត្រី ដើម្បីជួយមនុស្សឲ្យរួចពីទឹក ជំនន់ ដែលជាគ្រោះយក្សបណ្ដាលឡើង ។

២– អណ្ដើកឈ្មោះ កូម៌ា (Korma).– ធ្វើជាតំណល់ទល់ភ្នំមន្ទារៈ នៅ ពេលដែលអសុរនិងទេវតាចាប់កន្ទុយនាគម្ខាងម្នាក់ទាញបង្វិលភ្នំ ដើម្បីកូរសមុទ្រទឹកដោះ ដើម្បី យកទឹកអម្រឹត និងវត្ថុសក្តិសិទ្ធិ ១៣ មុខទៀតគឺ: អ្នកបង្កើតឱសថ ធន្វន្តរី, ទេពធីតាលក្ស្មី, ទឹក ស្រាមសុរា, ព្រះចន្ទ, ទេពអប្សរឈ្មោះរម្ភា, សេះទេវៈឈ្មោះ ឧច្ចៃស្រវស, ពេជ្រកៅស្តុភៈ, ផ្កាជាតិសួគ៌បារិជាត, គោញីសុរភី, ដំរីឰរាវតៈ, ស័ង្ខ, ធ្នូ, ថ្នាំពុល ហាលាហលៈ ។

ក្នុងបនាខ្មែរ មាននៅទីងក្រានក្តារដើយចូលទៅខាងក្នុង និងនៅលើជញ្ជាំងប្រាសាទអង្គរវត្ត (ចម្លាក់លិប = Bas relief) ។

៣– ជ្រូកព្រៃឈ្មោះ វរាហៈ ល្បីឈ្មោះដោយដេញសម្លាប់ ហិរណ្យយក្ស ដែល ចាប់នាង ភូមិទេវី យកទៅទុកនៅបាតសមុទ្រ ហើយមានប្រាថ្នារំលាយលោកឲ្យទៅជាទឹកសមុទ្រ ។

៤– មនុស្សសិង្ហឈ្មោះ នរសិង្ហ.– មានក្បាលជាសិង្ហៈ ខ្លួនជាមនុស្ស បានសម្លាប់យក្សឈ្មោះ ហិរណ្យកសិបុ ជាប្អូនយក្សឈ្មោះ ហិរណ្យាក្សៈ ។ យក្ស ហិរណ្យកសិបុ ដែលបានពរពីព្រះព្រហ្មថា កុំឲ្យស្លាប់ដោយមនុស្ស ឬ ទេវៈ ដែលបង់សម្លាប់ពេល

យប់ឬថ្ងៃ ហើយក៏ដើរកត់ត្រាទោសនិងមនុស្សតាមពិត - នរសិង្ហបានសម្លាប់យក្សនេះ នៅពេលព្រលប់ ។

៥- មនុស្សតឿឈ្មោះ **វាមនៈ** .- ជាព្រាហ្មណ៍តឿជួយស្រោចស្រង់មនុស្សឲ្យរួចពីកណ្ដាប់ដៃយក្សឈ្មោះ **ពលិ** ។ វាមនៈ បោកបញ្ឆោតយក្សសុំឈាន ៣ជំហាន ក៏ឈានផុតផែនដី ហើយយកដីឲ្យមនុស្សនៅ ។

៦- មនុស្សកាន់ពូថៅឈ្មោះ **បរសុរាម** .- ជាមនុស្សកាន់ពូថៅអំណោយសិវៈ ជួយស្រោចស្រង់មនុស្សឲ្យផុតពីកំណាចស្ដេចកាចឈ្មោះ **កាតិវិរ្យា** ដែលសង្កត់សង្កិនមនុស្សឯទៀតៗ ។

៧- **ព្រះរាម** .- ជាស្ដេចកាទិទេព ដែលមានមុខងារបង្ក្រាបពួកយក្សមានយក្សឈ្មោះ **រាពណ៍** ក្នុងរឿងរាមាយណៈ ដែលបៀតបៀនសាសនាព្រាហ្មណ៍ ។

៨- **ក្រិស្ណ** .- ជាមនុស្សខ្មៅស្រអំ គោវាល ជាអ្នកប្រយុទ្ធនឹងពួកអ្នកផ្ដាលគោឲ្យរួចពីផ្គរ, ភ្លៀង, ខ្លះ ហើយបានសម្លាប់ស្ដេចជាឪពុកមាឈ្មោះ **កម្សៈ** ដែលបង់សម្លាប់ប្អូនៗដោយហេតុថាគិតក្បត់ ។ ក្រិស្ណៈ ជាតួឯកក្នុងរឿងមហាភារតយុទ្ធ ផ្ទុយពីនេះ គេស្រឡាញ់ច្រើន ។

៩- **ពុទ្ធ** .- ជាព្រះពុទ្ធសមណៈគោតម (តាមលទ្ធិព្រាហ្មណ៍) ។

១០- **កល្កិន** .- នឹងកើតមានខ្លួនជាមនុស្ស, ក្បាលជាសេះ (នឹងកើតនៅអនាគតកាល) ដើម្បីកាត់ទោសមនុស្សប្រព្រឹត្តការកក់មិនរៀបចំយុគថ្មីឲ្យរុងរឿង ។

អវតារ គឺការប្តូររាងនៃព្រះវិស្ណុនេះមាន ១០ យ៉ាង ហៅថា ទសាវតារ ។ ៩លើកមានរួចហើយ១លើកទៀត នឹងមាននៅអនាគតកាល ។

៣- **សិវៈ** .-

សិវៈ ឬ ព្រះឥសូរ ជាអ្នកបង្កើតលោកផង បំផ្លាញលោកផង ជាកាទិទេពនៃជនជាតិឥណ្ឌាភាគខាងជើង តំណាងពួកអារ្យ៉ាន់ដែលកាចឃោរឃៅ ។

- រូបក្នុងសិល្បៈខ្មែរ គឺជារូបលិង្គស្ថិតលើផ្ទៃយោនី (ក្បិត) នៃនាងឧមា ពីដើមទេវរូប សតវត្សទី៧ ដល់ទី៨, ដល់ក្រោយមកជារូបមនុស្សក្បាល៥ ដៃ១០ ជាឥសីឬក្សត្រ ។

- ជិះគោនន្ទិ ជាជំនិះ កាន់ត្រីសូល, ខ្សែធ្នូ, ស្គរ, ដប, ខ្សែមួយចង្កៀង, ធ្នូ, ខ្យង ។

- មានឈ្មោះច្រើនគឺ: សិវៈ, ឥសូរ, មហាទេព, ហរ, មហេស្វរៈ, ឧគ្រ, សង្ករៈ, រុទ្រ, ភៃរវៈ ។

- មានមហេសី៩ គឺនាង ទុគ៌ា, ឧមា, គោរី, កាលី, ទេវី, កុមារី, ចណ្ឌី, បរ៌តី, មហាទេវី ។

- មានកូន២ នាក់គឺ: ស្កន្ទៈ អាទិទេពតំណាងសង្គ្រាម និង គណេសៈ អាទិ-ទេពតំណាងវិជ្ជា ។ គណេសៈខ្លួនជាមនុស្ស ក្បាលជាដំរីមានសក្តិពេញខ្លួន មានភ្លុកតែមួយ ។

**ចំណាំ**.- នៅក្នុងសិល្បៈខ្មែរ ទេពម្នាក់ត្រូវសាងតំណាង រូបតែ១ ជាតំណាងវិស្ណុ និងសិវៈផង ហៅថា ហរិហរៈ គឺ ខាងចំហៀងក្បាលស្តាំសំគាល់សិវៈ (ឥសូរហរ) ចំហៀងឆ្វេងសំគាល់វិស្ណុ (នារាយណ៍ហរៈ) ។

**ខ-មនុស្សលោក**.- ក្នុងលទ្ធិព្រាហ្មណ៍ ចាត់ចែកវណ្ណៈមនុស្សជា ៤ ពួក ដូចក្នុងវេទនិយមដែរ គឺ ព្រាហ្មណ៍, ក្សត្រ, វេស្សៈ និង សូទ្រៈ ។ ផ្សេងពីនេះ មានពួកចណ្ឌាល (កូនមនុស្សច្រលំយកគ្នាផ្សេងវណ្ណៈព្រាហ្មណ៍ និង សូទ្រៈឬ ក្សត្រនិងសូទ្រៈ) ។

**គ-បាតាល**.- (ដូចគ្នាក្នុងវេទនិយមដែរគឺ កន្លែងខាងក្រោមនិងក្នុងដីនៅ ក្រោមដីឬក្រោមភ្នំព្រះសុមេរុ ហើយផ្សេងពីនេះ មានប្រេត, អសុរកាយ, តិរច្ឆាន ថែមទៀត ។

ការពិត ក្នុងព្រាហ្មណ៍និយម ពុំនៅតែឲ្យតម្លៃទៅលើការទេវតា ហើយជាពិសេសគឺ ព្រហ្មហ្នឹងឯង ដោយមានសេចក្ដីជឿព្រាហ្មណ៍នេះ បានពន្យល់ថា សកលលោកទាំងមូលយ៉ាង បានមាននៅ ក្នុងលោកនេះហើយៗ កាលដំបូង កកើតជាស៊ុតមួយ មានបដិសន្ធិជាព្រហ្ម ។ កាលស៊ុតនោះ ១ម៉ឺនកល្បព្រហ្មក៏បំបែកស៊ុតជា២: មួយចំណែកលើជាមេឃ, អាកាស, ចំណែកក្រោមជាដីៗហើយ ព្រហ្មបានសាងសត្វមនុស្សគ្រប់ទៅក្នុងលោក ទើបមានការគ្រប់យ៉ាងនេះឡើង ដែលជាដើមកំណើតលោក

ទាំង៣ មានឋានសួគ៌, ឋានមនុស្ស និងឋានបាតាលនេះឯង ។

### ៣_ សាសនា.-

ទស្សនៈក្នុងព្រាហ្មណ៍និយម ក៏នៅតែពុំទាន់ផ្តាច់ខ្លួនចេញពីវេទនិយម ក្នុងផ្នែកការគោរពនេះដែរ ពោលគឺព្រាហ្មណ៍និយមឲ្យតម្លៃទៅលើពហុភាពនិយមទាំង ៣ ដែលមនុស្សត្រូវធ្វើការសសើរស្ញប់ ល្អកាត្រក់ នៅលើអាទិទេពទាំង ៣ គឺ ព្រះព្រហ្ម ព្រះវិស្ណុ និងសិវៈនេះឯង ។ ព្រោះអាទិទេពទាំង៣ ជាអ្នកបង្កើត - ព្យាបាល - រៀបចំ និងបំផ្លាញលោកសន្និវាស ។ ដោយហេតុនេះ បានជាមានទស្សនៈមួយ ក្នុងសម័យព្រាហ្មណ៍នេះ ហៅថាទស្សនៈត្រីមូរ្តិ គឺការនិយមលើកដម្កើងអាទិទេពទាំង ៣ អង្គ ដែលជាម្ចាស់នៃលោកទាំង៣ ។

## បញ្ហាសុខក្នុងព្រាហ្មណ៍និយម

បញ្ហាសុខៈនៅក្នុងព្រាហ្មណ៍និយម ក៏នៅតែមាន២ ផ្នែកដដែល គឺសុខធម្មតា និងបរម-សុខនេះឯង ប៉ុន្តែមុននឹងស្គាល់សុខ ត្រូវស្គាល់ទុក្ខសិន ។

**១- សុខប្រភេទ .-** សុខប្រភេទមាន ទុក្ខ - សុខ និងបរមសុខ ។

**ក- ទុក្ខ .-** ក្នុងទស្សនៈព្រាហ្មណ៍ ទុក្ខកើតឡើងដោយបុព្វហេតុ៤ យ៉ាង:

- ដោយសំសារ
- ដោយកម៌ន
- ដោយអាត្មន ពុំស្អាត
- ដោយអវិជ្ជា (ល្ងិតល្ងង់)
- តណ្ហា (ចំណង់)

នៅក្នុងទស្សនៈទាំង៦ មានមីមាំសា, វេទន្ត ជាដើម សុទ្ធតែយល់ថា ទុក្ខកើតដោយហេតុទាំងនេះដែរ ។

ខ- សុខ.- (សាមញ្ញសុខៈ សុខធម្មតា) សុខផ្នែកនេះ មានការពាក់ទង់ទៅនឹងព្រះព្រហ្មជាអ្នកបង្កើតលោក ពោលគឺ ការស្គាល់អាត្មន ដែលមានទំនាក់ទំនងនឹងព្រហ្ម

នេះឯង ៗ ប៉ុន្តែសុខនៃបរនេះ ពុំទាន់គ្រប់គ្រាន់ពេញលេញនៅឡើយ ទាល់តែបរមសុខប៉ុណ្ណោះ ទើបជាសុខពេញលេញ ។

គ- បរមសុខ .- សុខដែលពួកព្រាហ្មណ៍ខំប្រឹងប្រែងដោះស្រាយ និង ស្វែងរក គឺបរមសុខ ជាបរិបុណ្ណសុខ ហើយជាសុខរបស់អាទិទេពថែមទៀត ។

២- សុខវិធី .- វិធីសម្រេចបរមសុខមាន ២ យ៉ាង :

ក- មោក្ស .- ដើម្បីសម្រេច សុខ គេត្រូវបំបាត់អវិជ្ជា, សំសារ, កម្ម, តណ្ហា នេះឯង ៗ មិនតែប៉ុណ្ណោះ គេត្រូវ :

- សិក្សាគម្ពីរវេទ ឲ្យចាំមាត់
- ធ្វើពលីបូជាយញ្ញ
- អង្វរ - សរសើរអាទិទេព
- រៀនមន្តអាគមគាថា
- ប្រព្រឹត្តតាមកិច្ចរបស់ព្រាហ្មណ៍ -
- បួសជាតាបសឥសី ចំរើនឈាន
- បង្កើតវិជ្ជា ដែលនាំឲ្យយល់ច្បាស់ថា ខ្លួនជាព្រហ្ម ។

ខ- ភក្តិ .- ប៉ុន្តែធ្វើតែប៉ុណ្ណោះ ក៏នៅពុំទាន់គ្រប់គ្រាន់ទៀត ដូច្នេះគេត្រូវមានជំនឿយ៉ាងស៊ប់ទៅលើអាទិទេពតែម្យ៉ាង (ជំនឿដោយគ្មានពិចារណា) ដែលមានលក្ខណៈ សំខាន់ៗ គឺ:

- ជំនឿស៊ប់ស្ងួន
- ស្នេហាផ្ដេកផ្ដួល
- គោរពកោតខ្លាច
- ទឹកដល់អាទិទេព ។

មោក្សៈ និង ភក្តិនេះ ទុកជាកត្តាយ៉ាងសំខាន់ ដែលនាំឲ្យសម្រេចបរមសុខ ជាសុខ

គ្មានប្រែប្រួល ។

៣- សុខវាទ .- ប៉ុន្តែគំនិតសុខវាទ ទាំងអស់ខាងលើនេះ ក៏ស្រេចនៅលើព្រាហ្មណ៍ ដែលបានសេចក្តីថាបាន សុខ ឬ មិនបានសុខ ស្ថិតនៅលើព្រាហ្មណ៍ ដែលជាវណ្ណៈសំខាន់ មានសមត្ថភាពជួយអន្តរាគមន៍ស្នង សុំសុខពីអាទិទេពបាន ។

## យោបល់រួមចំពោះលទ្ធិព្រាហ្មណ៍និយម

ព្រាហ្មណ៍និយម ដែលបានកែប្រែបង្វែរចេញពីវេទនិយម ក៏នៅតែមានលក្ខណៈស្របស្រួលទៅនឹងវេទនិយមស្ទើរតែទាំងអស់ គឺជា ទេវនិយម បែបឯកទេវៈ និង ពហុទេវៈ ហើយនឹងព្រាហ្មណ៍និយម ដែលព្រាហ្មណ៍មានតួនាទីជាអ្នកនាំពាក្យនៃមនុស្សទៅអង្វរលួងលោម អាទិទេព ។ នៅក្នុងព្រាហ្មណ៍និយម (ក្រោយវេទនិយម) អាទិទេពស្ទើរតែមានសមត្ថភាព, មានលក្ខណៈគ្រប់ល្អ គ្រប់យ៉ាង (ដូចកវិនិយម ក្នុងអក្សរសិល្ប៍ខ្មែរដែរ) ។ ទស្សនៈនេះ មានជាប់ទាក់ទងទៅនឹង ហិណ្ឌូនិយម ថែមទៀត ។

× × ×

## ហិណ្ឌូនិយម

### អត្ថន័យសង្ខេប -

ហិណ្ឌូនិយម ពុំមែនជាលទ្ធិថ្មីមួយ ដោយឡែករបស់ពួកហិណ្ឌូឡើយ ហើយទស្សនៈទ្រឹស្តី ក៏ពុំបានផ្តាច់ខ្លួនចេញស្រឡះពីលទ្ធិមុនដែរ បានសេចក្តីថាហិណ្ឌូនិយម គឺជាលទ្ធិដែលល្បាយលទ្ធិវេទនិយម និង ព្រាហ្មណ៍និយមបញ្ចូលគ្នាតែឯង ។

ពាក្យហិណ្ឌូនិយម សំគាល់ន័យថា លទ្ធិដែលគេយកតាមវប្បធម៌ អរិយធម៌ហិណ្ឌូ ប៉ុន្តែមិនមែនជារបស់ហិណ្ឌូ (ឥណ្ឌា) ដោយសុទ្ធសាធឡើយ ។ ពួកជនជាតិឥណ្ឌា មានប្រវត្តិសាស្ត្ររបស់ខ្លួន មានលទ្ធិច្រើន ហើយមានជនជាតិ និងភាសាច្រើន ម្ល៉ោះហើយ លទ្ធិ, សាសនា,

ទស្សនៈផង តែងមានលក្ខណៈប្លែកៗ គ្នាបន្តិចៗ តាមការបដិវត្តន៍នៃកាលវេលា, ករុម ។

ទៅក្នុងហិណ្ឌូនិយម មានការដោះស្រាយ បញ្ហាព្រហ្ម, កាម៌ និងសុខស្រួលស្មើនៃអាត្ម ស្រដៀងទៅនឹង វេទនិយមនិងព្រាហ្មណ៍និយម ។ យ៉ាងណាមិញ: ការដោះស្រាយបញ្ហា ព្រហ្ម កាម៌ មានលក្ខណៈស្របតាមគម្ពីរវេទទាំង ៤ គឺ ឫគ្វេទ, យជុរវេទ, សាមវេទនិងអថវវេទ ជាដើម ។ ការចែកលោកជាំង៣: ទេវលោក, មនុស្សលោក និងបាតាលក៏ដូចគ្នា ។ល។

យោបល់.— ដូច្នេះ ហិណ្ឌូនិយម មិនមែនជាលទ្ធិថ្មីមួយដ៏ទំនើបទៀត ដោយក៏មិនមានលក្ខណៈផ្សេងពីលទ្ធិមុនដែរ ប៉ុន្តែតាមតម្រូវការនៃសង្គមមនុស្ស ការបង្កើតលទ្ធិហិណ្ឌូវេទ គឺ ដើម្បីនឹងតទល់ចំពោះការលូតលាស់នៃលទ្ធិមួយ ដែលទាំងក្នុងសម័យកាលមួយ ដូចជាពុទ្ធលទ្ធិនេះ ជាដើមផង ដើម្បីសម្រួលទឹកចិត្តមនុស្ស ដែលបោះបង់ចោលទួលឡូវៗ ដែលជឿនោះផង ។ លទ្ធិហិណ្ឌូត្រូវទទួលការបដិវត្តន៍ឡើង ដើម្បីសម្រួលទស្សនៈទៅតាមសង្គម នៃពួកហិណ្ឌូថ្មីនេះឯង ។

× × ×

## ពុទ្ធនិយម

អាទិបទ .— ពុទ្ធលទ្ធិ ពុំមែនជាសាសនាដោយសុទ្ធសាធឡើយ ហើយក៏ពុំមែនលទ្ធិដែលនិយមតាមទេព ដោយមានព្រះពុទ្ធជាតួឯកអាទិទេពធំៗនោះដែរ ប៉ុន្តែពុទ្ធលទ្ធិ ជាចំណេះវិជ្ជា ពោរពេញទៅដោយវិចារណញ្ញាណ ជាទស្សនវិជ្ជា និងជាវិទ្យាសាស្ត្រនេះឯង ។ ព្រះពុទ្ធជាមនុស្សមានរូបរស់នៅក្នុងសង្គមមនុស្ស ធ្លាប់ធ្វើកិច្ចការសំខាន់ៗ ដែលគេពិបាកធ្វើ ហើយធ្លាប់បញ្ចេញទ្រឹស្តីខ្ពង់ខ្ពស់ ផុតមនុស្ស, ទេវតា, សត្វធាតុ ដោយផ្ទាល់ថែមទៀតផង ។ ដើម្បីស្គាល់ពុទ្ធលទ្ធិនេះ យើងនឹងធ្វើការសិក្សានូវពុទ្ធប្រវត្តិជាមុនដូចតទៅ ៖

### ក- ពុទ្ធប្រវត្តិសង្ខេប .—

ព្រះពុទ្ធ ជាបុត្រក្សត្រសាក្យត្រកូលនៅដែនសក្កក្រុងកបិលព័ស្តុ (ស្ថិតនៅក្នុងប្រទេសនេប៉ាល

សព្វថ្ងៃ) ទ្រង់យាងពីស្ថានតុសិតឈ្មោះ សន្តុសិតទេវបុត្ត មកយកបដិសន្ធិក្នុងស្ថានមនុស្ស ។ ព្រះបិតាទ្រង់នាម សិរីសុទ្ធោទនៈ ព្រះមាតានាម សិរិមហាមាយាទេវី ។ ទ្រង់ប្រសូត្រនៅថ្ងៃសុក្រពេញបូណ៌មីខែពិសាខ ឆ្នាំច មុន គ.ស ៦២៣ ឆ្នាំ នៅក្នុងសួនឧទ្យាន ១ ឈ្មោះ លុម្ពិនី ចន្លោះក្រុងកបិល-ពស្តុ និងទេវទហៈ ។ ព្រះមាតាទ្រង់ប្រថាប់ឈរ ដោយគ្មានឈឺចាប់ទេ ។ ពេលប្រសូតភ្លាម ទ្រង់យាងបាន៧ជំហាន ដោយមានផ្កាឈូកទ្រព្រះបាទ ហើយបន្លឺវាចាថា «អគ្គោហមស្មិ លោកស្ស សេដ្ឋោ... នត្ថិទានិ បុនព្ភវោ= ខ្ញុំជាកំពូលនៃលោក, ខ្ញុំប្រសើរជាងលោក, ជាតិនេះជាជាតិទីបំផុតនៃខ្ញុំ» ។

កាលប្រសូតបាន ៥ ថ្ងៃ ព្រះបិតាបានធ្វើពិធីថ្វាយព្រះនាមថា សិទ្ធត្ថ (អ្នកសម្រេចប្រយោជន៍គ្រប់យ៉ាង) ហើយក្រោយមក ២ ថ្ងៃទៀត (៧ ថ្ងៃ) ព្រះមាតាទ្រង់សោយទិវង្គតទៅកើតនៅស្ថានតុសិត ដោយអស់ព្រះជន្ម ។

កាលព្រះជន្មបាន ៥ ថ្ងៃ ជាថ្ងៃថ្វាយព្រះនាម និងទាយលក្ខណៈព្រះអង្គ មានព្រាហ្មណ៍ម្នាក់ឈ្មោះ កោណ្ឌញ្ញៈ ទាយថា ព្រះសិទ្ធត្ថ នឹងចេញបួស ហើយបានត្រាស់ជាព្រះពុទ្ធ ។

លុះព្រះជន្មបាន ១៦ ឆ្នាំ ត្រូវទទួលរាជាភិសេកឡើងសោយរាជ្យស្នងបិតា ដោយមានព្រះនាង យសោធរាពិម្ពា ជាមហេសី ហើយដល់ព្រះជន្ម ២៩ វស្សា (ក្រោយសោយរាជ្យ ១៣ឆ្នាំ) ទើបមានបុត្រ ១ ឈ្មោះ រាហុលកុមារ ។

ក្នុងថ្ងៃដែលរាហុលប្រសូត ព្រះសិទ្ធត្ថទ្រង់យាងទៅក្រសាលក្នុងឧទ្យាន ហើយទ្រង់ទតឃើញទេវទូតទាំង ៤ គឺ: មនុស្សចាស់, ឈឺ, ស្លាប់ និងអ្នកបួស លុះយាងត្រឡប់មកវិញ ក៏ទ្រង់នឹកសង្វេគសូត្រព្រះទ័យ ដល់កណ្តាលរាត្រី ក៏ទ្រង់ឲ្យ ឆន្នអាមាត្យ រៀបសេះ កណ្ឋកៈ ហើយយាងចេញទៅសាងផ្នួស ដោយមានឆន្នអាមាត្យនិងសេះកណ្ឋកៈជូនដំណើរព្រះអង្គទៅនៅត្រើយ ថ្ងៃច័ន្ទពេញបូណ៌មី ខែអាសាឍឆ្នាំថោះ ក្នុងព្រះជន្ម ២៩ ព្រះវស្សា ។ ទ្រង់គង់សេះរំលងនគរ ៣ គឺ: កបិលពស្តុ, សាវត្ថី និងវេសាលី ដល់ត្រើយស្ទឹងអនោមា ; ក៏ដោះគ្រឿងប្រដាប់គ្រហស្ថចេញ ទ្រង់សាងផ្នួសតែព្រះអង្គឯង ។

ក្រោយពេលសាងផ្នួសហើយបាន ៦ ឆ្នាំ ដោយបានធ្វើទុក្ករកិរិយា ស្ទើរស្លាប់ចំរើនពុំមក ក៏បានគេឃើញនូវប្រាជ្ញាសម្មាសម្ពោធិញ្ញាណ ដែលហៅថាការត្រាស់ដឹងនៅឧរុវេលាប្រទេស ក្បែរស្ទឹងនេរញ្ជរានៅថ្ងៃពុធពេញបូរមី ខែពិសាខ ឆ្នាំរកា ក្នុងព្រះជន្ម ៣៥ ព្រះវស្សា (មុន គ.ស ៥៨៨ ឆ្នាំ) ។

កាលទ្រង់បានត្រាស់ដឹងធម៌ហើយ ទ្រង់យកពុទ្ធិ ដែលព្រះអង្គបានគេឃើញនោះ ទៅទូន្មាន ដឹកនាំអប់រំមនុស្សសត្វអស់ចំនួន ៤៥ឆ្នាំ ហើយទ្រង់ចូលបរិនិព្វានរំលត់សង្ខារ នៅថ្ងៃអង្គារ ពេញបូរមីឆ្នាំម្សាញ់ នៅនគរ កុសិនារា ក្នុងព្រះជន្ម ៨០ ព្រះវស្សា (មុន គ.ស ៥៤៣) ។

ដូច្នេះ យើងបានឃើញថា ព្រះពុទ្ធជាមេនៃលទ្ធិពុទ្ធសាសនា ពុំមែនជាអាទិទេព គ្មានរូប, គ្មានឈ្មោះនោះឡើយ ប៉ុន្តែ ជាមនុស្សដែលរស់ក្នុងសង្គមមនុស្ស ហើយបានដឹកនាំសង្គមមនុស្សឲ្យចេះដឹង ធ្វើល្អ មានវិចារណញ្ញាណ ហើយព្រះអង្គបានស្លាប់នៅក្នុងសង្គមមនុស្សនេះឯង ។

## ២– ពុទ្ធលទ្ធិ.–

ប៉ុន្តែមួយចំនួនក្នុងអ្នកប្រាជ្ញទាំងនោះ បានយល់ដូចគ្នាថា : ពុទ្ធលទ្ធិ ពុំមែនជាសាសនា ដែលយកអាទិទេពជាធំទេ ព្រោះពុទ្ធអង្គក៏ពុំទុកព្រះអង្គឯងជាអាទិទេព. ទទួលខុសត្រូវចំពោះអំពើល្អអាក្រក់របស់មនុស្សសត្វទេវតាដែរ ។ ពុទ្ធលទ្ធិគឺជាទស្សនវិជ្ជាដែលព្រះពុទ្ធ បានពន្យល់អ្នកផងឲ្យដើរផ្លូវត្រូវប្រកបដោយ វិចារណញ្ញាណផង ឲ្យមនុស្សសត្វទាំងអស់ ពឹងលើខ្លួនឯង ផង (អត្តាហិ អត្តនោ នាថោ) ។ គោលបំណងនៃការពន្យល់ដោះស្រាយនូវបញ្ហាពុទ្ធិ, គឺ: សុខៈហ្នឹងដែរ ។

## បញ្ហាពុទ្ធិក្នុងពុទ្ធនិយម

**១–ពុទ្ធិប្រភេទ.–** ពុទ្ធិក្នុងពុទ្ធនិយម សំដៅយកការចេះដឹងយល់ដោយវិចារណៈ ឯងការយល់ខុសត្រូវ ចំពោះជោគុបល ។ ពុទ្ធិសំខាន់ ៗ របស់ព្រះពុទ្ធមាន ៣ ជាវិជ្ជាញាណដែលព្រះអង្គ ទ្រង់ពិចារណាឃើញក្នុងរាត្រីពុធពេញបូរមីខែពិសាខ ឆ្នាំរកា ជាថ្ងៃត្រាស់ដឹងនោះគឺ :

**ក– បុព្វេនិវាសានុស្សតិវិជ្ជា.–** ចំណេះដឹងដែលជាការស្គាល់ - ដឹង - ឃើញដល់ជាតិកំណើត - ទីកន្លែង - គតិដែលព្រះអង្គធ្លាប់កើតជាអនេកជាតិ (បឋមយាម) ។

ខ- ចុតូបបាតវិជ្ជា.– ចំណេះចេះដឹង - យល់ស្គាល់នូវការស្លាប់កើតនៃមនុស្សសត្វ ក្នុងវដ្តសង្សារ ។

គ- អាសវក្ខយវិជ្ជា.– ចំណេះចេះដឹង - យល់ស្គាល់នូវហេតុនិងផលនៃការអស់អាសវកិលេស ។

វិជ្ជាសំខាន់ៗ ទាំងនេះ បាននាំឲ្យព្រះអង្គយល់ដល់ធម៌កើត - រលត់ ដោយមានបច្ច័យទាក់ទងគ្នា ដែលហៅថាបដិច្ចសមុប្បាទ ១២ ទៀត ។

## បដិច្ចសមុប្បាទ

- អវិជ្ជា បច្ចយា សង្ខារា សង្ខារកើតដោយអវិជ្ជា
- សង្ខារបច្ចយា វិញ្ញាណំ វិញ្ញាណកើតដោយសង្ខារ
- វិញ្ញាណបច្ចយា នាមរូបំ នាមនិងរូបកើតដោយវិញ្ញាណ
- នាមរូបបច្ចយា សឡាយតនំ អាយតនៈ ៦ កើតដោយនាមនិងរូប
- សឡាយតនបច្ចយា ផស្សោ ផស្សកើតដោយអាយតនៈ ៦
- ផស្សបច្ចយា វេទនា វេទនាកើតដោយផស្សៈ (ការពាល់ត្រូវ)
- វេទនាបច្ចយា តណ្ហា ចំណង់កើតដោយវេទនា
- តណ្ហាបច្ចយា ឧបាទានំ ឧបាទានកើតព្រោះចំណង់
- ឧបាទានបច្ចយា ភវោ ភពកើតព្រោះឧបាទាន
- ភវបច្ចយា ជាតិ ជាតិកើតព្រោះភពជាបច្ច័យ
- ជាតិបច្ចយា ជរាមរណំ ជរានិងមរណកើតព្រោះជាតិជាបច្ច័យ ។
- សោកបរិទេវទុក្ខទោមនស្សុបាយាសា សម្ភវន្តិ សេចក្តីសោកខ្សឹកខ្សួល ព្រួយ ទួញ. ចិត្ត និងចង្អៀតចង្អល់ចិត្តក៏កើតឡើងព្រោះ មានជាតិជាបច្ច័យ ។

ការកើតឡើងនេះ កាលរលត់ទៅវិញព្រោះតួនាទីរបស់វា ដោយរលត់អវិជ្ជា ក៏រលត់សង្ខារ... ការរលត់ ។ ល ។ នេះហើយ [illegible] និរោធធម៌ ។

មិនតែប៉ុណ្ណោះ វិជ្ជា ៣ ដែលជាពុទ្ធិសំខាន់នេះ នាំឲ្យគេឃើញនូវសច្ចធម៌ ៤ទៀត ។

## អរិយសច្ចធម៌ ៤ យ៉ាង

ក- ទុក្ខអរិយសច្ច.- ទុក្ខដែលជាសភាពពិត ។ ទុក្ខនេះមាន ៦ គឺ:

ជាតិទុក្ខ .- ទុក្ខព្រោះកំណើត

ជរាទុក្ខ .- ទុក្ខព្រោះចាស់

ព្យាធិទុក្ខ .- ទុក្ខព្រោះឈឺ

មរណទុក្ខ .- ទុក្ខព្រោះស្លាប់

សោកបរិទេវទុក្ខ ទោមនស្សុបាយាសាទុក្ខ.- ទុក្ខព្រោះសោក, ខ្សឹក, ខ្ទួចចិត្ត, ចង្អៀតចង្អល់ចិត្ត ជាដើម ។

ខ- សមុទយអរិយសច្ច .- ហេតុដែលនាំឲ្យកើតទុក្ខព្រោះមានអវិជ្ជា និងតណ្ហា ។

អវិជ្ជា .- មកពីមិនដឹងមិនយល់ហេតុនៃទុក្ខ ។

តណ្ហា .- ចំណង់ចង់បាននូវអ្វីៗ គ្រប់យ៉ាង មានកាមតណ្ហា - ចំណង់ក្នុងកាមគុណ មានរូប, សម្លេងជាដើម, ភវតណ្ហា ចំណង់ក្នុងភព ដោយចង់កើតជាទេព, ព្រហ្ម មានរូបជាដើម និង វិភវតណ្ហា - ចំណង់ចង់ទៅកើតក្នុងអរូបភព ដោយយល់ថាជាបរមសុខ ។

គ- និរោធអរិយសច្ច .- សភាពពិតក្នុងការរំលត់ទុក្ខ ដោយបំបាត់អវិជ្ជា ជាប្រភពដើមនៃទុក្ខ ។

ឃ- មគ្គអរិយសច្ច .- វិធីសំរាប់រំលត់ទុក្ខ ប្រកបដោយមគ្គ (ផ្លូវ) មានអង្គ ៨ ហៅថា អដ្ឋង្គិកមគ្គ គឺ:

សម្មាទិដ្ឋិ .- យល់ឃើញត្រូវ

សម្មាសង្កប្ប.- ត្រិះរិះត្រូវ

សម្មាវាចា .- សំដីត្រូវ

សម្មាកម្មន្ត .- ការងារត្រូវ

សម្មាអាជីវៈ .– ការចិញ្ចឹមជីវិតត្រូវ

សម្មាវាយាម .– ព្យាយាមត្រូវ

សម្មាសតិ .– រលឹកឃើញត្រូវ

សម្មាសមាធិ .– តាំងចិត្តត្រូវ ។

ពុទ្ធទាំងអស់របស់ព្រះពុទ្ធ ដែលទ្រង់បានប្រោសប្រទានដល់សត្វលោកចំនួន ៤៥ ឆ្នាំ បាន ចងក្រងទៅជាគម្ពីរនេះ ចែកជាបិដកបី ហៅថាព្រះត្រៃបិដក ។

## ព្រះត្រៃបិដក

១– វិន័យបិដក .– គម្ពីរ ឬ ក្បួននៃពុទ្ធ គឺព្រះវិន័យ ជាពុទ្ធានុញ្ញាត និង ពុទ្ធប្បញ្ញត្តិ មានចំនួន ២១០០០ ព្រះធម្មក្ខន្ធ មាន ៥ គម្ពីរ គឺ:

ក– អាទិកម្ម .– ច្បាប់និយាយពីទោសធ្ងន់ៗ ដូចជាបារាជិក ៤ សង្ឃាទិសេស ១៣ ជាដើម ។

ខ– បាចិត្តិយ .– ច្បាប់និយាយពីទោសស្រាល ដែលអាចសំដែងរួច បាន ដល់សុទ្ធិក បាចិត្តិយ ៣០ និស្សគ្គិយ បាចិត្តិយ ៩២ ។ល។

គ– មហាវគ្គ .– វគ្គ ឬ ផ្នែកធំ បាននិយាយពុទ្ធានុញ្ញាត ដែលជាការវិន័យ ។

ឃ– ចុល្លវគ្គ .– វគ្គ ឬ ផ្នែកតូច បានដល់ពុទ្ធានុញ្ញាតបន្ទាប់ពីមហាវគ្គ ។

ង– បរិវារ .– វិន័យកាយវន ដែល[illegible]ញត្តិ និង អនុញ្ញាតជាខាងក្រោយ ។

២– សុត្តន្តបិដក .– ក្បួននៃពុទ្ធផ្នែកព្រះសូត្រ ដែលនិយាយពីអំពើល្អ និង អាក្រក់ ការធ្វើបុណ្យទានជាដើម ។ សុត្តន្តបិដកនេះ មាន ២១០០០ ធម្មក្ខន្ធ ដូចព្រះវិន័យ ដែរ ហើយចែកចេញជាភាគមាន ៥ គម្ពីរ គឺ:

ក– ទីឃនិកាយ .– ផ្នែកនៃព្រះសូត្រដែលមានន័យវែង ។

ខ– មជ្ឈិមនិកាយ .– ផ្នែកនៃព្រះសូត្រ ដែលមានន័យជាកណ្ដាល - ល្មម ។

គ– សំយុត្តនិកាយ .– ផ្នែកនៃព្រះសូត្រ ដែលមានន័យប្រកបដោយនិទាន

ឧទាហរណ៍ ។

ឃ- អង្គុត្តរនិកាយ.- ផ្នែកនៃព្រះសូត្រ ដែលមានន័យប្រកបដោយអង្គសំខាន់ៗ

ង- ខុទ្ទកនិកាយ.- ផ្នែកនៃព្រះសូត្រ ដែលមានន័យតូចៗ ។

៣- អភិធម្មបិដក.- កម្រងនៃទស្សនៈ, គតិ ដែលនិយាយពីបរមត្ថធម៌ ប្រកបដោយអត្ថ ៤ យ៉ាងគឺ: ចិត្ត, ចេតសិក, រូប, និព្វាន ហើយចែកជា ៧ គម្ពីរ គឺ:

ក- ធម្មសង្គណី.- ផ្នែកនៃធម៌

ខ- វិភង្គ.- អត្ថ ឬ ចំណែកនៃធម៌

គ- កថាវត្ថុ.- ធម៌មានន័យផ្ទុយគ្នា

ឃ- បុគ្គលប្បញ្ញត្តិ.- បុគ្គលពណ៌នា

ង- ធាតុកថា.- ការញែកធាតុ

ច- យមកៈ.- ធម៌ជាគូៗ

ឆ- បដ្ឋាន.- ធម៌មានទំនាក់ទំនងដោយបច្ច័យ ។

ព្រះអភិធម្មបិដក មានចំនួន ៤២០០០ ព្រះធម្មក្ខន្ធ ។ គួរកត់សំគាល់ថា:

- វិន័យបិដក ប្រៀនដោយកិច្ច
- ព្រះសូត្របិដក ប្រៀនដោយវោហារ:
- ព្រះអភិធម្មបិដក ប្រៀនដោយអត្ថ ។

គុណិកនៃបិដកទាំង ៣ បើរួមមកជាការប្រៀនប្រដៅនៅនោះលោកពោល យ៉ាងនេះគឺ:

១- សព្វបាបស្ស អករណំ.- ត្រូវហាមមិនឲ្យធ្វើបាបគ្រប់យ៉ាង (បានដល់វិន័យបិដក) ។

២- កុសលស្សូបសម្បទា.- ត្រូវឲ្យបំពេញកុសលធម៌ (បានដល់ព្រះសូត្របិដក) ។

៣- សចិត្តបរិយោទបនំ.- ត្រូវឲ្យធ្វើចិត្តឲ្យផូរផង់ស្អាតស្អំ (បានដល់ព្រះអភិធម្មបិដក) ។

២– វុឌ្ឍិវិធី.– ដើម្បីនឹងបានវុឌ្ឍិ ក្នុងលទ្ធិពុទ្ធនិយម គឺបានដោយការសាងសន្សំ, ការសិក្សាពិចារណា, ការពិសោធន៍ផ្ទាល់ខ្លួន ។ បើនិយាយដោយឡែកព្រះពុទ្ធទ្រង់ទុកនូវវិធី ៤ យ៉ាងហៅថាឥទ្ធិបាទធម៌គឺ:

ក– ឆន្ទៈ.– ពេញចិត្តនឹងកិច្ចការ, ចំណេះវិជ្ជា

ខ– វិរិយ.– ព្យាយាមរៀន - ពិចារណា

គ- ចិត្ត.– មានចិត្តនឹងប៉ុនប៉ងនឹងរៀន - ពិចារណា

ឃ– វិមំសា.– សាកល្បងលខ្ទង់កិច្ចការ, ចំណេះវិជ្ជាដែលខ្លួនរៀនហើយ ។

ព្រះពុទ្ធកាលមុនទ្រង់ត្រាស់ ដែលជាវិជ្ជាឃើញក្នុងថ្ងៃត្រាស់ដឹងនោះ ព្រះអង្គព្យាយាមរៀនជាមួយឧទកតាបសនិងអាឡារតាបស លុះរកការត្រាស់ដឹងមិនឃើញក៏ប្រឹងស្វែងស្វាធ្យាយព្យាយាមដោយព្រះអង្គឯង នៅថ្ងៃត្រាស់ដឹងក៏ទ្រង់ពិចារណាដោយវិធីប្រាសបណ្ដោយចុះឡើង ។ ហេតុឃើញបដិច្ចសមុប្បាទ ហើយថែកប្រាជ្ញាក៏ភ្លឺស្វាងឡើង ។

## ៣– វុឌ្ឍិខាធ.– បញ្ញាកម្ម - ផល

មនុស្សមានការចេះដឹង ល្ងង់ខ្លៅ ល្អអាក្រក់ស្រេចនៅលើខ្លួនឯង, លើអំពើរបស់ខ្លួន ។ ខ្លះមានវិជ្ជា - ចេះដឹងបានសម្រេចមគ្គផល ក៏ដោយសារខ្លួនឯងបានសិក្សាសន្សំ - ប្រឹងស្វែងស្វាធ្យាយ, បើល្ងង់ខ្លៅឥតប្រាជ្ញា ក៏ដោយសារតែខ្ជិលច្រអូស - ធ្វេសប្រហែស ។

បើបានល្អ - អាក្រក់ក៏ដោយសារកម្មនិងផល ២ យ៉ាង :

ក– កល្យាណកម្ម.– អំពើល្អឲ្យផលល្អ

ខ– បាបកម្ម.– អំពើអាក្រក់ឲ្យផលអាក្រក់ ព្រះពុទ្ធបានបញ្ជាក់ដោយពុទ្ធភាសិតមួយទៀតថា (យាទិសំ វប្បតេ ពីជំ តាទិសំ លភតេ ផលំ= អ្នកណាសាបព្រួសពូជបែបណា អ្នកនោះនឹងបានផលបែបនោះ) ។

រួមមកហើយនេះ យើងបានឃើញថា ការដោះស្រាយបញ្ហាវុឌ្ឍិ ក្នុងពុទ្ធនិយមមានលក្ខណៈជាវិចារណៈ, ជាកំពឹងខ្លួនឯង ជាវិទ្យាសាស្ត្រ និងប្រាកដនិយមថែមទៀតគ្មានការទេពណាជាធំតាម

ជួយអ្នកណាឲ្យល្អ បរិសុទ្ធឬសៅហ្មងឡើយ (សុទ្ធិ អសុទ្ធិ បច្ចត្តំ នាញ្ញោ អញ្ញំ វិសោធយេ–ការបរិសុទ្ធិនិងមិនបរិសុទ្ធមានលក្ខណៈផ្សេងគ្នា មនុស្សម្នាក់មិនអាចធ្វើឲ្យមនុស្សម្នាក់ទៀតបរិសុទ្ធបានទេ) ។

## បញ្ហាភពៈក្នុងពុទ្ធនិយម

ក–ភពៈប្រភេទ.– ក្នុងពុទ្ធនិយម មានការចែកលោកជា៣ ប្រភេទ ដែលហៅថា ត្រៃលោក ឬ ត្រៃភពគឺៈ កាមភព, រូបភព, អរូបភព ។

### កាមភពមាន ១១ ជាន់គឺៈ

– ឋានកាមាវចរសួគ៌ ៦ ជាន់បានដល់ៈ

១– ឋានចាតុម្មហារាជិកា (មានទេពធំ ៤)

២– ឋានត្រៃត្រិង្ស (មានទេវតា ៣៣ អង្គ មានព្រះឥន្ទជាធំ)

៣– ឋានយាមា

៤– ឋានតុសិត (ជាលំនៅនៃអ្នកមានបុណ្យ)

៥– និម្មានរតី

៦– បរនិម្មិតវសវត្តី

– ឋានមនុស្ស ១ ជាន់

– ឋានអបាយ (អបាយភូមិ) ៤ ជាន់

រូបភព ១៦ ជាន់ បានដល់ឋានព្រហ្មមានរូបទាំង ១៦ ជាន់ ។

– ឋានអរូបភព ៤ ជាន់ បានដល់ឋានព្រហ្មឥតរូប ៤ ជាន់ មានអាកាសានញ្ចាយ–តនៈជាដើម ។

### ឋានកាមភព

ជាលំនៅនៃមនុស្ស, ទេវតា, សត្វ ដែលនៅជាប់ជំពាក់ក្នុងកាមគុណ ៥ ។

– ពួកទេវតា ជាអ្នកមានបុណ្យបារមីសន្សំទុកច្រើន សោយសុខច្រើន ។

– ពួកមនុស្សមិនសត្វ មានបុណ្យខ្លះ គ្មានបុណ្យខ្លះ ។

## ឋានអបាយ (អបាយភូមិ)

មាន: នរក, ប្រេត, អសុរកាយ, តិរច្ឆាន ។ (បាននិយាយរួចមកហើយ) ។

## ឋានមនុស្ស – និងមនុស្សប្រភេទ

មនុស្សក្នុងពុទ្ធនិយម ចែកចេញជា ២ ផ្នែកផ្សេងគ្នា:

ក– មនុស្សខ្ពង់ខ្ពស់ ឬ អរិយបុគ្គល .– មនុស្សពួកទី១ នេះ បានដល់ពួកព្រះអរហន្តខីណាស្រពទាំងឡាយផង ពួកអ្នកបានសម្រេចមគ្គផលផ្សេងៗ ផង មានព្រះពុទ្ធ, អរហន្តសាវ័ក, ព្រះបច្ចេកពុទ្ធ, ព្រះពោធិសត្វជាដើម ។

ខ– មនុស្សសាមញ្ញ .– បានដល់មនុស្សទូទៅជាបុថុជ្ជន មិនទាន់បានសម្រេចមគ្គផលណាមួយនៅឡើយ ។

### ខ– ភាវៈវិធី.–

ភាវៈទាំងអស់មាន ២ ចំណែកគឺ ភាវៈជានាម ១ ភាវៈជារូប ១ ។

១– ភាវៈជានាមសំដៅយកចិត្ត

២– ភាវៈជារូបសំដៅយកកាយ ។

នាមនិងរូប ឬ ចិត្តនិងកាយនេះ កើតផ្សំគ្នាបង្កើតជាជីវិតប្រកបដោយខន្ធ ៥ គឺ រូបខន្ធ, វេទនាខន្ធ, សញ្ញាខន្ធ, សង្ខារខន្ធ និងវិញ្ញាណខន្ធ ។

វិធីដែលនាំឲ្យកើតភាវៈឡើង មិនមែនដោយសារទេពណាជាអ្នកបង្កើតឡើយ តែដោយសង្ខតធាតុដែលផ្សំផ្គុំគ្នាឡើង តាមធម្មជាតិនេះឯង ។

### គ– ភាវខាធ.–

ភាវៈជាសង្ខតធាតុទាំងអស់ ស្ថិតនៅលើត្រៃលក្ខណ៍ដូចតទៅគឺ:

**១– អនិច្ចំ.–** ភាវៈទាំងអស់សុទ្ធតែមិនទៀងទាត់ ដូចការកើតស្លាប់ចំរើនវិនាស មិនទៀងពេល និងទីកន្លែង ។

២– ទុក្ខំ.– ការៈទាំងអស់ឡើតែមានខាងមិនទៀង សុខក៏មានទុក្ខផងគ្នា ។

៣– អនត្តា.– ការៈទាំងអស់សុទ្ធតែមិនមែនជារបស់ខ្លួន ។

ដូច្នេះការៈក្នុងពុទ្ធនិយម កុំមែនជាទិដ្ឋិ ជាប្រាជ្ញឡើយ ។

## បញ្ហាសុខៈ ក្នុងពុទ្ធនិយម

១– សុខប្បភេទ.– សុខក្នុងពុទ្ធសាសនាមាន ២ ថែរគឺ:

ក– សាមញ្ញសុខ ឬ លោកិយសុខ.– ជាសុខធម្មតា ឬ ហៅជាកាមសុខ គឺសុខនៅលាយឡំជាមួយទុក្ខ ។

ខ– បរមសុខ.– សុខដ៏ប្រសើរខ្ពង់ខ្ពស់ គឺសុខដែលកើតមកពីការរំលត់ទុក្ខ ញាណដល់ព្រះនិព្វាន ។

២– សុខវិធី.– សុខធម្មតា មានការទាក់ទងទៅនឹងប្រយោជន៍ ៤ យ៉ាងក្នុងបច្ចុប្បន្នគឺ :

ក– ឧដ្ឋានសម្បទា.– ដល់ព្រមដោយព្យាយាម

ខ– អារក្ខសម្បទា.– ដល់ព្រមដោយការថែរក្សា

គ– កល្យាណមិត្តតា.– មានមិត្តល្អ

ឃ– សមជីវិតា.– ការចិញ្ចឹមជីវិតស្របតៃ ។

ចំណែកឯការនាំសុខក្នុងបរលោក ឬ បរមសុខ មានទាក់ទងនឹងសីល, សមាធិ បញ្ញា ដែលទាក់ទងដល់ប្រយោជន៍ក្នុងបរលោក ៤ យ៉ាងគឺ :

ក– សទ្ធាសម្បទា.– ដល់ព្រមដោយជំនឿ

ខ– សីលសម្បទា.– ដល់ព្រមដោយសីល

គ– ចាគសម្បទា.– ដល់ព្រមដោយការបំណាយទាន

ឃ– បញ្ញាសម្បទា.– ដល់ព្រមដោយប្រាជ្ញា ។

ដំណើរនេះ នាំឱ្យផុតអាក់ចិត្តឱ្យស្អាតពីអកុសល, តណ្ហា, កិលេសជៀសវាងនិងតម្រេកក្នុងចិត្ត

ដើម្បីសម្រេចមគ្គផលជាន់ខ្ពស់គឺអរហត្តមគ្គនិងអរហត្តផលជាអវសាន ។

### ៣-សុខខាង—

បរមសុខក្តី សុខធម្មតាក្តី មិនមែនជាអំណោយនៃអាទិទេព ឬព្រះពុទ្ធ ឬ អ្នកណាឡើយ ប៉ុន្តែជាផលដែលកើតចេញពីខ្លួនឯង , បានមកពីការប្រព្រឹត្តិល្អដោយខ្លួនឯងនេះតែម្តង ។ ដូច្នេះ ដើម្បីសម្រេចបរមសុខ ជាសុខសំខាន់ជាងសុខធម្មតាគេត្រូវ :

- លះបង់តណ្ហា
- កំចាត់អវិជ្ជា
- មិនប្រមាទធ្វេសប្រហែស
- តំកល់ចិត្តក្នុងសីលសមាធិបញ្ញា
- លះបង់អត្តៈ កុំប្រកាន់ថាខ្លួន , ថារបស់ខ្លួន ។

## យោបល់រួមចំពោះបញ្ហាពុទ្ធនិយម

**ពុទ្ធសាសនា** នោះបើកើតឡើងនៅក្រោយសម័យ ព្រាហ្មណ៍និយមក្តី កើតនៅក្នុងសង្គមហិណ្ឌូក្តី ពុទ្ធសាសនាមិនមែនជាលទ្ធិដែលកែប្រែដើម្បីក្រាលទំព្រាហ្មណ៍សម្រាប់ជាផលប្រយោជន៍ពួកព្រាហ្មណ៍ឡើយ តាមពិតពុទ្ធលទ្ធិមានលក្ខណៈជាលទ្ធិ ប្រកបដោយទស្សនៈទ្រឹស្តីជាវិចារនិយម ជិតវិទ្យាសាស្ត្រថែម ទៀតៗ ព្រះពុទ្ធអង្គមហាទស្សនវិទូ មួយអង្គក្នុងសម័យនោះ ពុំបានទុកវណ្ណៈមនុស្សជាពួកទេ តែព្រះអង្គបានឲ្យតម្លៃទៅលើអំពើផលនៃមនុស្ស , ការប្រឹងប្រែងសន្សំសាងបារមីរបស់មនុស្សទៅវិញ ហើយគោលបំណងធំគឺបង្ខំឲ្យមនុស្សជឿលើខ្លួនឯងជាមុនក្នុងដំណើរ ទៅកាន់បរមសុខ ជានិព្វានៈ ឯកន្តសុខនិរាគ្រោះហ្នឹងឯង ។

× × ×

## មូលធម៌នៃវប្បធម៌ខ្មែរ

**វប្បធម៌ខ្មែរ**កើតជាមានរួចមកហើយ តាំងពីសម័យបុរេប្រវត្តិសាស្ត្រ (Préhistoire) មកម្ល៉េះ

ប៉ុន្តែចំនួនខ្លះនៃវប្បធម៌ ដែលជាផ្នែកនៃគោលគំនិត - ការចេះដឹង (ជាពុទ្ធិ) នៃជនជាតិនីមួយៗ នៅសម័យបុរេប្រវត្តិសាស្ត្រ ដែលមានចំណុះ ពុំទាន់គ្រប់គ្រាន់ស្របតាមកាលវិវត្តន៍នៅឡើយ ។ ដូច្នេះគោលគំនិតថ្មីៗ របស់ខ្មែរត្រូវតែរកទៅទៀតជានិច្ច ។

ជាមួយនឹងការរកគំនិតនេះខ្មែរបានជួបនឹងវប្បធម៌មួយមុនគេ គឺវប្បធម៌ឥណ្ឌា ។ រឿងនេះជាការពិតហើយឥតប្រកែកបាន ព្រោះឥណ្ឌាបាននាំវប្បធម៌របស់ជាតិខ្លួនដែលមានវ័យចាស់ទុំបន្តិចទៅហើយចូលមកស្រុកខ្មែរតាមផ្លូវជំនួញនិងសាសនា ។ តាមផ្លូវជំនួញ មានពួកឥណ្ឌាមកទិញគ្រឿងទេសដូចជាម្រេចជាដើម តាមដងទឹក ។ ផ្លូវសាសនា ឥណ្ឌាបាននាំសាសនា ២ ចូលមកប្រទេសខ្មែរ ដោយមិនអាចប្រកែកបានគឺព្រាហ្មណ៍សាសនា និងពុទ្ធសាសនា ។

## ប្រវត្តិសាសនាចូលមកស្រុកខ្មែរ

សាសនាឥណ្ឌាធំៗ ពីរគឺ ព្រាហ្មណ៍សាសនានិងពុទ្ធសាសនាត្រូវឥណ្ឌានាំចូលមកស្រុកខ្មែរ ។ ពុទ្ធសាសនា មានពីរផ្នែកទៀតគឺ ពុទ្ធសាសនាអាចារិយវាទ (មហាយាន) និងពុទ្ធសាសនាថេរវាទ (ហីនយាន) ។ សាសនាព្រាហ្មណ៍និងពុទ្ធសាសនាទាំងពីរបែប បានមានជីវិតរស់នៅក្នុងប្រទេស, សង្គម, ជីវភាព រហូតដល់សព្វថ្ងៃដោយសុខសាន្តជាមួយគ្នា គ្រាន់តែមានការរីកចំរើនម្តងម្នាក់ក្នុងសម័យមួយៗ :

- ពីគ្រឹស្តសតវត្សទី ១ ដល់ទី៨ ពុទ្ធសាសនាថេរវាទចំរើនលូតលាស់ជាងព្រាហ្មណ៍សាសនា និងពុទ្ធសាសនាអាចារិយវាទ (មហាយាន) ។
- ពីគ្រឹស្តសតវត្សទី ៨ ដល់ទី ១៣ ព្រាហ្មណ៍សាសនាចំរើនជាងពុទ្ធសាសនាទាំងពីរ ។
- ពីគ្រឹស្តសតវត្សទី១៣ ដល់សព្វថ្ងៃ ពុទ្ធសាសនាថេរវាទ (ហីនយាន) ចំរើនជាងព្រាហ្មណ៍សាសនា ។

គួរកត់សំគាល់ថា នៅចុងសតវត្សទី ១២ (ប្រហែលពី ១១៨១ ដល់ដើមសតវត្សទី ១៣) ពុទ្ធសាសនាអាចារិយវាទ (មហាយាន) បានចំរើនជាងពុទ្ធសាសនាថេរវាទ (ហីនយាន) យ៉ាងច្រើន ព្រោះនៅនឹងប្រាសាទបាយ័ន និងប្រាសាទនានា ដែលសាងក្នុងរជ្ជស្តេចជ័យវរ្ម័នទី ៧ (១១៨១-

១២១៨ ឬ ១២២០ ) មានសាងរូបពោធិសត្វ អវលោកិតេស្វរៈ ( ព្រះកេតុ ៤ ) ជាច្រើនដែរផង ។

## ចំណូលនៃលទ្ធិព្រាហ្មណ៍និយមមកក្នុងប្រទេសខ្មែរ

លទ្ធិព្រាហ្មណ៍និយម ត្រូវចូលមកស្រុកខ្មែរ តាំងពីមុនគ្រឹស្តសករាជមកម៉្លេះ ប៉ុន្តែភាពច្បាស់លាស់គឺ នៅដើមគ្រឹស្តសករាជ ពួកព្រាហ្មណ៍បាននាំយកលទ្ធិនេះចូលមកក្នុងស្រុកខ្មែរ ហើយបន្ទាប់ពីនោះ គឺព្រាហ្មណ៍ម្នាក់ឈ្មោះ កៅឌិន្យ បានមករៀបអភិសេកជាមួយនាង លីវយី នៅលើការ គោរពធ្លូត ឲ្យខ្មែរគោរពសាសនាព្រាហ្មណ៍ ហើយខ្មែរខ្លះបានយកព្រះព្រហ្មជាធំ ខ្លះយកព្រះវិស្ណុ ខ្លះយកព្រះសិវៈ ជាអាទិទេព ។ ឥទ្ធិពលនៃសាសនាព្រាហ្មណ៍បានលាតត្រដាងនៅក្នុងសិល្បៈ សិល្ប៍, ទំនៀមទម្លាប់, ប្រពៃណី និងសង្គមខ្មែរយ៉ាងច្រើន ។

## ១- សិល្បៈខ្មែរបែបព្រាហ្មណ៍និយម

### ក- ក្នុងសិល្បៈរចនាប្រាសាទបុរាណ.-

ប្រាសាទខ្មែរស្ទើរតែទាំងអស់ នៅគ្រប់ទេវាលយ លើកលែងតែទេវាលយ បាយ័ន មួយចេញ សុទ្ធសឹងតែសាងឡើងសំរាប់ព្រះសិវៈ (ឥសូរ) និងវិស្ណុ (ព្រះនារាយណ៍ទាំងអស់) ។

**-ពួកប្រាសាទសាងថ្វាយព្រះសិវៈ.-** ប្រាសាទពួកនេះគេទុកជាបូជនីយដ្ឋាន ចំពោះព្រះសិវៈ ដូចប្រាសាទសំបូរព្រៃគុក, ភ្នំធំ, ប្រាសាទអណ្តែត, កំពង់ព្រះ, ភូមិប្រាសាទ, ដំរីក្រាប, ខ្ទីងស្លាប់, រូបអារក្ស, ថ្មដាប់, ព្រះគោ, បាគង, លលៃ, ភ្នំបាខែង, ភ្នំក្រោម, កោះកេរ, បន្ទាយស្រី, ឃ្លាំង, តាកែវ, ពិមានអាកាស, ភ្នំជីសូរ, ព្រះវិហារ, ចៅស្រីវិបុល ជាដើម ។

**ខ- ភស្តុតាង.-** ប្រាសាទទាំងនេះ មានរូបលិង្គព្រះសិវៈនិងយោនីតាំងតម្កល់ នៅពាសពេញ ។

**ចំណាំ -** ប្រាសាទ ភ្នំបាខែង មានលក្ខណៈល្អិតល្អតាមក្បួនព្រាហ្មណ៍ហើយសម្បូណ៌លិង្គនិងយោនីជាងគេ ។

**-ពួកប្រាសាទសាងថ្វាយព្រះវិស្ណុ.-** ប្រាសាទពួកនេះគេទុក ជាបូជនីយដ្ឋានចំពោះព្រះវិស្ណុ ដូចប្រាសាទបាពួន, វត្តភ្នំ, មេបុណ្យ, អង្គរវត្ត, បន្ទាយសំរែ, ព្រះពិធូ, ធម្មនន្ទ

ចៅសាយទេវតា , វត្តអធ្វា ជាដើម ។

ភស្តុតាង.- ប្រាសាទទាំងនេះ មានរូបព្រះវិស្ណុឈរឬអង្គុយជាច្រើនដូចនៅប្រាសាទ មេបុណ្យខាងលិច មានរូបព្រះវិស្ណុផ្ទំជានិមិត្តរូបនៃការកើតបង្កើតលោក ។

ចំណាំ.- ប្រាសាទអង្គរវត្ត គេសាងថ្វាយព្រះវិស្ណុទាំងស្រុងក្នុងរជ្យស្ដេចសូរ្យវ- រ្ម័នទី ២ ហើយស្ដេចអង្គនេះកាលសុគតទៅ ក៏មានព្រះនាមថា «បរមវិស្ណុលោក» ។ល។

## លក្ខណៈប្រាសាទ

ក្នុងព្រហ្មញ្ញនិយម គេតែងសង់ប្រាសាទលើភ្នំ ឬជាពីរ៉ាមីតលើទីខ្ពស់ដែលគេលើកដី កួនឡើង ។

សំគាល់.- រូបលក្ខណៈនៃរូបបដិមាព្រះព្រហ្ម ព្រះសិវៈ ព្រះវិស្ណុនិងរូបតំណាង ព្រមទាំងគ្រឿងអលង្ការ , គេឃើញមាននិយាយក្នុងលទ្ធិព្រាហ្មណ៍ខាងដើមរួចហើយ ។

## ២- អក្សរសិល្ប៍ខ្មែរបែបព្រាហ្មណ៍និយម

អត្ថបទអក្សរសិល្ប៍បែបព្រាហ្មណ៍មាននៅក្នុងគម្ពីរផ្សេង ៗ ដូចគម្ពីរវេទទាំង ៤ គម្ពីរមហា- ភារតៈ , រាមាយណៈ , បុរាណៈ , តន្ត្រៈ (បញ្ចតន្ត្រៈ) ធម្មសាស្ត្រជាដើមជាភាសាសំស្ក្រឹត ។

ខ្មែរបានយកគម្ពីរទាំងនោះជាគោលដែរ តែបានរចនាឡើងដែលជាអត្ថបទអក្សរសិល្ប៍ខ្មែរឲ្យ មានលក្ខណៈជាខ្មែរតាមគុណគតិ , មនោសាស្ត្រ , និងការរបស់ខ្មែរ ដែលមានហេតុទេពអស្ចារ្យ, សិល្បសាស្ត្រ , មន្តអាគម ជាបែបជំនឿរបស់ខ្មែរដែលខ្មែរធ្លាប់មានតាំងពីពេលមុនសាសនាព្រាហ្មណ៍ ចូលផ្សាយសព្វពេលមកម៉្លេះ ។ អត្ថបទអក្សរសិល្ប៍ខ្មែរដែលមានលក្ខណៈជាព្រាហ្មណ៍និយមនេះមាន ច្រើនដែរ ដូចជារាមកេរ្តិ៍ខ្មែរ , រឿងព្រះជិនវង្ស , ទិព្វសង្វារ ជាដើម ។

## លក្ខណៈអក្សរសិល្ប៍ខ្មែរបែបព្រាហ្មណ៍និយម

១- ផ្ដើមរឿង.- បង្ហាញពីឈ្មោះអាទិទេពធំ ៗ ដូចព្រហ្ម , វិស្ណុ , សិវៈ ។

២- តួរឿង .-

ក.- តួអង្គ.- អាទិទេពឬអវតារនៃព្រះវិស្ណុ, សិវៈមកយកកំណើតក្នុងមនុស្សជា

វ

ចុះសេនាស្ពានមិនងារស្ពាន ។ ដោយពឹងអំណាចឥសី , ទេវៈ , យក្ស , គ្រុឌ ។ល។

ដំណើររឿង.– ច្បាំងមិនចេះចប់ ប្រកបដោយសិល្បសាស្ត្រស្ទាប ។

គ– កន្លែង.– ព្រៃហិមពាន្ត , ក្រុងអយុធ្យា , ស្ថានសួគ៌ , ភ្នំកៃលាស , បា-តាល , ស្ថានសត្តបរិ ។ល។

ឃ– បញ្ហាចោទ.– ដោយមានវិវត្តទំនាស់រវាងសភាវៈល្អនិងសភាវៈអាក្រក់ ។

ង– បញ្ហាដោះស្រាយ.– ដោយសិល្បមន្ត ឫទ្ធិអំណាច , សង់សឹក , ច្បាំងគ្នា ។

ច– ស្នេហា.– មកពីឫទ្ធិពលនៃទេវតា ហើយអ្នកឈ្នះ គឺបានទទួលស្នេហា ។

ឆ– កំសត់.– កើតដោយវិវត្តទំនាស់រវាងសភាវៈល្អនិងអាក្រក់ ច្បាំងតស៊ូនែន, មានការលំបាកខាងផ្លូវចិត្ត (កម្សត់) ឬកាយ (ជិះទៀន) ។

ជ–គតិរឿង.– ធ្វើឲ្យមនុស្ស :

–មានជំនឿលើទេវតា

–ស្គាល់ទេវតានិងឫទ្ធិពល

–ខំការពារសម្បូរលើខ្លួនឯង

–ខំសីលធម៌ ។ល។

៣– បញ្ចប់រឿង.– រឿងតែងចប់នៅពេលណា ដែលតួអង្គឯកការពារទេវតា, មានជ័យជំនះលើសភាវៈអាក្រក់ យក្ស, គ្រុឌ, អសុរ ។

## ៣– ព្រាហ្មណ៍និយមនិងសង្គមខ្មែរ

### ទំនៀមទំលាប់ – ប្រពៃណី

ក្នុងសង្គមខ្មែរ មានទំនៀមទំលាប់ប្រពៃណីជាច្រើនដែលមានទាក់ទងនឹងលទ្ធិព្រាហ្មណ៍និយម (លាយនឹងពុទ្ធនិយមខ្លះផង) ដូចជា :

ក–ពិធីប្រូកក់ប្រសិទ្ធីទារក.– មានផ្សាភ្ជាប់ព្រលឹង , អន្ទងព្រលឹង ។

ខ–ពិធីកោរជុក.– ប្រើមន្តគាថាប្រសិទ្ធ ។

គ- ពិធីរៀបមង្គលការ.- ធ្វើទំនៀមតំណាងលិង្គឥសូរ , ធ្វើទឹម តំណាងយោនីនាងឧមាភគវតី ។ ធ្វើពិធីចុកល័ក្ខណ៍, បង្វិលពពិល , បញ្ចុកបេក ។ ក្រមុំកម្លោះស្រឡាញ់គ្នាដោយដាក់ស្នេហ៍ , មន្តអាគម ។

ឃ- ធ្វើពិធីសែនព្រេន.- ឡើងផ្ទះថ្វាយស្រា , ស្លាធម៌ , បាយសី ។

ង- ក្នុងពិធីបុណ្យទាន.- មានធ្វើរោងទេពតា ៨ ទិស , ធ្វើទ្រូង , មានស្លាធម៌ បាយសី ៧ ថ្នាក់ ។

ច- ធ្វើពិធីបក់ព្រលឹង

ឆ-ពិធីលោយសព.- មានធ្វើបតិច្ចផ្ទុំរបស់នៅពេលបូជាសពរួចៗ លាងធាតុដោយទឹកដូង (លាងបាប) ។

ជ- ព្យាបាលជម្ងឺ.- ប្រើមន្តអាគម, ស្រោចទឹក, គ្រូប្រើសំពត់សកាវេ , ក្រមាសបង់ក ។ល។

នៅមានពិធីច្រើនទៀតណាស់ ដែលទាក់ទងនឹងលទ្ធិព្រាហ្មណ៍និយម ប៉ុន្តែពិធី, កិច្ចការទាំងនេះមានខ្លះ ។ ជារបស់ខ្មែរស្រេចទៅហើយ ។ ដូច្នេះខ្មែរយករបស់ណាមកធ្វើកែច្នៃយ៉ាងណាក៏ទៅជារបស់ខ្មែរ មានលក្ខណៈជាខ្មែរវិញ ។

× × ×

## ២- ពុទ្ធនិយមក្នុងសង្គមខ្មែរ

### ក- ចំណូលមកក្នុងស្រុកខ្មែរនៃពុទ្ធសាសនា.-

តតិយសង្គាយនា ក្រោមមហាថេរាធិបតីនៃព្រះមោគ្គលីបុត្តតិស្សត្ថេរ ដោយមានព្រះបាទអសោកមហារាជ ជាអ្នកឧបត្ថម្ភ បានធ្វើចប់នៅ ព.ស. ២៣៦ នៅវត្តអសោការាម ក្រុងបាតលីបុត្ត (ឧប្បត្តិហេតុនៃតតិយសង្គាយនានេះ កើតឡើងតាំងពី ព.ស. ២១៨ ឆ្នាំម្ល៉េះ) ។ ក្រោយ

តតិយសង្គាយនានេះ ព្រះមោគ្គលីបុត្តត្រទ្រង់បានបញ្ជូនព្រះសមណទូត ទៅគ្រប់ទិសទីក្នុងជម្ពូទ្វីប ចំនួន១៦ កន្លែង ដើម្បីផ្សាយព្រះពុទ្ធសាសនា ។ ព្រះសោណត្ថេរ និងព្រះឧត្តរត្ថេរ បាននិមន្តចូលមកកាន់ដែនដីសុវណ្ណភូមិ (មានភូមា, សៀម, ខ្មែរ, លាវ) ដើម្បីផ្សាយព្រះពុទ្ធសាសនា ។ ប្រទេសខ្មែរបានទទួលយកពុទ្ធសាសនាថេរវាទ តាំងពីពុទ្ធសតវត្សទី៣ នៃពុទ្ធសករាជនោះឯង ។

## ខ– ពុទ្ធសាសនានិងប្រជាជនខ្មែរ.–

ព្រះពុទ្ធសាសនាទាំងពីរនិកាយ គឺនិកាយមហាយាន និង ហីនយាន បានផ្សាយចូលមកក្នុងសង្គមខ្មែរតាំងពីដើមមក ។ ប៉ុន្តែនិកាយហីនយាន (ថេរវាទ) មានការលូតលាស់ជាងនិកាយមហាយាន (អាចរិយវាទ) លើកលែងតែនៅចុងគ្រិស្តសតវត្សទី ១២ និងដើមសតវត្សទី ១៣ បន្តិចចេញ (សម័យប្រាសាទបាយ័ន - រាជ្យស្តេចជ័យវរ្ម័នទី ៧) ដែលនិកាយមហាយានរីកចំរើនជាងហីនយាន ។

**ចំណាំ.–** និកាយមហាយាន-ហីនយានបានបែកចេញពីគ្នា ក្រោយទុតិយសង្គាយនា នៅវត្តវាលុការាម ក្រុងវេសាលីដែនវជ្ជី ក្រោយពុទ្ធបរិនិព្វាន១០០ ឆ្នាំ រឿងវត្ថុ ១០ ប្រការ ។ និកាយមហាយាន បែកទៅទិសខាងជើងនៃប្រទេសឥណ្ឌា ឬ ហៅថាឧត្តរនិកាយ ឯនិកាយហីនយាន បែករីកចំរើនមកផ្នែកខាងត្បូង ហើយទីបំផុតរីកចំរើននៅកោះលង្កាទ្វីប ដែលជានិកាយត្រឹមត្រូវតាមព្រះអរហន្តសាវ័កគាំទ្រតាមពុទ្ធវិន័យ ឬ ហៅថាទក្ខិណនិកាយ ។

និកាយមហាយាន គោរពព្រះពោធិសត្វជាងព្រះពុទ្ធ ព្រោះគេយល់ថា ព្រះពុទ្ធនិព្វានទៅហើយ មិនអាចនៅជួយជិះយានដឹកនាំសត្វឲ្យទៅនិព្វានបានទេ មានតែពោធិសត្វ ទើបជួយបាន ព្រោះពោធិសត្វមិនទាន់បានត្រាស់ មិនទាន់និព្វាន ។

ឯនិកាយហីនយាន (ថេរវាទ) គោរពតាមតែពុទ្ធវាទ ដែលទ្រង់សំដែងរួចមកហើយ តែប៉ុណ្ណោះ ។

ប្រជាជនខ្មែរបានយកពុទ្ធសាសនា បែបថេរវាទនេះ មកគោរពប្រតិបត្តិជាច្រើនសតវត្សណាស់មកហើយ ។ សូម្បីក្នុងសម័យខ្លះ សាសនាព្រាហ្មណ៍មានឥទ្ធិពលជាង ក៏ពុទ្ធសាសនាថេរ-

ពងនៅតែមានជីវិត និងរស់នៅក្នុងសង្គមខ្មែរ ដោយសុខសាន្តជាដរាប ជាពិសេសចាប់តាំងពី សតវត្សទី ១៣ រហូតដល់សព្វថ្ងៃ ពុទ្ធសាសនាថេរវាទបានរីកចំរើនយ៉ាងខ្លាំងក្នុងប្រទេសខ្មែរដែល មិនអាចនឹងមានសាសនាណាដទៃ ចូលមកផ្សព្វផ្សាយយកជ័យជំនះបាន ព្រោះពុទ្ធសាសនាថេរវាទ បានចាក់ឫសយ៉ាងក្នុងសង្គមនិងចិត្តគំនិតខ្មែរផុតការរង្គើទៅហើយ សឹងមានពុទ្ធិកមហាវិទ្យាល័យ, ពុទ្ធិកវិ-ទ្យាល័យ សាលាពុទ្ធិកបឋមសិក្សា និងវត្តអារាមគ្រប់ភូមិស្រុកនិងក្រុងជាក់ស្តែង ។ ក្នុងច្បាប់រដ្ឋធម្មនុញ្ញ រដ្ឋបានបញ្ចូលព្រះពុទ្ធសាសនាទៅជាសាសនារបស់រដ្ឋថែមទៀត ។

## គ- សិល្បៈខ្មែរបែបពុទ្ធនិយម

### ១- រូបបដិមា.-

ក- ពុទ្ធរូប.- ពុទ្ធរូបខ្មែរមាន ១០ យ៉ាងដែលហៅថា មុទ្រ ៖ គឺ ៖

១- សមាធិមុទ្រ ឬឈានមុទ្រ.- ទ្រង់គង់ពត់ព្រះភ្នែន ព្រះហស្តផ្ងារជាន់គ្នាលើគ្នា លើព្រះភ្នែន ។

២- ភូមិសប៉ីមុទ្រ.- ទ្រង់គង់ពត់ព្រះភ្នែនព្រះហស្តស្តាំដាក់ លើព្រះបាទស្តាំ ចុងព្រះហស្ត (ម្រាម ១) ដូចជាចង្អុលទៅរកដី ព្រះហស្តឆ្វេងដាក់ផ្ងារលើព្រះភ្នែន ។

៣- អភយមុទ្រ.- ទ្រង់ឈរលើកព្រះហស្តទាំងពីរក ចុងព្រះហស្តឡើងជា សញ្ញានៃការប្រទានអភ័យចំពោះសព្វសត្វ ។

៤- ធម្មចក្រមុទ្រ.- ទ្រង់គង់ពត់ព្រះភ្នែនលើកព្រះហស្តទាំងពីរ លាបាតព្រះហស្តស្តាំមកក្រៅ ឆ្វេងចូលក្នុងធ្វើដូចជាកង់ចក្រសញ្ញាធម្មចក្រ ។

៥- បាតទានមុទ្រ.- ទ្រង់គង់ឬឈរ (ច្រើនឈរ) ព្រះហស្តទាំងពីរទេបបាត្រ ។

៦- វរមុទ្រ.- ទ្រង់ប្រថាប់ឈរលាព្រះហស្តទាំងពីរទៅមុខ ចុងម្រាមសំយុងរកដី ។

៧- វិតក្កមុទ្រ.- ទ្រង់ប្រថាប់ឈរលាព្រះហស្តទាំងពីរទៅមុខ តាំងព្រះហស្តបង់មកក្នុង ចំនឹងមេព្រះហស្ត ជារង្វង់ ។

៨– ទុក្ករកិរិយាមុទ្រ.– ទ្រង់គង់ពត់ព្រះភ្លៅខ្ជុំ មានញើសស្រក់ពីព្រះកាយ ហើយរាងព្រះកាយស្គាំងស្គម ។

៩– ប្រក់នាគ.– ទ្រង់គង់ដូចសមាធិមុទ្រ មាននាគពែនខ្លួនធ្វើជាបល្ល័ង្ក បើកពារបាំងពីលើ ។

១០– និព្វានមុទ្រ ឬ សយនាមុទ្រ.– រូបផ្ទំផ្ទៀងទៅខាងស្ដាំ ព្រះហស្តស្ដាំទ្រព្រះកេស ព្រះហស្តឆ្វេងសណ្ដូកលើព្រះកាយ ។

ព្រះពុទ្ធរូបប្រក់នាគ ជាពុទ្ធរូបបែបខ្មែរសុទ្ធសាធ ព្រោះមាននៅក្នុងទេសខ្មែរ មុនទេសឯទៀតៗ ។

ព្រះពុទ្ធរូបក្នុងសិល្បៈខ្មែរ មានលក្ខណៈគួរកត់សំគាល់ច្រើនបែបគឺ :

– ទ្រង់គង់ពត់ភ្លៅលើបល្ល័ង្ក ឬ លើរនោងមានផ្កាឈូកទ្រ ហើយឃុំ ឬ គ្រង់ចីពរ ។

– ព្រះពុទ្ធរូបអង្គខ្លះមានទ្រង់គ្រឿងថែមទៀត ។

– មានព្រះមោលីតូច (ទាល ឬ ស្រួច) នៅលើព្រះសិរ ។

– ព្រះកេសារួញខ្មៅ ប្រទក្សិណព្រះកេស ឬ ជាបន្ទាទ្វា ។

– មានព្រះភមុខ្មៅផុសទៅប្រជុំចិញ្ចើម ។

– ព្រះកាណ៌វែងជិតធ្លាក់ដល់ស្មា ។

– ព្រះទស្សន៍បែបញញឹម ។

ក្នុងគំនូរ - ចម្លាក់

– រូបប្រសូត មានព្រះនាងសិរីមហាមាយាឈរទាញមែកសាលព្រឹក្ស, ព្រះសិទ្ធត្ថទ្រង់ឈានបាន ៧ ជំហានលើផ្កាឈូក លើកព្រះហស្តស្ដាំឡើងលើមានទេវៈបាំងក្លស់ ។

– រូបកុមារវ័យ៖ គង់ឈរលើព្រះកេសកាឡុងទៅលឬគង់សមាធិក្រោមរុក្ខជាតិ ពេលព្រះបិតានាំទៅច្រត់ព្រះនង្គ័ល ។

– រូបជួបនិមិត្តទាំង ៤: ចាស់ - ឈឺ, ស្លាប់, អ្នកបួស ។

- រូបចេញសាងព្រះផ្នួស (ចេញបួស) តែងតែមានសេះកណ្ឋកៈនិងឆន្នអាមាត្យជាមួយ ។
- រូបកំពុងសាងផ្នួស (សំរាន់កាត់ព្រះកេសា) ។
- រូបធ្វើទុក្ករកិរិយា ។
- រូបទទួលមធុបាយាសពីនាងសុជាតា នៅថ្ងៃត្រាស់ដឹង ។
- រូបផ្ចាញ់មារ ។
- រូបត្រាស់ដឹងក្រោមពោធិព្រឹក្ស ។
- រូបសំដែងធម្មចក្រ មានបញ្ចវគ្គិយនៅជុំវិញ ។
- រូបសំដែងទុកភពចងគតិមាតុទៅតាវត្តិង្ស ។
- រូបសំដែងព្រះអភិធម្មប្រោសមាតា ។
- រូបចុះពីស្ថានត្រៃត្រិង្ស ។
- រូបប្រោសពុទ្ធបិតា ។
- រូបបរិនិព្វានក្រោមដើមសាលព្រឹក្ស ។ល។ និង ។ល។

ខ– ព្រះចេតិយ - ព្រះស្តូប .– ព្រះស្តូបកន្ទូល (ដូចផ្កាកក្តាប់) ឯព្រះចេតិយកន្ទូចអគារប្រាង មានគ្រាប់របស់ទីសំរាប់តម្កល់ធាតុ ឬព្រះសារីរិកធាតុ, អរហន្តធាតុ ។ ព្រះចេតិយមាន ៤ បែបគឺ:

១– ធាតុចេតិយ.– សំរាប់ដាក់ធាតុ ។

២– បរិភោគចេតិយ.– សំរាប់ដាក់គ្រឿងប្រើប្រាស់ មានបាត្រចីវររបស់ព្រះពុទ្ធ ។

៣– ធម្មចេតិយ.– សម្រាប់តំកល់ក្បួនខ្នាតគម្ពីរដីកា ដូចជាធម្មមន្ទីរ, ហោត្រៃយ ជាដើម ។

៤– ឧទ្ទេសិកចេតិយ.– ដែលសម្រាប់ទុកសក្ការៈព្រះពុទ្ធ ឬពុទ្ធរូបផ្សេងៗ ។

គ– ព្រះវិហារ.– ជាអគារសំរាប់តំកល់ព្រះពុទ្ធរូបនិងសំរាប់ព្រះសង្ឃធ្វើបោសថកម្ម, សង្ឃកម្មផ្សេងៗ ព្រមទាំងសម្រាប់ពួកពុទ្ធបរិស័ទធ្វើបុណ្យទានផ្សេងៗផង ។

ព្រះវិហារនៅតែឋិតនៅកណ្ដាលឬផ្នែកមុខបន្តិចនៃវត្ត មានដំបូលពីរឬបីជាន់មានកំពូលស្រួច ។ បែរមុខទៅទិសកើតជានិច្ច ។ (លើកលែងតែវិហារលើភ្នំដូចវត្តភ្នំពេញ ដែលបែរមុខទៅជើងតាមដំណើរផ្លូវ ១) ។

ឃ- ប្រាសាទ.– គេច្រើនសង់ប្រាសាទថែបញ្ចុះខ្មោចនៅលើដីកប់ដូចប្រាសាទក្នុងរបាបាយ័ន មានប្រាសាទបាយ័ន, តាព្រហ្ម, បន្ទាយក្ដី, ព្រះខ័នជាដើម ។

ង- ពោធិសត្វរូប.– រូបព្រះពោធិសត្វមាន ២ បែប :

១-បែបមហាយាន.– ក្នុងលទ្ធិមហាយានគេតែងគោរពពោធិសត្វ ៣ អង្គគឺ:

ក- អវលោកេស្វរ ឬ អវលោកិតេស្វរៈ.– រូបគង់ឬឈរ លើផ្កាឈូក មានព្រះសិរមួយ ឬច្រើនត្រួតៗលើគ្នា : មានកាន់គ្រឿងសំគាល់គឺ : គម្ពីរ, ខ្សែផ្កា, ផាស, ផ្កាឈូក, ដបទឹកកុណ្ឌី ។

ចំណាំ.– ក្នុងរបាបាយ័ន មានប្រាសាទបាយ័នជាគោលសំខាន់ ព្រះពោធិសត្វអវលោកិតេស្វរ មានព្រះភក្ត្រ ៤ ហើយគឺជាតួអង្គព្រះជ័យវរ្ម័នទី ៧ នេះតែម្ដង បានសេចក្ដីថា ព្រះបាទជ័យវរ្ម័នទី ៧ ជាព្រះពោធិសត្វអវលោកិតេស្វរៈ ។

ខ- មៃត្រីយ.– រូបគង់ពត់ភ្លៅ ដូចព្រះពុទ្ធក្នុងបែបសមាធិមុទ្រ តែមានពាក់មកុដ និងគ្រឿងអលង្ការ ។ ខ្លះថាជារូបព្រះគោតម កាលនៅជាពោធិសត្វ ។ តែខ្លះថាជាព្រះសិ-អារ្យមេត្រៃ ។

ចំណែកព្រះពោធិសត្វមញ្ជុស្រី មិនសូវមានក្នុងបែបនេះទេ ។ ព្រះពោធិសត្វអវលោ-កិតេស្វរៈទើបតែគេធ្វើច្រើន ។

២-បែបហីនយាន.– ក្នុងលទ្ធិហីនយានមិនសូវមានឃើញរូបពោធិសត្វទេ ព្រោះខ្មែរមិនសូវគោរពពោធិសត្វទេ គឺគោរពតែព្រះពុទ្ធនិងព្រះធម៌តាមបែបដើមតែម្ដង ។

ទេវរូប – ទេវរូបជាទេវបុត្ត ឬទេវតាមានគ្រឿងអលង្ការ, ច្រើនជារូបទេពអប្សរៈ

# អក្សរសិល្ប៍ខ្មែរបែបពុទ្ធនិយម

អក្សរសិល្ប៍បែបពុទ្ធនិយម ជាអត្ថបទរឿងរ៉ាវផ្សេងៗ ដែលតែងនិ[illegible]ង ដោយលើកយកទ្រឹស្ដីក្នុងពុទ្ធលទ្ធិមកធ្វើជាគោល ហើយទ្រឹស្ដីទាំងនោះ ស្ថិតនៅក្នុងព្រះត្រៃបិដកនៃ. ជាពុទ្ធវចនៈសុទ្ធសាធ ។ ប៉ុន្តែអក្សរសិល្ប៍ក្នុងពុទ្ធនិយមនេះមាន ២ ប្រភេទគឺ :

## ១- អក្សរសិល្ប៍ខ្មែរបែបពុទ្ធនិយមពិតៗ.–

សំដៅយកអក្សរសិល្ប៍ខ្មែរ ដែលនិយាយពីការសាងបារមីនៃព្រះពោធិសត្វដោយត្រឹមត្រូវ បានដល់ទសជាតកគឺ:

| | | |
|---|---|---|
| – តេមិយជាតក | សាង | នេក្ខម្មបារមី |
| – ជនកជាតក | „ | វីរិយបារមី |
| – សុវណ្ណសាមជាតក | „ | មេត្តាបារមី |
| – នេមិរាជជាតក | „ | អធិដ្ឋានបារមី |
| – មហោសថជាតក | „ | បញ្ញាបារមី |
| – ភូរិទត្តជាតក | „ | សីលបារមី |
| – ចន្ទកុមារជាតក | „ | ខន្តិបារមី |
| – នារទជាតក | „ | ឧបេក្ខាបារមី |
| – វិធុរជាតក | „ | សច្ចបារមី |
| – វេស្សន្តរជាតក | „ | ទានបារមី |

## ២- អក្សរសិល្ប៍ខ្មែរបែបពុទ្ធនិយមក្លែងក្លាយ.–

សំដៅយកអក្សរសិល្ប៍ខ្មែរមួយប្រភេទដែលជាសាស្ត្រាល្បែងមានបញ្ញាសជាតក, ដែលនិពន្ធដោយព្រះសង្ឃលាវនៅឈៀងម៉ៃ ហើយបានប្រែដោយអ្នកនិពន្ធខ្មែរជាកំណាព្យខ្មែរ ដូចរឿងព្រះសុធន, ក្រុងសុភមិត្រ គោតកុលកុមារជាដើម ។ មានរឿងពុទ្ធនិយមក្លែងក្លាយមួយបែបទៀត ពុំមានលក្ខណៈជាពុទ្ធនិយមសោះ ប៉ុន្តែអ្នកនិពន្ធបានដាក់ក្នុងគន្លងជាពោធិសត្វដែរ ដូចរឿងកាកី, ហង្សយន្ត, ខ្យងសង្ខ, សព្វសិទ្ធិជាដើម ។

## លក្ខណៈនិពន្ធអក្សរសិល្ប៍ខ្មែរបែបពុទ្ធនិយម

១– ផ្តើមរឿង.– មានធ្វើបទនមស្ការព្រះរតនត្រ័យជាមុន ។

២– សាច់រឿង.–

ក– តួអង្គ.– ប្រុសជាពោធិសត្វ, ស្រីជាកញ្ញាសារទេព្វ ។ តួរាយរង មាន មនុស្ស, ទេវៈ, អសុរ ។

ខ– ទីកន្លែង.– នគរពារាណសី, សាវត្ថី, រាជគ្រឹះ, តក្កសិលា, ព្រៃហេមពាន្ត ។ល។

គ– បញ្ហាចោទ.– ជាទំនាស់រវាងព្រះពោធិសត្វនិងសង្គមមនុស្ស, ទំនៀមទំលាប់, តម្មរៀរ ។

ឃ– បញ្ហាដោះស្រាយ.– ព្យាយាមតស៊ូប្រឹងប្រែង និងយកសីលធម៌ទៅអប់រំ ដោយសន្តិវិធី ។

ង– ស្នេហា.– គឺស្នេហារវាងពោធិសត្វ និង បារមី, ពោធិសត្វ និង កញ្ញាសារទេព្វ ជាស្នេហាបរិសុទ្ធ ។

ច– កំសត់.– កើតឡើងដោយការព្រាត់ប្រាស ព្រោះសង្គមមនុស្ស - ទំនៀមទម្លាប់ - ពៀរវេរា ។

ឆ– ឧត្តមគតិ.– អប់រំមនុស្សឲ្យស្គាល់បុណ្យបាប, ឲ្យធ្វើល្អ, ឲ្យប្រឹងតស៊ូព្យាយាម ។

៣– បញ្ចប់រឿង.– មានការសរជាតិ គឺតួអង្គល្អ ជាពោធិសត្វនិងកញ្ញាសារទេព្វ ឯតួអង្គអាក្រក់ជាទេវទត្ត, នាងចិញ្ចា ។ល។

## ប្រពៃណី-ទំនៀមទម្លាប់ខ្មែរបែបពុទ្ធនិយម

លទ្ធិពុទ្ធនិយមបានជ្រួតជ្រាប ចាក់ឫសយ៉ាងជ្រៅណាស់មកក្នុងប្រពៃណី - ទំនៀមខ្មែរ ។ នៅក្នុងពិធីផ្សេងៗ ដែលជាប្រពៃណីខ្មែរ ដូចប្រកាន់ប្រសិទ្ធិការផ្តុកកូន, ឡើងផ្ទះ,

ចេញម្លប់កូនស្រី, រៀបអាពាហ៍ពិពាហ៍កូនប្រុសស្រី, ឡើងអ្នកតា, ចូលឆ្នាំថ្មី ជាដើម ប្រជាជនខ្មែរ តែងប្រារព្ធធ្វើដោយយកពិធីក្នុងនិយមមកធ្វើជាមួយផងគឺ និមន្តព្រះសង្ឃចំរើនព្រះបរិត្ត បាចទឹករំលាប់ចង្រៃ, ទេសនាក្នុងពេលយប់ ព្រឹកឡើងនិមន្តព្រះសង្ឃបិណ្ឌបាត្រ, ទទួលភត្ត ។

បើក្នុងពិធីបុណ្យ ជាប្រពៃណីក្នុងព្រះពុទ្ធសាសនា ដូចបុណ្យចូលវស្សា, ចេញវស្សា, កឋិនទាន, មាឃបូជា, វិសាខបូជា ជាដើម ខ្មែរបានធ្វើទៅតាមទំនៀមទម្លាប់របស់ខ្លួនដោយមានបញ្ចូលការកំសាន្តសប្បាយជាមួយផង ។

ឯចំពោះ ក្នុងពិធីបុណ្យអភិសេក, លើកសព, បូជាសព, ឆាក, បំសុកូល, វេរភត្ត, កតញ្ញូ, បច្ច័យ ៤ ជាដើម ខ្មែរបានធ្វើតាមទំនៀមទម្លាប់ផង តាមប្រពៃណីព្រះពុទ្ធសាសនាផង (ហើយពិធីខ្លះបានយកលទ្ធិព្រាហ្មណ៍មកបញ្ចូលជាមួយផង) ។

## វប្បធម៌ខ្មែរផ្នែកភាសា-ពាក្យពេចន៍ក្នុងព្រាហ្មណ៍និយមនិងពុទ្ធនិយម

តាមរយៈសាសនាពីរគឺ សាសនាព្រាហ្មណ៍និងពុទ្ធសាសនា ដែលឥណ្ឌាបានផ្សាយមកក្នុងសង្គមខ្មែរ ខ្មែរបានទទួលវប្បធម៌ផ្នែកភាសា - ពាក្យពេចន៍ពីរបែបគឺ:

**១- ភាសាសំស្ក្រឹត.–** ក្នុងអក្សរសិល្ប៍បែបព្រាហ្មណ៍និយម ខ្មែរមានប្រើភាសាសំស្ក្រឹតយ៉ាងច្រើន ។ ក្នុងសិលាចារឹក នៅសម័យដែលសាសនាព្រាហ្មណ៍លូតលាស់ខ្លាំង (ពីសតវត្សទី ៤ ដល់ទី ១៣) មានចារជាភាសាខ្មែរបុរាណផង ភាសាសំស្ក្រឹតផង ហើយភាសាផ្ទុំការនឹកាសាសំស្ក្រឹត ។

**២- ភាសាបាលី.–** ក្នុងអក្សរសិល្ប៍ខ្មែរបែបពុទ្ធនិយម មានប្រើភាសាបាលីយ៉ាងច្រើន ។ ឯចំពីព្រះត្រៃបិដក គេឃើញមាននៅក្នុងអត្ថបទផ្សេងៗ ជាអត្ថកថា ឬ ជារឿងកំរជាភាសាខ្មែរ មានពាក្យបាលីយ៉ាងច្រើនទៅពាសពេញ លាយឡំនឹងភាសាខ្មែរ ហើយភាសាបាលី ខ្មែរទុកជាភាសាសំខាន់ក្នុងសតវត្សទី ១៣ ដល់សព្វថ្ងៃ ។

### យោបល់រួមចំពោះលទ្ធិពុទ្ធនិយម.–

រួមមកហើយនេះ យើងបានឃើញថាលទ្ធិពុទ្ធនិយម បានជ្រួតជ្រាបចាក់ឫសគល់យ៉ាងខ្លាំង

ចាកពីវប្បធម៌ខ្មែរ ហើយសន្ទុះនៃកម្លាំងនេះ បានដោតជាប់ក្នុងចិត្តគំនិតខ្មែរ ៩៩ ភាគរយថែមទៀត ដែលមិនអាចនឹងទាញផ្ដាច់ពីផលនៃសាសនា ឬ លទ្ធិណាមកប្រណាំងប្រជែងបានឡើយ ។ ខ្មែរបានយកព្រះពុទ្ធសាសនា ដ៏មានសរណៈ ៣ គឺ: ព្រះពុទ្ធ, ព្រះធម៌, ព្រះសង្ឃ ទុកជាទីពឹង រំលឹកស្មើជីវិត ។

## ខ្មែរនិយម

ចំពោះបញ្ហាខ្មែរនិយម ក្នុងវិជ្ជានៃខ្លួនជាខ្មែរស្រេចទៅហើយនេះ យើងអាចមើលឃើញដោយខ្លួនឯងបានគឺ:

**១– សង្គមកិច្ច.–** ខ្មែរបានរៀបចំសង្គមកិច្ច ស្របទៅតាមពុទ្ធលទ្ធិដោយច្រើន ដែលមានលក្ខណៈជាការសម្រេចតាមបែបមនុស្សធម៌. តាមបែបបែកខាង និងតាមចំណង់ចិត្ត ។

**២– សិល្បៈ.–** ក្នុងផ្នែកសិល្បៈ (ក្បាច់រាំក្បាច់ចេតា, តន្ត្រី, របាំ, ចម្រៀង) ខ្មែរមានលក្ខណៈមួយសម្រាប់ជាតិខ្លួន គ្រប់សិល្បៈមានបែបទន់ភ្លន់ មានដើម, កណ្ដាលនិងចុង ។ ក្នុងសិល្បៈចម្លាក់ ចាប់ពីបុរាណព្រះគោមក ខ្មែរមានលក្ខណៈមួយដោយឡែក គ្រប់ការពណ៌ល្អស ល្អន់ ហើយរឹងមាំរបស់ខ្មែរ លើថ្មនិងក្នុងប្រាសាទបុរាណ គឺជាការញញឹមព្រាយ ហើយមានជម្រៅ វិចិត្រស័យដ៏ខ្ពស់បំផុត ។ រហូតមកដល់បច្ចុប្បន្នកាល សិល្បៈខ្មែរគ្រប់ផ្នែក នៅតែរក្សាលក្ខណៈខ្មែរប្រពៃណីជាតិមួយ មានរបៀបនិងគំនិតខ្ពស់ជានិច្ច ។

**៣– អក្សរសិល្ប៍.–** អក្សរចូលចិត្តតែរឿង ដែលជាអស្ចារ្យ, ផុតពិស្ម័យមនុស្ស, អាទិទេព ឯអក្សរសិល្ប៍ខ្មែរ បានការបំបែកអស្ចារ្យ ផុតពិស្ម័យ-អាទិទេពនេះ មកជាបច្ចុប្បន្នភាពទៅវិញ ដូចក្នុងច្បាប់ផ្សេងៗ ខ្មែរតែងតែចូលនាំអប់រំគុណជនខ្លួន ឲ្យច្រើនប្រែងធ្វើការតាមគន្លងបច្ចុប្បន្ន ដើម្បីប្រយោជន៍បច្ចុប្បន្ន ឃើញជាក់ស្ដែងនឹងភ្នែក ។ ក្នុងពាក្យខ្មែរសាមញ្ញ ខ្មែរនិយាយថា «កើស៊ី» ជាការបញ្ជាក់ថា ខ្មែរចូលចិត្តតែរឿងដែលងាយ-ជាក់ស្ដែងក្ដាមៗ ។

ទៅក្នុងរឿងរាមកេរ្ដិ៍ខ្មែរ, មហាវេស្សន្ដរជាតកបែបខ្មែរ ខ្មែរច្រើនទាញទេវភាព ពោធិសត្វភាព របស់ព្រះរាម-ព្រះវេស្សន្ដរពីអាទិទេព, ពោធិសត្វអ្នកប្រាជ្ញាមិត្តាន មកជាមនុស្ស

សាបញ្ញ ជាមនុស្សរស់នៅដោយភាពការុញ្ញភាព, ភក្ដី, ឯកភាព ដែលចេះស្រឡាញ់ប្រពន្ធកូន, ដែលជាប្រទេសចំណូល, មានកំហឹង ហើយក្រុមប្រយោជន៍របស់បុគ្គលជាសុខសុភមង្គលថែមទៀត ។ ឧទាហរណ៍ព្រះរាមប្រចាំណាទាំងសិក ហើយឱ្យព្រះលក្ស្មណ៍យកនាងសីតាទៅចោល, ព្រះរាមមិនស្គាល់ខ្លួនឯង; ព្រះវេស្សន្តរប្រទានបុត្រាបុត្រីទៅតាមចិត្តហើយ កាលឃើញខ្លួនតកងដកូន ក៏មិនកោតខ្លួន, ព្រះវេស្សន្តរសុំភរិយាព្រះឥន្ទ្រ ដើម្បីបានទៅសោយនគរសម្បត្តិវិញជាដើម ។

**៣- កិច្ចប្រតិបត្តិ-ជំនឿ.–** ខ្មែរមានការប្រតិបត្តិពិធីផ្សេងៗច្រើន, មានជំនឿជាបេះបៀតក្តី គឺជឿដោយស្រឡាញ់ដូនតាជំនុំ ចំណែកខ្មែរមានការប្រតិបត្តិស្របតាមនិស្ស័យលក្ខណៈខ្លួនឯង តាមកិរិតជីវភាព (ប្រតិបត្តិក្នុងជីវភាព–កាន់បុណ្យវង្ស សេដ្ឋកិច្ច) ហើយជឿតាមមើល [illegible] តាមការពិចារណា ហើយមានលក្ខណៈជាលោកិយសម្បូរណ៍ថែមទៀត ។

**៤– និតិចិត្ត.–** វិតចិត្តខ្មែរក្នុងសម័យ ពីដើមមកហេតុ គ្មានលទ្ធិព្រាហ្មណ៍ដូចពុទ្ធ-លទ្ធិ ឯខ្មែរមានទឹកចិត្តផ្ទៃមួយ ចង់ ប្រើសិរីល្អមានវែបជា „សម្របនិយម„ តាមកាលៈទេសៈ តាមសន្តិមហាវិយោគសៈ ។ល។

រួមទាំងអស់នេះមក ចរិតខ្មែរ ស្ថិតនៅលើលោកិយនិយមផង លើមនុស្សនិយមផង ក៏ប៉ុន្តែដោយកំពូលលក្ខណៈជាលោកិយទន្ទឹមខ្លួន ដែលអាចមើលឃើញ ហើយតែងតែខ្លួនខ្មែរនៅលើសមត្ថភាពមនុស្សទាំងអស់ បញ្ហាព្រហ្មញ្ញ ស្តិតិភាព ជាបញ្ហាទី ២ ឬ បញ្ហាប្រយោល ឯការលោកិយ ជាបែបមនុស្សនិយម គឺជាបញ្ហាទី១ ហើយជាបញ្ហាផ្ទាល់ ។

## បរទេសនិយម

ចាប់តាំងពីពេលណា ខ្មែរបានទទួលឥទ្ធិពលនៃវប្បធម៌ និងមួយទៀតពីភូគព្ភ គឺគតិការផ្តួចផ្តើម ជាពិសេសពីភូមិភាគ ដែលខ្លួនមកសមាគមខ្មែរត្រឹមតែកណ្តាលពិភព ។ ពីសម័យមុនខ្មែរមានគតិការផ្តួចផ្តើមកុលាភាពពិត ប៉ុន្តែជាបរទេសរាល់ [illegible] បានចូលមកមានការទាក់ទងជាមួយខ្មែរ ១ បានរៀបចំគតិការ ៣ ស្របទៅតាមបរទេសនិយមគឺ ៖

**១– អង្គការនីតិបញ្ញត្តិ.–** ខ្មែរបានរៀបចំតាក់តែងជាក្រុម , [illegible]

គំណោះនីកស្ត្រ ។ មានគណៈបក្ស , មានរដ្ឋសភា តាមលទ្ធិប្រជាធិបតេយ្យ ។

២- អង្គការនីតិប្រតិបត្តិ.- មានការរៀបចំរដ្ឋាភិបាល ដោយមានគណៈរដ្ឋមន្ត្រី ទទួលខុសត្រូវអំណាចពីរដ្ឋសភាមកបាត់តែងការងារតាមក្រសួង ។

៣- អង្គការតុលាការ.- ខ្មែរបានរៀបចំតុលាការតាមបែបសម័យថ្មី តែក្នុងនាមនៃព្រះមហាក្សត្រ ។

ដរែចពីវប្បធម៌ទាំង ៣ ដំណាក់ៗ សំខាន់រដ្ឋបាលនេះ ខ្មែរបានទទួលការបោះជំហានផ្សេងៗ ចំរើន ជាពិសេសវិទ្យាសាស្ត្រ សម័យទំនើប ។

## ៣- យោបល់បញ្ចប់

### តម្លៃនៃវប្បធម៌ខ្មែរក្នុងក្របខ័ណ្ឌអរិយធម៌ពិភពលោក

ជាការពិតមួយដែលគេប្រាកដបាន ខ្មែរមានវប្បធម៌មួយសំខាន់ជាតិសាសន៍ ដែលកើត [illegible] ដោយផលនៃគំនិត និងជំនឿរបស់ខ្លួនពីដីពុំប្រៀបផ្ទឹមសាស្ត្រមកម្ទេះ ហើយតមក ខ្មែរបានទទួលវប្បធម៌ឥណ្ឌាតែ តាមរយៈសាសនាព្រាហ្មណ៍ និងពុទ្ធសាសនាថែមទៀត ដោយ វប្បធម៌នេះបានជះឥទ្ធិពលលើសង្គមខ្មែរក្នុងគ្រប់វិស័យ និងរក្សាវប្បធម៌ឥណ្ឌា មានលក្ខណៈ ប្រែប្រួលយ៉ាងច្រើនក្នុងចិត្តខ្មែរដែលខ្មែរបានទទួលយកបានដែរ ប៉ុន្តែទោះយ៉ាងនេះក្តី គឺខ្មែរពុំបានទុក [illegible] ។ [illegible] , រូបរាងនៃវប្បធម៌ឥណ្ឌាពីដើមនៅក្នុងវប្បធម៌ខ្មែរ គឺ ខ្មែរបានផ្លាស់ប្តូរវប្បធម៌ឥណ្ឌាឲ្យមានលក្ខណៈជាខ្មែរស្របតាមបំណងចិត្តរបស់ខ្លួនទាំង [illegible] ខាងសាសនា , សិល្បៈ, អក្សរសិល្ប៍, ប្រពៃណី ទំនៀមទំលាប់, ភាសា និងផ្សេងៗ ទៀត តែវប្បធម៌ឥណ្ឌាបិទបាំងវប្បធម៌ខ្មែរទេឡើយ ។

តាមធម្មតា វប្បធម៌នៃជនជាតិនីមួយៗ តែងតែផ្លាស់ប្តូរពីជាតិមួយទៅជាតិមួយជា [illegible] ដូចវប្បធម៌បារាំងដែរ បានទទួលឥទ្ធិពលពីខ្មែរ ហើយនៅស្ទើរតែទាំងអស់ ប៉ុន្តែជនជាតិថៃ បានកែប្រែវប្បធម៌នេះ ទៅតាមចំណាប់ចិត្តរបស់គេសរសេរ ។ វប្បធម៌ខ្មែរសម័យបុរាណនេះ បានឡើងកំពូលនៃភាពរុងរឿង ហើយវប្បធម៌នេះបានជះឥទ្ធិពលទៅលើប្រទេសជិតខាង

យ៉ាងទាំងថែមទៀតដូចលាវ, យួន , ឥណ្ឌូណេស៊ីជាដើម ។

នៅក្នុងក្របខ័ណ្ឌនៃអរិយធម៌ពិភពលោកវប្បធម៌ខ្មែរបានចាត់ទុកជាកេតនភណ្ឌមួយសម្រាប់មនុស្សជាតិផ្សេងទៀត ព្រោះដូចយ៉ាងអង្គរវត្តជាដើម មនុស្សក្នុងពិភពលោកតែងតែស្ងើចសរសើរនិងឲ្យតម្លៃដែលមិនអាចកាត់បាន: ពួកទេសចរ បានចំណាយប្រាក់យ៉ាងច្រើន ដើម្បីមកទស្សនាប្រាសាទអង្គរឲ្យបានឃើញផ្ទាល់ភ្នែក ។ ក្រៅពីនេះវប្បធម៌ផ្នែកសិល្បៈ, របាំ, ភ្លេង, អក្សរសិល្ប៍, សាសនា, ប្រពៃណី, ទំនៀមទំលាប់ និងផ្នែកផ្សេងៗ ទៀត ក៏លេចធ្លោមានតម្លៃក្នុងផ្នែកអន្តរជាតិដែរ ។

× × ×

# តែងសេចក្ដីគម្រូ

## សម្រាប់ថ្នាក់ធីបញ្ចប់

ប្រធានទី ១ .– បញ្ហាកើតស្លាប់នៃមនុស្សនៅក្នុងពុទ្ធនិយមនិងនៅក្នុងព្រាហ្មណ៍និយម ។

ប្រឡងមធ្យមសិក្សាបំប្រភាគទី២
ថ្ងៃ ២២ - ៦ - ៧១
ក្រុងស្នួវិជ្ជា

## អត្ថាធិប្បាយ

លទ្ធិពុទ្ធនិយមក៏ដូចលទ្ធិព្រាហ្មណ៍និយមដែរ សុទ្ធតែបានបញ្ចេញទស្សនៈទ្រឹស្ដីពន្យល់ដោះស្រាយនូវបញ្ហារបស់មនុស្ស ពិសេសគឺបញ្ហាកើតស្លាប់នេះជាដើម ។ ប៉ុន្តែតើបញ្ហាកើតស្លាប់នៅក្នុងពុទ្ធនិយមនិងក្នុងព្រាហ្មណ៍និយមមានលក្ខណៈស្របគ្នាដែរឬទេ ?

បញ្ហាកើតស្លាប់នៃមនុស្សដែលជាការៈនៅក្នុងលទ្ធិទាំងពីរ ត្រូវបានទទួលការ... ដូចគ្នាឡើយ ។ យ៉ាងណាមិញ :

ក– បញ្ហាកើតស្លាប់ក្នុងពុទ្ធនិយម.– ការៈទាំងអស់សុទ្ធតែរួមផ្សំឡើងពីធាតុ បរមាណូធាតុ គឺកើតដោយទឹកដីភ្លើងខ្យល់ហើយធាតុទាំង ៤ នេះផ្សំគ្នាកើតជាធម្មជាតិ : មនុស្ស , សត្វ-រុក្ខជាតិ , ។ល។ ផ្សេង ៗ ទៀត គ្មានការៈណាកើតដោយគ្មានការផ្សំធាតុនោះឡើយ ។ ធម្មជាតិមានមនុស្សជាដើមនេះ គឺជាផលនៃសង្ខតធាតុ មានរូប , វេទនា , សញ្ញា , សង្ខារ , វិញ្ញាណដែលជាខន្ធ ៥ នេះឯង ។

សង្ខតធាតុទាំងអស់នេះ កាលណាមានហើយក៏តែងស្ថិតនៅក្នុងកំណាត់នៃបច្ច័យធម្មជាតិ លក្ខណៈទូទៅ ៣ យ៉ាងគឺ អនិច្ចំ , ទុក្ខំ , អនត្តាដែលជាសភាពមិនទៀង , ជាទុក្ខ មិនមែនរបស់ជាខ្លួនប្រាណហ្នឹងឯង មាននៅតែព្រះនិព្វានមួយប៉ុណ្ណោះ ដែលមិនស្ថិតនៅក្នុងវដ្ដកាលនៃបច្ច័យធម្មជាតិ ។ ការបែកធ្លាយនៃខន្ធនេះហៅថា ស្លាប់ ។ កាលណាមានខន្ធដោយការប្រែប្រួលនៃ...ធាតុហើយ ក៏តែងតែបែកធ្លាយទៅវិញជានិច្ច ។ ដរាបណានៅមានកិលេសតណ្ហាដែលធាតុ

តាមតាក់តែងពុំមាន ផលបរលោះ តែងតែមានបញ្ហាកើតស្លាប់នេះជាដរាប ។

ខ– បញ្ហាកើតស្លាប់ក្នុងព្រាហ្មណ៍និយម .– ផ្ទុយទៅវិញ នៅក្នុងព្រាហ្មណ៍និយម, ការរស់នៅកើតដោយសារធាតុទឹកដី, ភ្លើងខ្យល់ និងអាត្មន័ទៅវិញ ។ ការរស់ មនុស្ស, សត្វ ដែលជាទឹកដី ភ្លើងខ្យល់នេះ ជាអនិច្ច តែងប្រែក្លាយទៅ ប៉ុន្តែអាត្មន័ ដែល យើងហៅថាព្រលឹង ឬ ក្នុងពុទ្ធសាសនាហៅថា "វិញ្ញាណ" នោះ ពុំចេះប្រែក្លាយទេ ។ ការដែលជា សមូហភាពនៃទឹកដីភ្លើងខ្យល់នេះ ជាអំណោយនៃអាទិទេព គឺសុទ្ធតែអាទិទេពបង្កើតឡើងទាំងអស់ ។

តាមទស្សនៈទាំងពីរខាងលើ យើងអាចយល់បានថា បញ្ហាកើតស្លាប់ក្នុងពុទ្ធសាសនាបាន ពន្យល់ថា ការរស់ជាសង្ខតធាតុ កាលណាកើតឡើងហើយ គឺតែងប្រែក្លាយរលត់ទៅវិញទាំងអស់ ទាំង វិញ្ញាណ ក៏រលត់ដែរ ឯក្នុងព្រាហ្មណ៍និយមវិញ បានពន្យល់ថា ការរស់ទាំងអស់ ក្រៅពីអាទិទេពនិង អាត្មន័ចេញ សុទ្ធតែអាទិទេពបង្កើត ហើយការរស់ទាំងនោះរមែងតែងតែប្រែក្លាយទៅ អាត្មន័ពុំ បានប្រែក្លាយទៅជាមួយឡើយ ។

ដូច្នេះចំពោះបញ្ហាកើតស្លាប់នេះ ពុំមានការស្របគ្នាទេ នៅក្នុងពុទ្ធនិយមនិងព្រាហ្មណ៍និយម ហើយតាមទស្សនៈព្រាហ្មណ៍និយម គេតែងជឿថាកាលណាមនុស្សស្លាប់ទៅ នៅសល់អាត្មន័ ឬព្រលឹងវិញ្ញាណនេះ ទៅលងញាតិធ្វើជាខ្មោចបិសាចតាមក្រោយឬទៅចាប់ជាតិកំណើតថ្មីទៀត ។

× × ×

ប្រធានទី ២.– ចូរធ្វើអត្ថាធិប្បាយ អំពីព្រះវិស្ណុនៅក្នុងសាសនាព្រាហ្មណ៍ ។ តាម ការអធិប្បាយរួចមកហើយនោះ តើសិស្សអ្នកយល់ថា អាទិទេពនៅក្នុងសាសនាព្រាហ្មណ៍ ពិតជាមានឥទ្ធិពល អាចផ្តល់ នូវសេចក្តីសុខ ឲ្យដល់មនុស្សបានដែរ ឬទេ ? ព្រោះអ្វី ?

ប្រឡងចម្លងសិក្សាប័ត្រភាគទី ២
ថ្ងៃ ២២ - ៦ - ១៩៧១
ផ្នែកវិទ្យាសាស្ត្រពិសោធន៍និងគណិតវិទ្យា

# អត្ថាធិប្បាយ

នៅក្នុងសាសនាព្រាហ្មណ៍ ព្រះវិស្ណុជាអាទិទេពមួយអង្គយ៉ាងសំខាន់ក្នុងចំណោមអាទិទេពទាំង៣អង្គ ។ ប៉ុន្តែតើអាទិទេព ដូចព្រះវិស្ណុជាដើមនេះ អាចផ្តល់សេចក្តីសុខឲ្យមនុស្សដែរ ឬ មិនអាចផ្តល់ទេ?

ព្រះវិស្ណុ ឬ ព្រះនារាយណ៍ ជាអ្នកថែរក្សាមនុស្សផង សត្វមនុស្សផង ។ ពួកប្រជាជនឥណ្ឌាភាគខាងត្បូងតែងគោរពព្រះវិស្ណុនេះណាស់ ព្រោះគេយល់ថា ព្រះវិស្ណុជាតំណាងផងជាតិមិលក្ខៈ ដែលជាម្ចាស់ដើមនៃទឹកដីឥណ្ឌា ។

ក្នុងលទ្ធិព្រាហ្មណ៍និយម ព្រះវិស្ណុមាននាទីជាអ្នកថែរក្សាគ្រប់គ្រងមនុ[illegible]លោក ហើយជាអ្នកផ្តល់សេចក្តីសុខឲ្យមនុស្សផង ។ យ៉ាងណាមិញ យើងបានឃើញហើយថា ព្រះវិស្ណុបានចែងការចុះមកយកកំណើតក្នុងមនុស្សលោកចំនួន ១០ លើកហៅថា ទសាវតារ ដើម្បីជួយស្រោចស្រង់ យិភរយាន រំដោះការពារមនុស្សលោកឲ្យរួចពីគ្រោះថ្នាក់ច្រើនយ៉ាង ។ នៅក្នុងសិល្បៈខ្មែរមានរូបមួយនៅក្នុងប្រាសាទមេបុណ្យខាងលិច (កណ្តាលបារាយណ៍ទឹកថ្លា) គឺរូបព្រះវិស្ណុផ្ទំផ្ទៀងដើម្បីគិតរំពឹងគមនោបាយថែរក្សាការពារមនុស្សលោក ។ ប៉ុន្តែ តើយើងអាចយល់បានថា តើអាទិទេពដូចយ៉ាងព្រះវិស្ណុនេះ អាចផ្តល់សេចក្តីសុខឲ្យមនុស្សបានមែនឬមិនបាន ?

តាមពិត យើងយល់ថាមិនបានទេហើយយើងមិនបាច់និយាយពីទ្រឹស្តីកម្មផល តាមពុ[illegible]ៈក្នុងលទ្ធិពុទ្ធសាសនាទេ យើងនិយាយតែតាមលទ្ធិអាត្មននិងកម្ម ក្នុងលទ្ធិព្រាហ្មណ៍និយមប៉ុណ្ណោះ ។ នៅក្នុងលទ្ធិព្រាហ្មណ៍ គេ[illegible]នពន្យល់ថា មនុស្សកើតឡើងដោយសារអាទិទេព កាលស្លាប់ទៅអាត្មនក៏ជាប់តាមទេ នឹងបើកាលធ្វើល្អអាត្មននឹងទៅជួបព្រហ្ម បានទទួលបរិបុណ្ណសុខ បើមិនបានធ្វើល្អមិនប្រព្រឹត្តធម៌ៈនិងយោគៈទេ អាត្មននឹងទទួលទុក្ខវិលវល់កើតស្លាប់ក្នុងសំសារៈនេះឯង ។ ក្នុងនាទីនេះ យើងយល់ថា បើរូបកាយនៃមនុស្សជាតំណាងនៃអាទិទេព, អាត្មនក៏ផ្តាច់ខ្លួនពី[illegible]អាទិទេពមករស់នៅជាមួយការៈជាមនុស្សល្អនេះដែរ ម្តេចក៏អាទិទេពមិនព្រមធ្វើការៈនោះឲ្យល្អ[illegible]ទៅ? ម្តេចក៏ទំបាច់ឲ្យមានអាក្រក់ ហើយផ្តល់សេចក្តីទុក្ខឲ្យការៈទៅវិញ? ហើយបើ[illegible] [illegible]អាទិទេព

ដ៏មុតមាំខ្ពង់ខ្ពស់ភាព អាចបង្កើតការៈបានដូច្នេះ ម្តេចក៏មិនផ្តល់សុខនៃសេចក្តីសុខឲ្យគេ ? ត្រង់ យើងរំលេចឃើញថា អាទិទេពគ្មានសមត្ថភាពអាចផ្តល់សេចក្តីសុខឲ្យមនុស្សទេឡើយ បើមានសមត្ថភាព ដូច្នោះមែន ការៈជារបស់ខ្លួនទៅហើយ មុខជាអាចផ្តល់សុខមិនខាន ដូចម្តាយឪពុកដែលមាន សមត្ថភាពបង្កើតកូនប្រុសស្រី ហើយពិតជាមានសមត្ថភាពស្តីប្រដៅ អប់រំ ការពារ មិនបណ្តោយឲ្យកូនធ្វើ អាក្រក់ឡើយ ។ ឯសមត្ថភាពអាទិទេព ក៏តែតែមានប្រសិទ្ធិភាពណាស់ទៅទៀត ។

ទោះបីអាទិទេព នៅក្នុងសាសនាព្រាហ្មណ៍មានតាទីជាអ្នកថែរក្សាលោកតាមទស្សនៈពួក ព្រាហ្មណ៍ បែបណាក៏ដោយ ក៏នៅក្នុងទស្សនៈខ្ញុំឯងដែលនេះ ពុំអាចដោះស្រាយបញ្ហាខ្លួនឯង រួច ត្រង់ឲ្យមានការៈផង មានកាត្តុផង ហើយបែរជាគ្មានអំណាចការពារគេ [illegible] ក្នុងនោះ ឲ្យ ប្រព្រឹត្តនៃអំពើល្អ ដើម្បីទៅជួបព្រហ្មវិញ និងទទួលបរមសុខ នោះឯង ។

\+ \+ \+

ប្រធានទី ៣.– គេថា វប្បធម៌ខ្មែរ គឺវប្បធម៌ឥណ្ឌា ។ ចំពោះគំនោលនេះ តើអ្នកមាន ទស្សនៈយ៉ាងណាដែរ ? ចូរធ្វើអត្ថាធិប្បាយ ។

សែម–ស្សូ

## អត្ថាធិប្បាយ

ខ្មែរពិតជាបានទទួលវប្បធម៌មួយផ្នែកធំពីឥណ្ឌាដោយឥតប្រកែកបាន ជាពិសេសគឺសាសនា, អក្សរសិល្ប៍, ភាសានេះឯង ។ ប៉ុន្តែតើការទទួលយកមកនេះ ខ្មែរចុះបេស់ឥណ្ឌា នោះឲ្យនៅជា លក្ខណៈឥណ្ឌាដាំងស្រុង ឬខ្មែរធ្វើជាទេវតាមយកមកឲ្យមានលក្ខណៈជាខ្មែរគេស់ទៅហើយ ?

យើងទទួលយកវប្បធម៌ឥណ្ឌាមកបញ្ចូលក្នុងវប្បធម៌យើងមែន ព្រោះវប្បធម៌នេះបូលមកស្រុក ខ្មែរយើងមុនគេ និងមានលក្ខណៈ ស្របស្រួលដែលខ្មែរអាចទទួលយកបានផង ។ ឧទាហរណ៍ៈ

– ក្នុងសិល្បៈ ខ្មែរទទួលយកតាមបែបឥណ្ឌាក្នុងសម័យមុនអង្គរ និងសម័យអន្តរៈ ដូចជា

ពោរគំនិតព្រហ្មញ្ញ , រូបចម្លាក់ ខាងគំនិតចាប់បង្កើត , ការសាងប្រាសាទ ដើម្បីទទួលបំពេ ចំពោះទេវតា ។ល។

– ក្នុងអក្សរសិល្ប៍ ខ្មែរទទួលយកតាមរយៈសាសនាពីរ គឺព្រាហ្មណ៍សាសនា និងពុទ្ធសាសនានូវអត្ថបទរឿងរាមកេរ្តិ៍ , មហាភារតយុទ្ធ , រាមាយណ , ទសជាតកជាដើម ទាំងឈ្មោះទីកន្លែងនិងភូមិភាគ និងគោលសំខាន់ ៗ ។

– ក្នុងភាសា គឺខ្មែរទទួលយកភាសាពីរគឺបាលី និងសំស្រ្កឹតផង ។

– ក្នុងសាសនា គឺខ្មែរទទួលយកពីឥណ្ឌានូវសាសនាពីរ គឺព្រាហ្មណ៍សាសនា និងពុទ្ធ-សាសនាផង ។

ប៉ុន្តែតើវប្បធម៌ទាំងអស់នេះ ដែលខ្មែរយកមកបញ្ចូលក្នុងវប្បធម៌របស់ខ្លួន តើខ្មែរទុកឲ្យនៅជាលក្ខណៈឥណ្ឌាទាំងស្រុងឬ ? តាមពិតខ្មែរទទួលយកពីឥណ្ឌាមែន តែខ្មែរបានបន្ថែមកែច្នៃឲ្យមានលក្ខណៈជាខ្មែរស្របតាមចំណោះចំណង់ចិត្តរបស់ខ្លួនអស់ទៅហើយ បានសេចក្តីថា ខ្មែរពុំបានទុកវប្បធម៌ឥណ្ឌាទាំងស្រុងឲ្យនៅក្នុងវប្បធម៌ខ្មែរទេ ។ យ៉ាងណាមិញ :

– ក្នុងសិល្បៈ រូបចម្លាក់ដែលកាប់ចម្លាក់ក្នុងសិល្បៈឥណ្ឌា ខ្មែរបានធ្វើឲ្យមានដងខ្លួនត្រង់ , ហើយប្រាសាទដែលគេសាងឡើងយកតាមទេពនោះ ខ្មែរបានធ្វើឲ្យនៅជាទីសក្ការបូជាសម្រាប់បុព្វបុរសទៅវិញ ដូចយ៉ាងប្រាសាទភ្នំបាខែង ខ្មែរសាងទុកជានិមិត្តរូបនៃភិភពលោកផង ទុកជានិមិត្តរូបនៃស្ពានក្រុងត្រីឡោកផង និងជាប្រក្រតិទិនប្រចាំឆ្នាំសំរាប់ខ្មែរផង ។ រូបៈពាក្យសព្ទការលោកកិតេស្វរៈ ខ្មែរធ្វើឲ្យមានមុខ ៤ តំណាងព្រះបាទជ័យវរ្ម័នទី ៧ ដែលបានព្រះហឫទ័យមើលទៅគ្រប់ទិសទាំង ៤ ចំពោះប្រជាពលរដ្ឋផង ។ មិនតែប៉ុណ្ណោះ ដូចយ៉ាងក្បាច់ចម្លាក់នានាក្នុងសិល្បៈខ្មែរដោយសុទ្ធសាធព្រោះក្នុងប្រទេសនេះ មាននៅតែក្នុងសិល្បៈខ្មែរតែប៉ុណ្ណោះ តែគ្មានក្នុងសិល្បៈឥណ្ឌាទេ ។

– ក្នុងអក្សរសិល្ប៍ ខ្មែរបានបង្កើតអក្សរសិល្ប៍ពីរឿងព្រាហ្មណ៍និយម និងពុទ្ធនិយមឲ្យមានលក្ខណៈជាខ្មែរទាំងអស់ គឺមានលក្ខណៈជាលោកិយនិយមផង ជាមនុស្សនិយមផង ដែលឲ្យស្ទួននៅលើផលប្រយោជន៍បុគ្គល និងឲ្យតម្លៃនៅលើសមត្ថភាពមនុស្ស ។

- ក្នុងភាសា ខ្មែរបានយកភាសាបាលី សំស្ក្រឹតមកប្រើផង តែបានធ្វើឲ្យទៅជាបែបខ្មែរ អស់ទៅហើយ ដូចពាក្យបុណ្យ, បាប, ប្រព្រឹត្ត, ព្រឹក្សព្រៃ, ព្រះរាជវាក្យជាដើម ។

- ក្នុងសាសនា ខ្មែរបានកែតែលក្ខណៈ នៃសាសនាព្រាហ្មណ៍ក៏ដូចក្នុងសាសនាពុទ្ធដែរ ឲ្យមានលក្ខណៈនៃការគោរពប្រតិបត្តិពិធីផ្សេងៗ ឲ្យមានលក្ខណៈជាខ្មែរ ស្របស្រួលទៅនឹងសន្តិម ចិត្តខ្មែរទាំងអស់ ។

វប្បធម៌ខ្មែរ ក៏ដូចវប្បធម៌នៃជនជាតិដទៃៗដែរ គឺជាផលនៃការប៉ះទង្គិចគ្នារវាងវប្បធម៌ ២ និងវប្បធម៌ទឹកចិត្តបំណាច់នៃជាតិ១ នេះឯង ហើយពេលណាជាតិ១ យកវប្បធម៌ជាតិ១ ទៅប្រើ ក៏តែងតែកែវប្បធម៌នោះ ឲ្យមានលក្ខណៈស្របតាមមនោសញ្ចេតនា របស់ខ្លួនជានិច្ច ។

ដូច្នេះ វប្បធម៌ខ្មែរមិនមែនជាវប្បធម៌ឥណ្ឌាទៀយ គឺប៉ុន្តែ ក៏ជាផលនៃការរាក់ទងនៃឥណ្ឌានិងខ្មែរ ព្រោះរូបសំណាកនីសម្លូសារៈរបស់ឥណ្ឌា បានបាត់បង់ស្ទើរតែអស់ទៅក្នុងវប្បធម៌ខ្មែរនេះទៅហើយ ។ ការបញ្ចូលគ្នានេះបានចេញជាផល ១ ទៀតគឺវប្បធម៌ខ្មែរនេះឯង ។

-ចប់-

ដំណឹងពិសេស

សូមប្អូនៗ រៀននៅថ្នាក់ទីបញ្ចប់ កុំភ្លេចសួររកទិញសៀវភៅ "បរមាធិប្បាយខ្មែរ" និពន្ធដោយលោក គឹម - សែត ។ សៀវភៅថ្មីនេះមានប្រធានអក្ស-ខ្មែរ ប្រធានទស្សនវិជ្ជា ប្រធានតិចមួយៗ សុទ្ធតែមានសេចក្ដីណែនាំ សេចក្ដីអធិប្បាយគំរូយ៉ាងសព្វគ្រប់ ។

តម្កល់ទុកត្រឹមត្រូវតាមច្បាប់លេខ ១០១៩
ចុះថ្ងៃទី ១-៩-១៩៧១
បោះពុម្ពលើកទី ១ ចំនួន ១០០០ ក្បាល